**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royal de Droit et des Sciences Economiques**

**Royal University of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# អំណាចចៅក្រមស៊ើបសួរ នៅក្នុងរឿងព្រហ្មទណ្ឌ

ស្រាវជ្រាវពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១ ដល់ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ **ល. យ៉ុន សុខឆេង**

**ល. មុំ គឹមឡុង**

សាស្ត្រាចារ្យណែនាំ ៖

**លោក ហ៊ាង ឡេង**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **យ៉ុន សុខឆេង** និង **មុំ គឹមឡុង** គឺជានិស្សិតឆ្នាំទី៤ ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី ២១ ឆ្នាំសិក្សា ២០១៧-២០២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ**

លោកអ្នកមានគុណទាំងពីរ **លោកឪពុក និង អ្នកម្តាយ** ជាអ្នកមានគុណដ៏ធំធេង ដែលលោកទាំងពីរបានផ្តល់កំណើតដល់កូន និងបានចំណាយពេលវេលាស្ទើរពេញមួយជីវិតដើម្បីចិញ្ចឹមបីបាច់ថែរក្សា ណែនាំ អប់រំទូន្មានប្រៀនប្រដៅដល់រូបកូន ដោយបានជួយទំនុកបម្រុងកូនឱ្យបានទទួលនូវការអប់រំខ្ពង់ខ្ពស់ រហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ប្រកបដោយភាពជោគជ័យគួរជាទីមោទនៈ។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការង ព្រឹទ្ធបុរស ថ្នាក់ដឹកនាំ មន្ត្រីការិយាល័យ និង លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ** ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានផ្តល់នូវចំណេះដឹង ដំបូន្មានល្អៗដើម្បីបង្ហាត់បង្រៀន និងបាន ណែនាំដល់រូបខ្ញុំបាទទាំងពីរយ៉ាងយកចិត្តទុកដាក់ ចាប់តាំងពីពេលចាប់ផ្តើម រហូតដល់ពេលបញ្ចប់ការសិក្សា។

**លោកសាស្ត្រាចារ្យណែនាំ ហ៊ាង ឡេង** ដែលលោកបានចំណាយពេលវេលាយ៉ាងមមាញឹករបស់លោក ក្នុងការត្រួតពិនិត្យ ពន្យល់ ណែនាំ និងកែតម្រូវ ដើម្បីឱ្យយើងខ្ញុំអាចស្រាវជ្រាវ និងតាក់តែងសារណាបញ្ចប់ការសិក្សានេះឡើង ប្រកបដោយភាពជោគជ័យ។

ជាចុងក្រោយ យើងខ្ញុំសូមបួងសួងដល់បារមីនៃវត្ថុស័ក្តិសិទ្ធិទាំងពួងដែលមាននៅលើលោកយើងនេះ សូមតាមថែរក្សា និង ប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ ជូនចំពោះ លោកអ្នកមានគុណទាំងពីរ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការង ព្រឹទ្ធបុរស ថ្នាក់ដឹកនាំ មន្ត្រីការិយាល័យ និងលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ សូមឱ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ជានិច្ចនិរន្តរ៍ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ពេលវេលា៤ឆ្នាំជានិស្សិតផ្នែកនីតិសាស្ត្រនៅ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ត្រូវបានបញ្ចប់ ថ្បិតថាពេលវេលាហាក់ដើរលឿនបន្តិចក៏ពិតមែន តែវាបានប្តូរមកនូវចំណេះដឹង បទពិសោធន៍ និងអនុសាវរីយ៍ល្អៗជាច្រើន ដែលមិនអាចបំភ្លេចបាន។ ការសិក្សាផ្នែកនីតិសាស្ត្រមិនមែនជារឿងងាយស្រួលដូចអ្វីដែលបានគិតនោះទេ ពោលយើងត្រូវសិក្សាបែបវិភាគទៅលើ ទ្រឹស្តី និងបទបញ្ញត្តិនៃច្បាប់នីមួយៗ ហើយការសិក្សាទៀតសោធន៍ទាមទារឱ្យយើងត្រូវយកចិត្តទុកដាក់ ខិតខំប្រឹងប្រែង និងអានសៀវភៅជាច្រើន ដែលជាហេតុធ្វើឱ្យមានការលំបាកយ៉ាងខ្លាំងដល់និស្សិតទាំងអស់គ្នា។ ហេតុដូចនេះហើយ ដើម្បីជាការឆ្លើយតបទៅនឹងការលំបាកដែលយើងខ្ញុំធ្លាប់បានឆ្លងកាត់កន្លងមក និងដើម្បីសម្រួលដល់និស្សិតជំនាន់ក្រោយក្នុងការស្វែងយល់បន្ថែម ទើបសារណាស្តីអំពី **"អំណាចចៅក្រមស៊ើបសួរនៅក្នុងរឿងព្រហ្មទណ្ឌ"** ដែលអ្នកកំពុងកាន់ក្នុងដៃនេះលេចចេញជារូបរាងឡើង។

ជាការពិតណាស់ការតាក់តែងសារណាមួយនេះឡើងមក ត្រូវចំណាយកម្លាំង ការត្រិះរិះពិចារណា ការសិក្សាស្រាវជ្រាវអស់រយៈពេលជាច្រើន និងអានរាល់ឯកសារទាំងឡាយដែលពាក់ព័ន្ធ ដើម្បីអាចទទួលបាននូវសារណាបញ្ចប់ការសិក្សាមួយដែលត្រឹមត្រូវ និងច្បាស់លាស់ ។ ជារួមមក សារណាមួយនេះ គឺជាសមិទ្ធផលថ្មីមួយរបស់យើងខ្ញុំ តាមរយៈការតាក់តែងយ៉ាងយកចិត្តទុកដាក់ ការស្រាវជ្រាវយ៉ាងប្រុងប្រយ័ត្ន និងការខិតខំប្រឹងប្រែងយ៉ាងអស់ពីសមត្ថភាព។ អាស្រ័យហេតុនេះ យើងខ្ញុំសង្ឃឹមថា សារណាបញ្ចប់ការសិក្សាមួយនេះនឹង អាចចូលរួមជាចំណែកខ្លះ ក្នុងការពង្រីកចំណេះដឹង ក៏ដូចជាផ្តល់នូវការស្វែងយល់បន្ថែមទៀត ដល់អ្នកសិក្សាស្រាវជ្រាវ មិត្តអ្នកអាន និងនិស្សិតទាំងអស់ ដែលបានអានអត្ថបទសារណាមួយនេះ។

ជាចុងបញ្ចប់ ថ្វីត្បិតថា សារណាមួយនេះត្រូវបានយើងខ្ញុំតាក់តែងមកយ៉ាងយកចិត្តទុកដាក់ក៏ដោយ ក៏យើងខ្ញុំនៅតែជឿជាក់ថា កំហុសឆ្គងដោយប្រការណាមួយ នឹងអាចកើតមានឡើង ដោយមិនអាចជៀសផុតបានឡើយ ដែលអាចជាកំហុសផ្នែកអក្ខរាវិរុទ្ធ ការប្រើពាក្យពេជន៍ វេយ្យាករណ៍ និង ការភ្ជាប់ឃ្លាល្បះមិនបានត្រឹមត្រូវជាដើម ដូច្នេះយើងខ្ញុំ សូមមេត្តា អភ័យទោសទុកជាមុន។ យើងខ្ញុំនឹងរងចាំទទួលយកការិះគន់ក្នុងន័យស្ថាបនាពីសំណាក់ សាស្ត្រាចារ្យ បញ្ញាវ័ន្ត និងបណ្តាលនិស្សិតទាំងអស់ ដើម្បីចូលរួមកែសម្រួល និងបំពេញបន្ថែមនូវរាល់ចំណុចខ្វះខាតដែលអាចកើតមានឡើងដោយកំហុសអចេតនា។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**អំណាចក្នុងការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ**

**១.១. អំណាចចៅក្រមស៊ើបសួរក្នុងកិច្ចនីតិវិធី** ........ ៤

១.១. ១. កិច្ចនីតិវិធីនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ........ ៤

១.១.១.១. កិច្ចស្រាវជ្រាវទាក់ទងនឹងបុគ្គល ........ ៥

១.១.១.២. ការស្រាវជ្រាវទាក់ទងនឹងវត្ថុ ........ ៦

**១.២. អំណាចក្នុងការចេញដីកាចាត់ឱ្យស៊ើបសួរជំនួស** ........ ១៣

១.២.១. អត្ថន័យនៃដីកាចាត់ឱ្យស៊ើបសួរជំនួស ........ ១៤

១.២.២ ការស៊ើបសួរជំនួសដោយចៅក្រមស៊ើបសួរ ........ ១៤

១.២.៣. ការស៊ើបសួរជំនួសដោយមន្ត្រីនគរបាលយុត្តិធម៌ ........ ១៤

១.២.៣.១. ការស្តាប់ចម្លើយសាក្សី ........ ១៥

១.២.៣.២. ការស្តាប់ទូរស័ព្ទ ........ ១៦

១.២.៣.៣. ការធ្វើការឆែកឆេរ និងការចាប់យកវត្ថុតាង ........ ១៦

១.២.៣.៤. ការឃាត់ខ្លួន ........ ១៧

**ជំពូកទី២**

**អំណាចរបស់ចៅក្រមស៊ើបសួរមុនពេលឃុំខ្លួនជនត្រូវចោទ**

**២.១ អំណាចនៅក្នុងការប្រើប្រាស់វិធានការនិរន្តរាយ** ........ ១៨

២.១.១. ដីកាបង្គាប់ឲ្យចូលខ្លួន ........ ១៨

២.១.១.១ គោលបំណង ........ ១៨

២.១.១.២. និទ្ទេសដែលត្រូវចុះនៅលើដីកាបង្គាប់ឲ្យចូលខ្លួន ........ ១៩

២.១.១.៣. ការជូនដំណឹងអំពីដីកាបង្គាប់ឲ្យចូលខ្លួន ........ ១៩

២.១.២. ដីកាបង្គាប់ឲ្យនាំខ្លួន ........................................................................................................................................ ២០
២.១.២.១. គោលបំណង ........................................................................................................................................ ២០
២.១.២.២. និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឲ្យនាំខ្លួន ........................................................................................ ២០
២.១.២.៣ ការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន ........................................................................................................ ២០
២.១.៣. ដីកាបង្គាប់ឲ្យចាប់ខ្លួន ........................................................................................................................ ២១
២.១.៣.១. គោលបំណង ........................................................................................................................................ ២១
២.១.៣.២. និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឲ្យចាប់ខ្លួន ...................................................................................... ២៤
២.១.៣.៣ ការផ្សព្វផ្សាយជាអន្តរជាតិនូវដីកាបង្គាប់ឲ្យចាប់ខ្លួន .......................................................................... ២៤
២.១.៣.៤. ការបង្ហាញខ្លួនតាមដីកាបង្គាប់ឲ្យចាប់ខ្លួន .......................................................................................... ២៤
១.១.៣.៥. ការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួន ...................................................................................................... ២៥
**២.២. អំណាចនៅក្នុងការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ** ........ ២៥
២.២.១. សញ្ញាណនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ........................................................................................ ២៥
២.២.១.១. គោលការណ៍សេរីភាពរបស់បុគ្គល ...................................................................................................... ២៦
២.២.១.២. គោលការណ៍សន្មតទុកជាមុននូវភាពគ្មានទោស .................................................................................... ២៧
២.២.១.៣. លក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ...................................................................................... ២៧
២.២.២. នីតិវិធីនៃការត្រួតពិនិត្យតាមផ្លូវតុលាការ .......................................................................................... ២៨
២.២.២.១. ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ .......................................................................................... ២៩
២.២.២.២. ការបង្ហាញខ្លួនលើកដំបូង .................................................................................................................. ៣០
២.២.២.៣. ការពិភាក្សាដេញដោលចំពោះមុខ ...................................................................................................... ៣០
២.២.២.៤ ការសួរចម្លើយជនត្រូវចោទ .................................................................................................................. ៣២
២.២.២.៥. ដីកាសម្រេចឲ្យដាក់ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ .................................................... ៣២
២.២.៣. អានុភាពនៃការត្រួតពិនិត្យតាមផ្លូវតុលាការ .......................................................................................... ៣៣
២.២.៣.១. កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ .................................................................................... ៣៣
២.២.៣.២. ការកែប្រែកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ .................................................................... ៣៤

២.២.៤. ការបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ.......................................................................៣៦

## ជំពូកទី៣

## អំណាចនៅក្នុងការសម្រេចឃុំខ្លួនជនត្រូវចោទដោយចៅក្រមស៊ើបសួរ

**៣.១. អំណាចក្នុងការចេញដីកាបង្គាប់ឲ្យឃុំខ្លួនជនត្រូវចោទ**.......................................៣៨
៣.១.១ គោលបំណងនៃការចេញដីកាបង្គាប់ឲ្យឃុំខ្លួន....................................................................៣៨
៣.១.២. លក្ខខ័ណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន .................................................................... ៤០
៣.១.២.១. គោលការណ៍នៃការឃុំខ្លួនបណ្តោះអាសន្ន ......................................................... ៤០
៣.១.២.២. ករណីនៃការឃុំខ្លួនបណ្តោះអាសន្ន .................................................................... ៤០
**៣.២. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន**.................................................................... ៤១
៣.២.១. ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះបទឧក្រិដ្ឋ និង បទមជ្ឈឹម................................ ៤១
៣.២.១.១. ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទឧក្រិដ្ឋ ...........................................៤២
៣.២.១.២ ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទមជ្ឈឹម ...........................................៤៣
៣.២.២ ចិរវេលាចំពោះការឃុំខ្លួនបណ្តោះអាសន្នក្នុងករណីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ.....................៤៣
**៣.៣ អំណាចរបស់ចៅក្រមស៊ើបសួរក្រោយពេលសម្រេចឃុំខ្លួនបណ្តោះអាសន្ន**........... ៤៤
៣.៣.១ ការដោះលែងជនត្រូវចោទអោយនៅក្រៅឃុំដោយចៅក្រមស៊ើបសួរ ............................ ៤៥
៣.២.២. ការដោះលែងជនត្រូវចោទអោយនៅក្រៅឃុំតាមបណ្តឹងរបស់ព្រះរាជអាជ្ញា........................... ៤៥
៣.៣.៣ ការដោះលែងជនត្រូវចោទអោយនៅក្រៅឃុំ តាមពាក្យសុំរបស់ជនត្រូវចោទ.......................... ៤៥

## ជំពូកទី៤

## អំណាចនៅក្នុងការបិទការស៊ើបសួរតាមដីកាដំណោះស្រាយ

**៤.១. នីតិវិធីនៃការបិទការស៊ើបសួរ** ...........................................................................៤៧
៤.១.១. សញ្ញាណទូទៅនៃការបិទការស៊ើបសួរ...................................................................៤៧
៤.១.២ លក្ខខ័ណ្ឌដើម្បីបិទការស៊ើបសួរ.......................................................................... ៤៨
៤.១.២.១. កិច្ចនីតិវិធីត្រូវបំពេញ ...................................................................................... ៤៩
៤.១.២.២. ភាពពេញលេញនៃការប្រមូលភស្តុតាង ................................................................ ៤៩

៤.១.៣. ការជូនដំណឹងស្តីពីការបិទការស៊ើបសួរ ..... ៥០
**៤.២. ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ** ..... ៥០
៤.២.១. ប្រភេទនៃដីកាដំណោះស្រាយ ..... ៥០
៤.២.១.១ ដីកាបញ្ជូនទៅជំនុំជម្រះ ..... ៥១
៤.២.១.២ ដីកាលើកលែងការចោទប្រកាន់ ..... ៥១
៤.២.២. លក្ខណៈរួមនៃដីកាដំណោះស្រាយ ..... ៥២
**៤.៣. អានុភាពគតិយុត្តនៃការបិទការស៊ើបសួរ** ..... ៥៣
៤.៣.១. បញ្ចប់កិច្ចស៊ើបសួរ ..... ៥៣
៤.៣.១.១ បិទបញ្ចប់នីតិវិធីស៊ើបសួរ ..... ៥៣
៤.៣.១.២ ការបញ្ចប់វិធាននៃការអនុវត្តកាតព្វកិច្ច ..... ៥៤
៤.៣.១.៣. សម្រេចទៅលើវត្ថុដែលចាប់យក ..... ៥៥
៤.៣.២. ភាពមិនដាច់ខាតនៃការបញ្ចប់នីតិវិធី ..... ៥៥
៤.៣.២.១ គ្មានអាជ្ញាអស់ជំនុំ ..... ៥៥
៤.៣.២.២. ការបើកការស៊ើបសួរជាថ្មី ..... ៥៦
៤.៣.៣. តម្លៃគតិយុត្តិនៃការបិទបញ្ចប់ការស៊ើបសួរ ..... ៥៧
៤.៣.៣.១. ចងកាតព្វកិច្ចចៅក្រមជំនុំជម្រះ ..... ៥៧
៤.៣.៣.២ លុបលាងមោឃភាពនៃកិច្ចនីតិវិធី ..... ៥៨
**សេចក្តីសន្និដ្ឋាន** ..... ៥៩
**អនុសាសន៍** ..... ៦១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ គឺជាសមិទ្ធផល និងជាលទ្ធផលការងារអស់រយៈពេលជិត១០ឆ្នាំ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងយុត្តិធម៌ជាសេនាធិការក្នុងការរៀបចំឡើង ដោយមានជំនួយគាំទ្រ ពីសហប្រតិបត្តិការបារាំង។ នីតិវិធីព្រហ្មទណ្ឌ គឺជាច្បាប់ដ៏ចំបង និងជាមធ្យោបាយដ៏សំខាន់មួយរបស់តុលាការព្រហ្មទណ្ឌ ហើយក៏ជាបណ្តុំវិធាន ដែលត្រូវបានយកទៅអនុវត្ត ចាប់ពីពេល ដែលមានការសង្ស័យពីការប្រព្រឹត្តបទល្មើស រហូតដល់ពេលដែលជនល្មើស ត្រូវបានកំណត់អត្តសញ្ញាណ និងផ្តន្ទាទោស។

លើសពីនេះ ក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ញត្តិយ៉ាងច្បាស់លាស់ អំពីគោលការណ៍គ្រឹះមួយចំនួន ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព ក្នុងការស្វែងរកជនល្មើស ការចោទប្រកាន់ ការស៊ើបសួរ និងការជំនុំជំរះ ព្រមទាំងការគោរពនូវសេរីភាពបុគ្គលដោយស្របទៅតាមគោលការណ៍ ដែលបានកំណត់ដោយ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាយើងផងដែរ។ នៅក្នុងនោះ ក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់នូវអំណាចដ៏សំខាន់មួយ ឱ្យទៅចៅក្រមស៊ើបសួរ ដើម្បីដំណើរការនីតិវិធីព្រហ្មទណ្ឌ នោះគឺការបើកការស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងទាំងដាក់បន្ទុកផង និងដោះបន្ទុកផង ក្នុងគោលបំណងធ្វើយ៉ាងណារកឱ្យឃើញនូវការពិតដែលបានកើតឡើង ។

ជាការពិតណានៅពេលដែលមានបទល្មើសណាមួយបានកើតឡើង វិធានការផ្លូវច្បាប់មួយចំនួននឹងត្រូវបានមន្ត្រីអនុវត្តច្បាប់យកមកប្រើប្រាស់ ដូចជា ការស៊ើបអង្កេត ការចោទប្រកាន់ ក៏ដូចជា ការស៊ើបសួរជាដើម។ នៅក្នុងនោះ ការស៊ើបសួរ ត្រូវបំពេញដោយចៅក្រមស៊ើបសួរ និងប្រើប្រាស់អំណាចទាំងអស់ដែលទទួលបានពីក្រមនីតិវិធីព្រហ្មទណ្ឌនេះ ដោយយើងនឹងលើកយកមកបកស្រាយឱ្យបានក្បោះក្បាយនៅក្នុងអត្ថបទស្រាវជ្រាវមួយនេះ។ អត្ថបទស្រាវជ្រាវមួយនេះ អាចធ្វើឱ្យ អ្នកស្រាវជ្រាវគ្រប់មជ្ឈដ្ឋាន ជាពិសេស និស្សិតគ្រប់រូប មានការយល់ដឹងកាន់តែច្បាស់ និងទូលំទូលាយថែមទៀតអំពី **អំណាចរបស់ចៅក្រមស៊ើបសួរនៅក្នុងរឿងព្រហ្មទណ្ឌ** ។

ជាការពិតណាស់ ការសិក្សាស្វែងយល់ពី អំណាចចៅក្រមស៊ើបសួរក្នុងរឿងព្រហ្មទណ្ឌ គឺជាភាពចាំបាច់មួយដែលអ្នកសិក្សាស្រាវជ្រាវ និង និស្សិតគ្រប់រូបត្រូវតែសិក្សាស្វែងយល់បន្ថែមទៀត។ ដោយហេតុថា និស្សិតមួយចំនួន ព្រមទាំងយើងខ្ញុំផ្ទាល់ ពិតជាមានការលំបាកក្នុងការស្វែងយល់ ឱ្យបានច្បាស់លាស់ពី អំណាចចៅក្រមស៊ើបសួរនៅក្នុងរឿងព្រហ្មទណ្ឌ ថាតើចៅក្រមស៊ើបសួរប្រើប្រាស់អំណាចរបស់លោកយ៉ាងដូចម្តេចខ្លះ? ហេតុនេះ ដើម្បីផ្សារភ្ជាប់ទៅនឹងបញ្ហាទាំងនេះ ការសិក្សាស្រាវជ្រាវរបស់ យើងខ្ញុំនឹងដាក់ចេញនូវចំណោទបញ្ហាសំខាន់ៗ ដូចខាងក្រោមនេះ ៖

- តើអំណាចក្នុងការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរប្រព្រឹត្តទៅយ៉ាងដូចម្តេច?
- តើនៅមុនពេលឃុំខ្លួនជនត្រូវចោទចៅក្រមស៊ើបសួរមានអំណាចអ្វីខ្លះ?
- តើអំណាចរបស់ចៅក្រមស៊ើបសួរក្នុងការឃុំខ្លួនជនត្រូវចោទប្រព្រឹត្តទៅបែបណាខ្លះ?

- តើចៅក្រមស៊ើបសួរបិទការស៊ើបសួរដោយវិធីណា?

គោលបំណងសំខាន់ៗមួយចំនួន នៅក្នុងការស្រាវជ្រាវនេះមានដូចខាងក្រោម ៖

- ស្វែងយល់ឱ្យបានស៊ីជម្រៅ ពីការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ ជាពិសេសដំណើការនីតិវិធីក្នុងការអនុវត្តអំណាចរបស់ចៅក្រមស៊ើបសួរក្នុងកិច្ចនេះ។
- ស្វែងយល់ឱ្យបានស៊ីជម្រៅពី អំណាចរបស់ចៅក្រមស៊ើបសួរក្នុងការឃុំខ្លួនជនត្រូវចោទ និងការអនុវត្តនីតិវិធីក្នុងការឃុំខ្លួន។
- ស្វែងយល់ឱ្យបានស៊ីជម្រៅ ពីវិធានការនិរន្តរាយ របស់ចៅក្រមស៊ើបសួរ។
- ស្វែងយល់ឱ្យបានស៊ីជម្រៅពី ការបិទការស៊ើបសួររបស់ ចៅក្រមស៊ើបសួរ តាមរយៈដីកាដំណោះស្រាយ។
- ចងក្រងទុកឯកសារ សម្រាប់អ្នកសិក្សាស្រាវជ្រាវ ក៏ដូចជានិស្សិត ឱ្យមានការយល់ដឹងបន្ថែមពីអំណាចរបស់ចៅក្រមស៊ើបសួរនៅក្នុងរឿងព្រហ្មទណ្ឌ។
- ចងក្រងទុកជា ឯកសារ និងស្នាដៃសម្រាប់យើងខ្ញុំផ្ទាល់។

យើងខ្ញុំសូមជម្រាបជូនថា សារណាបញ្ចប់ការសិក្សាមួយនេះ ផ្តោតសំខាន់តែទៅលើដំណាក់កាលស៊ើបសួរប៉ុណ្ណោះ ដោយចាប់ផ្តើមពីការបើកការស៊ើបសួររបស់ចៅក្រមស៊ើបសួរ រហូតដល់ការបិទការស៊ើបសួររបស់ចៅក្រមស៊ើបសួរតាមរយៈដីកាដំណោះស្រាយ។ ដោយហេតុថាពេលវេលាមានកំណត់ យើងខ្ញុំមិនអាចលើកយកនូវនីតិវិធី ស្តីពីមោឃភាពនៃការស៊ើបសួរ និងនីតិវិធីនៅក្នុងសភាស៊ើបសួរនៃសាលាឧទ្ធរណ៍យកមកសិក្សា និងបកស្រាយបាននោះទេ។

យើងខ្ញុំសង្ឃឹមថា សារណាបញ្ចប់ការសិក្សាមួយនេះនឹងអាចដោះស្រាយ និងបកស្រាយចម្ងល់មួយចំនួន របស់អ្នកសិក្សាស្រាវជ្រាវ និង និស្សិតទាំងអស់ ដែលធ្លាប់មានទាក់ទងជាមួយនឹងប្រធានបទមួយនេះ។ លើសពីនេះទៅទៀតតាមរយៈសារណាបញ្ចប់ការសិក្សានេះ យើងខ្ញុំអាចមានឱកាសទាញយកចំណេះដឹងយ៉ាងច្រើនសន្ធឹកសន្ធាប់ ពីការស្រាវជ្រាវទៅលើប្រធានបទមួយនេះផងដែរ។ ជាការពិតណាស់ថ្វីត្បិតតែសារណាបញ្ចប់ការសិក្សាមួយនេះគ្រាន់តែជាសមិទ្ធផលដ៏តូចមួយ ប៉ុន្តែយើងខ្ញុំជឿជាក់ថា វានឹងផ្តល់ជាបទពិសោធន៍ដ៏ល្អមួយក្នុងការអភិវឌ្ឍចំណេះដឹង និងការស្វែងយល់បន្ថែម របស់យើងខ្ញុំផ្ទាល់ ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវ និងនិស្សិតទាំងអស់ដែលបានអានអត្ថបទសារណាមួយនេះ។

អត្ថបទសារណានេះ គឺយើងខ្ញុំបានធ្វើការសិក្សាតាមបែបទ្រឹស្តីផង និងរួមបញ្ចូលជាមួយនឹងការអនុវត្តជាក់ស្តែងមួយចំនួនផង។ ហេតុនេះ សារណាបញ្ចប់ការសិក្សាមួយនេះ ត្រូវបានយើងខ្ញុំចងក្រងឡើង ដោយប្រើប្រាស់វិធីសាស្ត្រមួយចំនួន ដូចជា ការអាន ការវិភាគ ទៅលើបទបញ្ញត្តិច្បាប់ ការរំលឹកឡើងវិញនូវអត្ថបទ ដែល

បានបោះពុម្ពផ្សាយជាសៀវភៅ ក៏ដូចជាសៀវភៅដែលបានបង្ហោះតាមរយៈប្រព័ន្ធអេឡិចត្រូនិចជាដើម។ ប្រភពឯកសារសំខាន់ៗដើម្បីចងក្រង សារណានេះ រួមមាន រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មេរៀននីតិវិធីព្រហ្មទណ្ឌ ចេញផ្សាយដោយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ឆ្នាំ២០០៧ ព្រមទាំងឯកសារសំខាន់ផ្សេងៗទៀតដូចមានកំណត់ក្នុងឯកសារយោង។ លើសពីនេះទៀត យើងខ្ញុំក៏បានលើកយក និងរួមបញ្ចូលនូវបទពិសោធន៍ យើងខ្ញុំផ្ទាល់មួយចំនួនផងដែរ អំពីការអនុវត្តជាក់ស្តែងនៅក្នុងប្រព័ន្ធតុលាការសព្វថ្ងៃនេះ។

ដើម្បីផ្តល់នូវភាពងាយស្រួល យើងខ្ញុំនឹងធ្វើការបែងចែក អត្ថបទសារណានេះចេញជា ៤ជំពូក ដើម្បីយកមកពន្យល់ និងបកស្រាយ ជូនមិត្តអ្នកអានទាំងអស់ ទៅតាមលំដាប់លំដោយដូចខាងក្រោមៈ

**ជំពូកទី១ ៖ អំណាចក្នុងការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ**

**ជំពូកទី២ ៖ អំណាចរបស់ចៅក្រមស៊ើបសួរមុនពេលឃុំខ្លួនជនត្រូវចោទ**

**ជំពូកទី៣ ៖ អំណាចនៅក្នុងការសម្រេចឃុំខ្លួនជនត្រូវចោទដោយចៅក្រមស៊ើបសួរ**

**ជំពូកទី៤ ៖ អំណាចនៅក្នុងការបិទការស៊ើបសួរតាមដីកាដំណោះស្រាយ**

# ជំពូកទី១

# អំណាចក្នុងការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

## ១.១. អំណាចចៅក្រមស៊ើបសួរក្នុងកិច្ចនីតិវិធី

ដូចយើងបានដឹងហើយថានៅក្នុងរឿងព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរ មានតួនាទីយ៉ាងសំខាន់ក្នុងការស៊ើបសួរ ដោយចៅក្រមស៊ើបសួរ ធ្វើការស៊ើបសួរទាំងដាក់បន្ទុកផង និងដោះបន្ទុកផង។ ការស៊ើបសួរនេះធ្វើឡើងក្នុងគោលដៅតែមួយគត់គឺ ដើម្បីស្វែងរកនូវការពិត។ ចៅក្រមស៊ើបសួរ អាចបើកការស៊ើបសួរបានតាមរយៈ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា និងបណ្តឹងដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[1] ដែលធ្វើឡើងដោយជនរងគ្រោះផ្ទាល់ ឬធ្វើឡើងដោយមេធាវីក្នុងនាមជនរងគ្រោះ។ ក្នុងករណីចៅក្រមស៊ើបសួរ បើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿង នោះចៅក្រមស៊ើបសួរអាចបើកការស៊ើបសួរបានតែចំពោះអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាប៉ុណ្ណោះ។ ប្រសិនជាពេលដែលធ្វើការស៊ើបសួរទៅរកឃើញ នូវអង្គហេតុថ្មីណាមួយដែលអាចជាបទល្មើសព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុថ្មីនេះ ទៅព្រះរាជអាជ្ញា លើកលែងតែអង្គហេតុថ្មីនោះគឺជាស្ថានទម្ងន់ទោសទៅលើអង្គហេតុ ដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកដំបូង។ ព្រះរាជអាជ្ញាអាចប្តឹងសុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអង្គហេតុថ្មីនោះតាមរយៈ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។[2] ការស៊ើបសួរត្រូវធ្វើដោយខានមិនបានចំពោះបទឧក្រិដ្ឋ ព្រោះតែវាជាបទល្មើសដែលធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់ទ្រព្យសម្បត្តិ កិត្តិយស សេចក្តីថ្លៃថ្នូរ និង អាយុជីវិតរបស់មនុស្ស។ ចំណែកបទមជ្ឈិមវិញការស៊ើបសួរអាចធ្វើក៏បានមិនធ្វើក៏បាន[3] ដោយអាស្រ័យទៅលើស្ថានភាពជាក់ស្តែងនៃភាពធ្ងន់ធ្ងររបស់បទល្មើសនោះ។

ចៅក្រមស៊ើបសួរអាចប្រើប្រាស់អំណាចទាំងនេះដោយខ្លួនឯងផ្ទាល់ ឬ ប្រគល់អំណាចឱ្យទៅចៅក្រមនៃតុលាការរបស់ខ្លួន ឬតុលាការផ្សេងទៀត មន្ត្រីនគរបាលយុត្តិធម៌ ឬដល់អង្គភាពនគរបាលយុត្តិធម៌ដើម្បីបំពេញកិច្ចស៊ើបសួរជំនួស[4] តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស។ ដើម្បីយល់កាន់តែច្បាស់ យើងនឹងធ្វើការសិក្សាទៅលើចំណុចបន្ថែមអំពី **(១.១.១) កិច្ចនីតិវិធីនៃការស៊ើបសួរ** និង **(១.១.២) ការចាត់ឱ្យស៊ើបជំនួស។**

[1] មាត្រា១២៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[2] មាត្រា១២នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[3] មាត្រា១២២នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[4] មាត្រា១៧៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

### ១.១.១. កិច្ចនីតិវិធីនៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ សម្រាប់បង្ហាញឱ្យឃើញនូវការពិតដោយអនុលោមតាមច្បាប់។ ដូច្នេះចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរដោយសេរី និងឯករាជ្យដោយមិនទទួលអធិបញ្ជាពីភាគី ឬអាជ្ញាធរណាមួយឡើង។[5] ចៅក្រមស៊ើបសួរត្រូវមាន ក្រឡាបញ្ជីម្នាក់អមជានិច្ច ប៉ុន្តែទោះក្នុងករណីណាក៏ដោយក៏ក្រឡាបញ្ជីមិនអាចបំពេញកិច្ចដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរបានទេ[6]។ ចៅក្រមស៊ើបសួរអាចចុះដល់ទីកន្លែងជាមួយក្រឡាបញ្ជីរបស់ខ្លួន ដើម្បីបំពេញកិច្ចស៊ើបសួរដែលស្ថិតនៅលើវិសាលភាពនៃសម្ថកិច្ចដែនដីនៃតុលាការជាន់ដំបូង ដើម្បីបំពេញកិច្ចស៊ើបសួរដែលខ្លួនយល់ថាមានប្រយោជន៍ជាអាទិ៍ ការពិនិត្យសម្ភារៈ ការឆែកឆេរ និងការចាប់យកវត្ថុតាង។ ប៉ុន្តែប្រសិនជាការចាំបាច់នៃការស៊ើបសួរតម្រូវ ចៅក្រមស៊ើបសួរអាចចុះដល់ទីកន្លែងជាមួយក្រឡាបញ្ជីរបស់ខ្លួនដើម្បីបំពេញកិច្ចស៊ើបសួរដែលស្ថិតនៅលើវិសាលភាពដែនដីជាតិទាំងមូល ដោយចៅក្រមស៊ើបសួរត្រូវជូនដំណឹងជាមុន ដល់ព្រះរាជអាជ្ញាអមតុលាការជាន់ដំបូង នៅក្នុងដែនដីដែលខ្លួន ធ្វើដំណើរទៅកាន់នោះ ហើយចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្ដីពីប្រតិបត្តិការរបស់ខ្លួន[7]។

នៅក្នុងការបំពេញកិច្ចស៊ើបសួររបស់ ចៅក្រមស៊ើបសួរដើម្បីស្វែងរកភស្តុតាងទាំងដាក់បន្ទុកផង និងដោះបន្ទុកផងនោះ ប្រព្រឹត្តទៅតាមកម្មវត្ថុពីរយ៉ាងដូចជា ៖ (១.១.១.១) **កិច្ចស្រាវជ្រាវទាក់ទងនឹងបុគ្គល** និង **(១.១.១.២) ការស្រាវជ្រាវទាក់ទងនឹងវត្ថុ**

#### ១.១.១.១. កិច្ចស្រាវជ្រាវទាក់ទងនឹងបុគ្គល

នេះគឺជាអំណាចមួយរបស់ចៅក្រមស៊ើបសួរពាក់ព័ន្ធនឹងការស្រាវជ្រាវទាក់ទងនឹងបុគ្គល។ ចៅក្រមស៊ើបសួរប្រើប្រាស់អំណាចរបស់ខ្លួននៅក្នុងកិច្ចស្រាវជ្រាវទាក់ទងនឹងបុគ្គលតាមរយៈ ៖

**(ក) ការសួរចម្លើយជនត្រូវចោទ (ខ) ការស្តាប់ចម្លើយ (គ) ការសួរតទល់**

##### ក. ការសួរចម្លើយជនត្រូវចោទ

បន្ទាប់ពីត្រូវបានចោទប្រកាន់ពីសំណាក់អយ្យការ ជនសង្ស័យនឹងប្រែក្លាយទៅជាជនត្រូវចោទ[8]។ ដូចនេះ ការសួរចម្លើយសំដៅសួរទៅលើបុគ្គលដែលត្រូវបានដាក់ពិរុទ្ធរួចហើយ និងចោទសួរគ្រប់សំណួរដែលចាំបាច់ក្នុងការបង្ហាញការពិត។ គ្រប់ពេលសួរចម្លើយ ជនត្រូវចោទត្រូវមានមេធាវីអមជានិច្ច ហើយចៅក្រមស៊ើបសួរមិនអាចសួរចម្លើយជនត្រូវចោទដោយគ្មានវត្តមានរបស់មេធាវីឡើយ ដែលមេធាវីរបស់ជនត្រូវចោទត្រូវបានកោះហៅ

[5] មេរៀននីតិវិធីព្រហ្មទណ្ឌ, រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០០៧, ទំព័រ ៦៧

[6] មាត្រា១២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[7] មាត្រា១៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[8] នីតិវិធីព្រហ្មទណ្ឌ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត,២០១៣-២០១៤, ទំព័រ ៨

យ៉ាងតិច៥ថ្ងៃមុនការសួរចម្លើយមកដល់។ ប៉ុន្តែការកំណត់បែបនេះមិនមែនមានន័យថាអវត្តមានរបស់មេធាវីនឹងធ្វើឱ្យរាំងស្ទះដល់នីតិវិធីនោះទេ ពោលចៅក្រមស៊ើបសួរក៏អាចសួរចម្លើយជនត្រូវចោទបានផងដែរ ប្រសិនបើជនត្រូវចោទបានបោះបង់យ៉ាងជាក់លាក់នូវវត្តមានរបស់មេធាវីរបស់ខ្លួន ឬ បើមេធាវីត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយ មិនចូលបង្ហាញខ្លួនតាមការកំណត់។ និទ្ទេសនៃអវត្តមាននេះនឹងត្រូវបានចុះក្នុងកំណត់ហេតុសួរចម្លើយ។ ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរក៏អាចសួរចម្លើយដោយពុំចាំបាច់កោះហៅមេធាវី។[9]ភាពបន្ទាន់នេះត្រូវ បញ្ជាក់ឱ្យបានច្បាស់លាស់ និងស្ថិតនៅក្នុងករណីដែលចែង ដោយកថាខណ្ឌ៤ នៃមាត្រា ១៤៥ នៃក្រមព្រហ្មនីតិវិធីព្រហ្មទណ្ឌ ដូចជាគ្រោះថ្នាក់ដល់អាយុជីវិត ហានិភ័យនៃការបាត់បង់តម្រុយនៃភស្តុតាង។ ប្រភេទនៃភាពបន្ទាន់ត្រូវចុះនិទ្ទេស នៅក្នុងកំណត់ហេតុ។ នៅក្នុងពេលសួរចម្លើយ ព្រះរាជអាជ្ញាអាចមានវត្តមាន។ ព្រះរាជអាជ្ញា និងមេធាវីអាចសួរជនត្រូវចោទគ្រប់សំណួរ ដោយទទួលការអនុញ្ញាតពីចៅក្រមស៊ើបសួរ[10]។ ការបដិសេធលទ្ធភាពលើកសំណួរនេះ ត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុ។ ក្នុងរយៈពេលយ៉ាងយូរបំផុត៤ខែ គិតចាប់ពីពេលសួរចម្លើយនៅពេលបង្ហាញខ្លួនលើកដំបូង ប្រសិនបើជនត្រូវចោទមិនត្រូវបានសួរចម្លើយ ឬសួរតទល់ នោះជនត្រូវចោទមានសិទ្ធិស្នើសុំផ្តល់ចម្លើយ ចំណែកចៅក្រមស៊ើបសួរត្រូវតែទទួលចម្លើយ។ ក្នុងករណីដែលចៅក្រមស៊ើបសួរមិនព្រមកោះហៅជនត្រូវចោទក្នុងថេរវេលា ១ខែ បន្ទាប់ពីមានការស្នើសុំទេ ជនត្រូវចោទអាចធ្វើការប្តឹងទៅសភាស៊ើបសួរបាន[11]។ នៅពេលដែលការសួរចម្លើយត្រូវបានបញ្ចប់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីត្រូវចុះហត្ថលេខានៅគ្រប់ទំព័រនៃកំណត់ហេតុសួរចម្លើយ ចំណែកឯជនត្រូវចោទវិញត្រូវផ្តិតមេដៃទទួលស្គាល់ចម្លើយខ្លួន និងអានចម្លើយរបស់ខ្លួន ក្នុងករណីដែលជនត្រូវចោទមិនចេះអានអក្សរ ក្រឡាបញ្ជីត្រូវអានចម្លើយឱ្យជនត្រូវចោទស្តាប់។

នៅគ្រប់កំណត់ហេតុរបស់ចៅក្រមស៊ើបសួរត្រូវមានចុះនិទ្ទេសដូចតទៅ៖

- ឈ្មោះរបស់ចៅក្រមស៊ើបសួរ
- ឈ្មោះក្រឡាបញ្ជី
- លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង
- កាលបរិច្ឆេទនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ
- ប្រភេទនៃបទល្មើស ដែលបានចង្អុលប្រាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ
- កាលបរិច្ឆេទនៃការធ្វើកំណត់ហេតុ។

[9] មាត្រា១៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[10] មាត្រា១៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[11] មាត្រា១៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

កំណត់ហេតុមិនត្រូវទុកឱ្យមានចន្លោះបន្ទាត់ទំនេរទេ ការឆូតលុប ឬការយោងត្រូវតែបញ្ជាក់ដោយហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីនៅរឹមទំព័រ[12]។

### ខ . ការស្តាប់ចម្លើយ

ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយបុគ្គលគ្រប់រូប ដែលចម្លើយនោះអាចមានប្រយោជន៍នៅក្នុងការសំដែងឱ្យឃើញការពិត[13]។ នៅក្នុងការស្តាប់ចម្លើយ ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយទៅលើបុគ្គល២ប្រភេទដូចជា៖ **(ក.១) ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី** និង **(ក.២) ការស្តាប់ចម្លើយសាក្សី។**

#### ក.១. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

ការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺជានីតិវិធីមួយដែលមានសារៈសំខាន់ដើម្បីចង្អុលបង្ហាញផ្លូវដល់ចៅក្រមស៊ើបសួរ អំពីហេតុការណ៍ ព្យសនកម្ម និង អំពើទាំងឡាយណាដែលជាប់ពាក់ព័ន្ធជាមួយនឹងរឿងក្តីនេះ ដើម្បីអាចឱ្យចៅក្រមស៊ើបសួរ អាចស្វែងរកការពិតបានកាន់តែងាយស្រួល និងច្បាស់លាស់ផងដែរ។ នៅក្នុងករណីដែលដើមបណ្តឹងរដ្ឋប្បវេណីមានមេធាវី ចៅក្រមស៊ើបសួរត្រូវធ្វើការកោះហៅមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងតិចបំផុត៥ថ្ងៃមុនការស្តាប់ចម្លើយ។ ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានស្តាប់ចម្លើយនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ។ ប៉ុន្តែអវត្តមានរបស់មេធាវីនឹងមិនធ្វើឱ្យរាំងស្ទះដល់ ដំណើរការនីតិវិធីនោះទេ ពោលចៅក្រមស៊ើបសួរក៏អាចស្តាប់ចម្លើយ ដើមបណ្តឹងរដ្ឋប្បវេណីបានផងដែរ ប្រសិនបើ ដើមបណ្តឹងរដ្ឋប្បវេណីបានបោះបង់យ៉ាងជាក់លាក់នូវវត្តមានមេធាវីរបស់ខ្លួន ឬ បើមេធាវីត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយ មិនចូលបង្ហាញខ្លួនទៅតាមការកំណត់។ និទ្ទេសនៃអវត្តមាននេះនឹងត្រូវបានចុះក្នុងកំណត់ហេតុស្តាប់ចម្លើយ។[14] ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរក៏អាចស្តាប់ចម្លើយ ដើមបណ្តឹងរដ្ឋប្បវេណីដោយពុំចាំបាច់កោះហៅមេធាវី ។ ភាពបន្ទាន់នេះ ត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់ និងស្ថិតនៅក្នុងករណីដែលចែង ដោយកថាខណ្ឌ៤ នៃមាត្រា ១៥០ នៃក្រមព្រហ្មនីតិវិធីព្រហ្មទណ្ឌ ដូចជាគ្រោះថ្នាក់ដល់អាយុជីវិត ហានិភ័យនៃការបាត់បង់តម្រុយនៃភស្តុតាង។ ប្រភេទនៃភាពបន្ទាន់ ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។ នៅក្នុងពេលស្តាប់ចម្លើយ ព្រះរាជអាជ្ញាក៏អាចមានវត្តមាន។ ព្រះរាជអាជ្ញា និងមេធាវីអាចសួរ ដើមបណ្តឹងរដ្ឋប្បវេណីគ្រប់សំណួរ ដោយទទួលការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ ការបដិសេធលទ្ធភាពលើកសំណួរនេះ ត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុ។

[12] មាត្រា២៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[13] មាត្រា១៥៣ កថាខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[14] មាត្រា១៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

### គ.២. ការស្តាប់ចម្លើយសាក្សី

នៅក្នុងសំណុំរឿងព្រហ្មទណ្ឌ សាក្សីគឺជាអ្នកជួយបញ្ជាក់បំភ្លឺអំពីអង្គហេតុដែលពួកគេបានឃើញបានឮ ឬបានដឹងទាក់ទងនឹងព្រឹត្តិការណ៍នៃបទល្មើសទៅកាន់ចៅក្រម និងអង្គសវនាការ។ សាក្សីដើរតួយ៉ាងសំខាន់ក្នុងដំណើរការស្វែងរកឲ្យឃើញនូវយុត្តិធម៌ក្នុងរឿងក្តី។ គេអាចឱ្យនិយមន័យសាក្សីបានថាគឺ ជាបុគ្គលដែលស្ថិតនៅក្រៅអង្គហេតុដែលជាកម្មវត្ថុនៃ ការចោទប្រកាន់ និងជាបុគ្គលដែលអាចផ្តល់នូវព័ត៌មាន ដែលជាប្រយោជន៍អាចជួយដល់ចៅក្រមស៊ើបសួរក្នុងការបង្ហាញការពិត។[15] ដូចនេះប្រសិនជាចៅក្រមស៊ើបសួរ យល់ឃើញថាសាក្សីមានសារៈសំខាន់ដើម្បីបំភ្លឺរឿងក្តី ចៅក្រមស៊ើបសួរ អាចកោះហៅសាក្សីឱ្យចូលខ្លួនដើម្បីបំភ្លឺផងដែរ។ នៅពេលដែលសាក្សីត្រូវបានកោះហៅដោយចៅក្រមស៊ើបសួរឱ្យចូលមកបំភ្លឺ នៅពេលនោះសាក្សីត្រូវមានកាតព្វកិច្ចបង្ហាញខ្លួន។ ក្នុងករណីដែលសាក្សីឈឺ ឬ មិនអាចធ្វើដំណើរបានចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីអាចចុះទៅកាន់ លំនៅឋាន ឬទីកន្លែងដែលសាក្សីនោះនៅ ដើម្បីទទួលបានចម្លើយ[16]។ ប៉ុន្តែប្រសិនបើសាក្សីបដិសេធមិនចូលបង្ហាញខ្លួន ចៅក្រមស៊ើបសួរអាចស្នើសុំឱ្យកងកម្លាំងសាធារណៈបង្ខំសាក្សីនោះឱ្យចូលមកបង្ហាញខ្លួនបាន[17]។ លើសពីនេះទៅទៀត ការដែលសាក្សីបដិសេធមិនចូលខ្លួនមកផ្តល់ចម្លើយសាក្សីនោះអាចត្រូវបានផ្តន្ទាទោសដោយច្បាប់ដែលមានចែងនៅក្នុង ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាក្នុង មាត្រា៥៣៨ (បទបដិសេធក្នុងការចូលខ្លួន) ។ ក្រោយពេលបង្ហាញខ្លួនសាក្សីត្រូវធ្វើសម្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនដើម្បីបញ្ជាក់ថាខ្លួននឹងឆ្លើយតែការពិតប៉ុណ្ណោះ[18]។ សាក្សីមិនត្រូវបានអនុញ្ញាតឱ្យឆ្លើយអ្វីដែលខុសពីការពិត រងការគំរាមកំហែង ឬ ការគាប់សង្កត់ពីសំណាក់ជនណាមួយនោះទេ ។ ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយសាក្សីដាច់ដោយឡែកពីគ្នា ដោយគ្មានវត្តមានជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ហើយចៅក្រមស៊ើបសួរ ក៏អាចសួរតទល់គ្នារវាងជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីបានផងដែរ។[19] ប៉ុន្តែចៅក្រមស៊ើបសួរមិនអាចស្តាប់ចម្លើយក្នុងឋានៈជាសាក្សីនូវបុគ្គលណាមួយដែលមានតម្រុយពិរុទ្ធភាពថាបានប្រព្រឹត្តិបទល្មើសនោះទេ។ ទន្ទឹមគ្នានោះក៏មាន បុគ្គលមួយចំនួនដែលជាសាក្សី និងត្រូវបានច្បាប់អនុញ្ញាតឱ្យរួចផុតពីការធ្វើសម្បថរួមមាន៖

- ឪពុក ម្តាយ និងបុព្វជនគ្រប់រូបរបស់ជនត្រូវចោទ។
- កូនប្រុស កូនស្រី និងបច្ឆាជនគ្រប់រូបផ្សេងទៀតរបស់ជនត្រូវចោទ។

---

[15] មេរៀននីតិវិធីព្រហ្មទណ្ឌ, រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០០៧, ទំព័រ ៦៩

[16] មាត្រា១៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[17] មាត្រា១៥៣ កថាខណ្ឌ៤ ផនៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[18] មាត្រា១៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[19] មាត្រា១៥៣ កថាខណ្ឌ២ ផនៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

- បងប្អូន ប្រុស ស្រីរបស់ជនត្រូវចោទ។
- បងប្អូន ថ្លៃប្រុស ស្រីរបស់ជនត្រូវចោទ។
- ប្តី ឬប្រពន្ធរបស់ជនត្រូវចោទ ទោះបីលែងលះគ្នាហើយក៏ដោយ។
- កុមារអាយុតិចជាង១៤ឆ្នាំ។[20]

**គ. ការសួរតទល់**

ការសួរតទល់គ្នាអាចឱ្យនិយមន័យបានថាជាការសួរចម្លើយ ឬ ការស្តាប់ចម្លើយបុគ្គលជាច្រើនព្រមគ្នាក្នុងគោលដៅ ធ្វើអោយលេចចេញនូវធាតុពិត តាមរយៈយោបល់ និងជំហររបស់បុគ្គលម្នាក់ៗដែល ចៅក្រមដាក់ឱ្យតទល់គ្នានោះ[21]។ នីតិវិធីនៃការសួរតទល់នេះមិនមានលក្ខណៈដែលខុសពី ការសួរចម្លើយជនត្រូវចោទ និងការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ពោលនីតិវិធីនេះ គឺត្រូវបានប្រព្រឹត្ត និងអនុវត្តទៅដូចការសួរចម្លើយជនត្រូវចោទ[22] និងការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែរ[23]។

**១.១.១.២. ការស្រាវជ្រាវទាក់ទងនឹងវត្ថុ**

ក្រៅពីការស្រាវជ្រាវទាក់ទងនឹងបុគ្គល ចៅក្រមស៊ើបសួរអាចធ្វើការស្រាវជ្រាវទាក់ទងនឹងវត្ថុបានផងដែរ ដើម្បីឱ្យដំណើរការនៃការស្វែងរកការពិតកាន់តែច្បាស់លាស់ និងពិតប្រាកដ។ ការស្រាវជ្រាវទាក់ទងនឹងវត្ថុនេះប្រព្រឹត្តទៅដោយផ្អែកទៅតាមផ្នែកសំខាន់ៗមួយចំនួនដូចជា៖ (ក) **ការឆែកឆេរ និងការចាប់យកវត្ថុតាង** (ខ) **ការធ្វើកោសលវិច័យ** និង (គ) **ការស្តាប់ទូរស័ព្ទ។**

**ក. ការឆែកឆេរ និងការចាប់យកវត្ថុតាង**

ការឆែកឆេរនេះគឺជា អំណាចរបស់ចៅក្រមស៊ើបសួរដើម្បីស្វែងរកតម្រុយ ឬភស្តុតាងដែលជាប់ពាក់ព័ន្ធជាមួយបទល្មើស នៅក្នុងកន្លែងឯកជន ដែលមានលក្ខណៈបិទបាំង។ ដោយឡែកការចាប់យកវត្ថុតាង គឺជាអំណាចរបស់ចៅក្រមស៊ើបសួរ ក្នុងការដកហូតដោយស្របច្បាប់ នូវវត្ថុទាំងឡាយណា ដែលជាភស្តុតាង ឬវត្ថុដែលជាប់ពាក់ព័ន្ធជាមួយនឹងបទល្មើស។ ចៅក្រមស៊ើបសួរអាចធ្វើការឆែកឆេរបាន ប្រសិនជាលោកយល់ឃើញថាចាំបាច់ និងមានប្រយោជន៍ដល់ការស៊ើបសួរ។ ការឆែកឆែកត្រូវធ្វើឡើងដោយគោរពទៅតាមការកំណត់របស់ច្បាប់។ នៅពេលឆែកឆេរចៅក្រមស៊ើបសួរត្រូវឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬ បើគ្មានអ្នកកាន់កាប់ទីកន្លែងទេត្រូវធ្វើនៅចំពោះមុខសាក្សី ២ (ពីរ) នាក់ដែលត្រូវបានចាត់តាំងដោយចៅក្រមស៊ើបសួរ។ ប៉ុន្តែសាក្សីដែលត្រូវបានចាត់តាំងនោះមិនអាចជានគរបាល ឬជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការ

[20] មាត្រា១៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[21] មេរៀននីតិវិធីព្រហ្មទណ្ឌ, រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០០៧, ទំព័រ ៧០

[22] មាត្រា១៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[23] មាត្រា១៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

ឆែកឆេរនោះឡើយ។ លើសពីនេះទៅទៀតចៅក្រមស៊ើបសួរ មិនអាចឆែកឆេរមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និង ក្រោយម៉ោង ១៨ (ដប់ប្រាំបី) បានទេ។ ករណីលើកលែង ចៅក្រមស៊ើបសួរអាចឆែកឆេរនៅពេលណាក៏បាន ចំពោះ ទីកន្លែងដែលបើកចំហដល់សាធារណៈ គ្រប់កន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ឬប្រើប្រាស់ គ្រឿងញៀន។[24]

ក្នុងករណីពិសេសដែលការឆែកឆេរត្រូវប្រព្រឹត្តទៅ នៅក្នុងការិយាល័យមេធាវី ការឆែកឆេរត្រូវធ្វើនៅ ចំពោះមុខប្រធានគណៈមេធាវី ឬ ប្រតិភូរបស់ប្រធានគណៈមេធាវីនោះ។ នៅរាល់ការឆែកឆេរត្រូវធ្វើកំណត់ហេតុ ស្តីពីការឆែកឆេរ ដែលកំណត់ហេតុនោះត្រូវមានចុះនិទ្ទេសអំពីអត្តសញ្ញាណរបស់ អ្នកកាន់កាប់ទីកន្លែង។ ហើយបើការឆែកឆេរប្រព្រឹត្តទៅនៅ ចំពោះមុខសាក្សី ២ (ពីរ) នាក់ កំណត់ហេតុត្រូវចុះនិទ្ទេស អំពីអត្ត សញ្ញាណរបស់សាក្សីនីមួយៗ។ ប៉ុន្តែប្រសិនជាការឆែកឆេរប្រព្រឹត្តទៅនៅចំពោះមុខ ប្រធានគណណៈមេធាវី ឬ ប្រតិភូនៃប្រធានគណៈមេធាវី កំណត់ហេតុត្រូវចុះនិទ្ទេសអំពីវត្តមានរបស់ប្រធានគណៈមេធាវី ឬ ប្រតិភូនៃប្រធាន គណៈមេធាវី។ បន្ទាប់ពីមានការចុះនិទ្ទេសនៅក្នុងកំណត់ហេតុរួចរាល់អស់ហើយ ចៅក្រមស៊ើបសួរ ក្រឡាបញ្ជី អ្នកកាន់កាប់ទីកន្លែង ឬ សាក្សី២(ពីរ)នាក់ ត្រូវចុះហត្ថលេខារបស់ខ្លួននៅលើកំណត់ហេតុនោះ។[25]

នៅក្នុងពេលឆែកឆេរ ប្រសិនជាចៅក្រមស៊ើបសួរបានស្វែងរកឃើញនូវវត្ថុតាងណាមួយ ចៅក្រមស៊ើប សួរក៏មានអំណាចក្នុងការចាប់យកវត្ថុតាងនោះបានដោយស្របច្បាប់ផងដែរ។ ប៉ុន្តែចៅក្រមស៊ើបសួរត្រូវតែបិទ ស្លាកបោះត្រាលើវត្ថុតាងនោះ ក្រោយពីបានបង្ហាញវត្ថុដែលចាប់ដល់អ្នកកាន់កាប់ទីកន្លែង ឬ ដល់សាក្សីទាំង២ (ពីរ) នាក់ រួចមក ចៅក្រមស៊ើបសួរធ្វើកំណត់ហេតុស្តីពីការចាប់យក ដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែល ចាប់យក។ កំណត់ហេតុត្រូវមានចុះនិទ្ទេសអំពីអត្តសញ្ញាណនៃអ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ។ មិនតែ ប៉ុណ្ណោះ នៅក្នុងកំណត់ហេតុស្តីពីការចាប់យកនេះ ត្រូវមានចុះហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី រួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬ សាក្សី ២ (ពីរ) នាក់។[26]

នៅពេលមិនទាន់ចេញដីកាដំណោះស្រាយរឿងនៅឡើយទេ ចៅក្រមស៊ើបសួរមានសម្ថកិច្ចប្រគល់សង ទៅម្ចាស់ដើមវិញ នូវវត្ថុដែលចាប់បាន កាលណាកម្មសិទ្ធិនេះគ្មានការជំទាស់អ្វីប្រាកដប្រជា។ប៉ុន្តែការប្រគល់វិញ មិនអាចធ្វើទៅបាននោះទេ កាលណាវិធានការនេះ អាចជាឧបសគ្គដល់ការសម្តែងការពិត ។ លើសពីនេះ វត្ថុ មួយចំនួនក៏ត្រូវបានច្បាប់កំណត់មិនអាចប្រគល់វិញផងដែរ កាលណាវត្ថុនោះជាវត្ថុដែលមានគ្រោះថ្នាក់ដល់

---

[25] មាត្រា១៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[26] មាត្រា១៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

បុគ្គល ឬ ទ្រព្យសម្បត្តិ ដូចជាអាវុធ ឬជាតិផ្ទុះ ព្រមទាំងវត្ថុដែលការកាន់កាប់មិនស្របច្បាប់ មិនអាចត្រូវប្រគល់សងទៅឱ្យសមីខ្លួនបានទេ។ វត្ថុទាំងនេះត្រូវរឹបអូសជាកម្មសិទ្ធិរបស់រដ្ឋ។[27]

**ខ. ការធ្វើកោសលវិច័យ**

ការធ្វើកោសលវិច័យគឺជា ការពិនិត្យ ធ្វើឡើងដោយអ្នកដែលមានជំនាញច្បាស់លាស់ និងត្រូវបានចាត់តាំង ដោយចៅក្រមស៊ើបសួរ ដើម្បីធ្វើការបំភ្លឺទៅលើបញ្ហាបច្ចេកទេសសុទ្ធសាធ ទៅលើវិស័យផ្សេងៗដូចជា វេជ្ជសាស្ត្រ ពេទ្យវិជ្ជា នីត្យានុកូល ជីវសាស្ត្រ ចិត្តវិជ្ជា អង្គុលីទស្សន៍ អង្គុលីលេខ ព័ត៌មានវិជ្ជា.ល។[28] នៅក្នុង ការអនុវត្តជាក់ស្តែងការបំភ្លឺលើបញ្ហាបច្ចេកទេសនោះអាចជា៖ ការពិនិត្យ សារធាតុញៀន ប្រភេទឈាម ប្រភេទអាវុធ សាកសពជាដើម ។ ដូច្នេះហើយ នៅពេលដែលមានបញ្ហាបច្ចេកទេសចោទឡើង ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យធ្វើកោសលវិច័យដោយឯកឯង ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញា តាមពាក្យសុំរបស់ជនត្រូវចោទ ឬតាមពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ប៉ុន្តែចៅក្រមស៊ើបសួរអាចបដិសេធពាក្យសុំធ្វើកោសលវិច័យនោះបានតាមរយៈ ដីកាដែលមានសំអាងហេតុ ដែលត្រូវចេញក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ប្រសិនពាក្យសុំចេញពីព្រះរាជអាជ្ញា និង ១ (មួយ) ខែ ប្រសិនបើពាក្យសុំនោះចេញពីជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។[29]

បុគ្គលដែលត្រូវបានចាត់តាំងជាអ្នកធ្វើកោសលវិច័យ ត្រូវបានហៅថា អ្នកជំនាញ ហើយចៅក្រមស៊ើបសួរតាមធម្មតាត្រូវជ្រើសរើសអ្នកជំនាញដែលត្រូវបានចុះ បញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ[30]។ ក្នុងករណីពិសេស ចៅក្រមស៊ើបសួរ អាចចាត់តាំងអ្នកជំនាញ ដែលគ្មានឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិបានតាមរយៈដីកាដោយមានសំអាងហេតុ ។ ក្នុងករណីនេះអ្នកជំនាញត្រូវស្បថតាមសាសនា ឬ ជំនឿរបស់ខ្លួនថា ខ្លួននឹងផ្តល់ជំនួយដោយស្មោះត្រង់ដល់ការស្វែងរកយុត្តិធម៌។[31]

អ្នកជំនាញទាំងអស់ត្រូវបានចាត់តាំងដោយចៅក្រមស៊ើបសួរតាមរយៈដីកា។ នៅក្នុងដីកាត្រូវបញ្ជាក់អំពីបេសកកម្មរបស់អ្នកជំនាញ ដែលទាក់ទិននឹងការពិនិត្យបញ្ហា ដែលមានលក្ខណៈបច្ចេកទេសតែប៉ុណ្ណោះ រួមទាំងចិរវេលាដែលត្រូវបំពេញបេសកកម្មនេះ។[32] ចិរវេលានេះអាចត្រូវបានពន្យាពេលបាន ដោយមានការអនុញ្ញាតពីសំណាក់ចៅក្រមស៊ើបសួរតាមរយៈដីកាសម្រេច ឬចាត់ឱ្យអ្នកជំនាញផ្សេងទៀតជំនួសអ្នកជំនាញនោះ។ អ្នក

---

[27] មាត្រា១៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[28] មេរៀននីតិវិធីព្រហ្មទណ្ឌ, រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ២០០៧, ទំព័រ ៧១

[29] មាត្រា១៦២ កថាខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[30] បញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ គឺជាបញ្ជីដែលត្រូវរៀបចំឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ហើយ អ្នកជំនាញដែលត្រូវបានចុះឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិត្រូវធ្វើស្បថនៅមុខសាលាឧទ្ធរណ៍ភ្នំពេញ ស្របតាមសាសនា ឬជំនឿរបស់ខ្លួនថា នឹងផ្តល់ជំនួយដោយស្មោះត្រង់ដល់ការស្វែងរកយុត្តិធម៌។

[31] មាត្រា១៦៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[32] មាត្រា១៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

ជំនាញបំពេញបេសកកម្មរបស់ខ្លួន ក្រោមការពិនិត្យរបស់ចៅក្រមស៊ើបសួរ ។ អ្នកជំនាញ ត្រូវជូនព័ត៌មាន ដល់ចៅក្រមស៊ើបសួរ អំពីការប្រព្រឹត្តទៅនៃបេសកកម្មរបស់ខ្លួនជាអាទិ៍ និងការលំបាក ដែលខ្លួនអាចជួបប្រទះ។ [33]

ចៅក្រមស៊ើបសួរអាចចាត់តាំងអ្នកជំនាញច្រើនរូបបាន ហើយប្រសិនអ្នកជំនាញមានយោបល់ផ្សេងៗគ្នា អ្នកជំនាញនីមួយៗត្រូវសរសេរ ប្រាប់អំពីយោបល់របស់ខ្លួនផ្ទាល់ ឬការមិនយល់ព្រមរបស់ខ្លួន។[34] អ្នកជំនាញអាចស្នើសុំការអនុញ្ញាតពីចៅក្រមស៊ើបសួរ ដើម្បីទទួលបាននូវសិទ្ធិក្នុងការស្តាប់ចម្លើយ ជនត្រូវចោទដោយមានវត្តមានមេធាវី លើកលែងតែការធ្វើកោសលវិច័យនោះ ជាការពិនិត្យវេជ្ជសាស្ត្រ ឬចិត្តសាស្ត្រ។ ប៉ុន្តែអ្នកជំនាញអាចស្តាប់គ្រប់ចម្លើយទាំងអស់ ពីបុគ្គលទាំងឡាយណាដែលមិនមែនជាជនត្រូវចោទ។[35]

នៅពេលដែលអ្នកជំនាញបានបញ្ចប់កោសលវិច័យ អ្នកជំនាញដែលត្រូវបានចាត់តាំងត្រូវប្រគល់ជូនចៅក្រមស៊ើបសួរ នូវរបាយការណ៍របស់ខ្លួន ដែលមានការពិពណ៌នាអំពីប្រតិបត្តិការរបស់ខ្លួន និងធ្វើសេចក្តីសន្និដ្ឋាន។[36] ក្រោយពីទទួលបានរបាយការណ៍ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងនេះទៅព្រះរាជអាជ្ញា និងធ្វើការកោះហៅ ជនត្រូវចោទ និង មេធាវីរបស់ជនត្រូវចោទ ដើម្បីប្រាប់ពួកគេឱ្យបានដឹងអំពីសេចក្តីសន្និដ្ឋាននៃរបាយការណ៍របស់អ្នកជំនាញ។ ចៅក្រមស៊ើបសួរក៏អាចកោះហៅដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីផងដែរ ដើម្បីប្រាប់ឱ្យដឹងពីសេចក្តីសន្និដ្ឋាននៃរបាយការណ៍ផងដែរ ។ នៅពេលដែលចៅក្រមស៊ើបសួរជូនដំណឹងរួចហើយ ចៅក្រមស៊ើបសួរទុកពេលវេលាយ៉ាងតិច១០ (ដប់) ថ្ងៃ ដល់ព្រះរាជអាជ្ញា និង ភាគីដើម្បីស្នើសុំឱ្យធ្វើកោសលវិច័យបន្ថែម ឬ ឱ្យធ្វើប្រតិកោសលវិច័យ ដែលត្រូវធ្វើជាលាយលក្ខអក្សរ និងមានមូលហេតុត្រឹមត្រូវ។ កាលណាចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំធ្វើ កោសលវិច័យបន្ថែម ឬ ប្រតិកោសលវិច័យទេ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដែលមានសំអាងហេតុ។ ដីកាត្រូវសម្រេច ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ប្រសិនបើពាក្យសុំចេញពី ព្រះរាជអាជ្ញា និង ១ (មួយ) ខែ ប្រសិនបើពាក្យសុំនេះធ្វើឡើងដោយជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី។ បើចៅក្រមស៊ើបសួរមិនបានសម្រេចនៅក្នុងថេរវេលានេះទេ អ្នកសុំអាចប្តឹងទៅសភាស៊ើបសួរដោយផ្ទាល់បាន។[37]

[33] មាត្រា១៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[34] មាត្រា១៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[35] មាត្រា១៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[36] មាត្រា១៦៨ វាក្យខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[37] មាត្រា១៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

**គ. ការស្តាប់ទូរស័ព្ទ**

ការស្តាប់ទូរស័ព្ទគឺជាវិធានការមួយដែលប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិរបស់បុគ្គលឯកជន ដែលសិទ្ធិនេះត្រូវបានការពារយ៉ាងជាក់លាក់នៅក្នុង រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។[38] ដូច្នេះហើយមានតែចៅក្រមស៊ើបសួរតែមួយប៉ុណ្ណោះដែលមានអំណាចក្នុងការបង្គាប់ឱ្យស្តាប់ទូរស័ព្ទ និងថតការសន្ទនាតាមទូរស័ព្ទបាន ព្រោះចៅក្រមស៊ើបសួរមានតួនាទីចាំបាច់ដើម្បីស្វែងរក និងសំដែងឱ្យឃើញនូវការពិត។ ចៅក្រមស៊ើបសួរក៏អាចបង្គាប់ឱ្យចាប់ និងថតគ្រប់ការឆ្លងឆ្លើយគ្នាតាមគ្រប់មធ្យោបាយទូរគមនាគមន៍ផងដែរ ដូចជា សារតាមទូរសារ ឬ សារតាមអិនធើណែត។ ក្រោយពេលបេសកម្មត្រូវបានបំពេញរួចហើយ អង្គភាពសាធារណៈ ឬ គ្រប់មន្ត្រីរាជការដែលត្រូវបានចាត់តាំងដោយចៅក្រមស៊ើបសួរ ត្រូវចម្លងជាលាយលក្ខណ៍អក្សរនូវសំលេងដែលថតបាន។[39]

## ១.២. អំណាចក្នុងការចេញដីកាចាត់ឱ្យស៊ើបសួរជំនួស

ការចាត់ឱ្យស៊ើបសួរជំនួសគឺជា អំណាចរបស់ចៅក្រមស៊ើសួរក្នុងការចេញដីកាចាត់ឱ្យស៊ើបសួរជំនួស ដើម្បីប្រគល់សិទ្ធិឱ្យទៅចៅក្រមនៃតុលាការរបស់ខ្លួន ឬ តុលាការផ្សេងទៀត មន្ត្រីនគរបាលយុត្តិធម៌ ឬ ដល់អង្គភាពនគរបាលយុត្តិធម៌ដើម្បីបំពេញកិច្ចស៊ើបសួរជំនួស។[40] មូលហេតុដែលនាំឱ្យមានការចេញដីកាចាត់ឱ្យស៊ើបសួរជំនួសមានដូចជា បញ្ហាជំងឺ ឬមានធុរៈចាំបាច់ផ្សេងៗ ឬ ការធ្វើដំណើរផ្លូវឆ្ងាយជាដើម។ ហេតុនេះដើម្បីជៀសវាងពីការយឺតយ៉ាវ និង ភាពបន្ទាន់នៃការស៊ើបសួរ ទើបក្រមនីតិវិធីព្រហ្មទណ្ឌ បើកផ្លូវឱ្យចៅក្រមស៊ើបសួរអាចចាត់ អ្នកបំពេញកិច្ចស៊ើបសួរជំនួសខ្លួនបាន។ ដើម្បីយល់កាន់តែច្បាស់អំពីការផ្ទេរសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរតាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស យើងនឹងសិក្សាទៅលើ (១.២.១) **អត្ថន័យនៃដីកាចាត់ឱ្យស៊ើបសួរជំនួស** (១.២.២) **ការស៊ើបសួរជំនួសដោយចៅក្រមស៊ើបសួរ** និង (១.២.៣) **ការស៊ើបសួរជំនួសដោយមន្ត្រីនគរបាលយុត្តិធម៌**។

### ១.២.១. អត្ថន័យនៃដីកាចាត់ឱ្យស៊ើបសួរជំនួស

តើអ្វីទៅគឺជាដីកាចាត់ឱ្យស៊ើបសួរជំនួស? ដីកាចាត់ឱ្យស៊ើបសួរជំនួសគឺជាដីកាដែលចេញដោយចៅក្រមស៊ើបសួរ ដើម្បីចាត់ឱ្យស៊ើបសួរជំនួស។ ដីកាចាត់ឱ្យស៊ើបសួរជំនួសនេះមិនអាចមានលក្ខណៈជាទូទៅនោះទេ ដោយចៅក្រមស៊ើបសួរត្រូវណែនាំឱ្យបានច្បាស់លាស់ អំពីថេរវេលានៃការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ត្រូវតែបញ្ជាក់អំពីប្រភេទនៃកិច្ចដែលត្រូវធ្វើ ហើយកិច្ចនោះត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលចោទប្រកាន់។ ដីកាដែលចាត់ឱ្យស៊ើបសួរជំនួសត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយ

[38] មាត្រា៤០ កថាខណ្ឌ២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានចែងថា ការរក្សាសិទ្ធិមិនឱ្យរំលោភលើលំនៅឋាន និងអាថ៌កំបាំងនៃការឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមន៍ និង តាមទូរស័ព្ទត្រូវបានធានា។

[39] មាត្រា១៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[40] មាត្រា១៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

ចៅក្រមស៊ើបសួរ និងមានបោះត្រាផងដែរ។ លើសពីនេះទៅទៀតចៅក្រមស៊ើបសួរលោកអាចដកហូតដីកាចាត់ឱ្យស៊ើបសួរជំនួសនៅពេលណាក៏បាន។[41]

**១.២.២ ការស៊ើបសួរជំនួសដោយចៅក្រមស៊ើបសួរ**

នៅពេលដែលចៅក្រមស៊ើបសួរចេញ ដីកាចាត់ឱ្យស៊ើបសួរជំនួសឱ្យចៅក្រមម្នាក់ទៀត ពេលនោះចៅក្រមរូបនោះអាចប្រើប្រាស់អំណាចទាំងអស់របស់ចៅក្រមស៊ើបសួរ។[42] ដូច្នេះមានន័យថាចៅក្រមស៊ើបសួរដែលទទួលបាននូវអំណាចស៊ើបសួរជំនួស អាចបំពេញកិច្ចផ្សេងៗដូចជា៖

- កិច្ចស្រាវជ្រាវទាក់ទងនឹងបុគ្គល៖ ការសួរចម្លើយជនត្រូវចោទ ការស្តាប់ចម្លើយ និង ការសួរតទល់
- ការស្រាវជ្រាវទាក់ទងនឹងវត្ថុ៖ ការឆែកឆេរ និងការចាប់យកវត្ថុតាង ការធ្វើកោសលវិច័យ និង ការស្តាប់ទូរស័ព្ទ។

**១.២.៣. ការស៊ើបសួរជំនួសដោយមន្ត្រីនគរបាលយុត្តិធម៌**

កាលណាដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវបានប្រគល់អំណាចឱ្យ មន្ត្រីនគរបាលយុត្តិធម៌ នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវបំពេញកិច្ចស៊ើបសួរដូចមានកំណត់នៅក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួសនោះ ដោយមិនអាចស៊ើបសួរលើសពីអ្វីដែលបានកំណត់នៅក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួសនោះទេ។ ក្នុងករណីមន្ត្រីនគរបាលយុត្តិធម៌ បើកការស៊ើបសួរ ទៅរកឃើញ នូវអង្គហេតុថ្មីណាមួយដែលអាចជាបទល្មើសព្រហ្មទណ្ឌ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនព័ត៌មានអំពីអង្គហេតុថ្មីនេះ ទៅចៅក្រមស៊ើបសួរ ដើម្បីឱ្យចៅក្រមស៊ើបសួរ ជូនដំណឹងទៅព្រះរាជអាជ្ញា ដែលព្រះរាជអាជ្ញាអាចចេញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។[43]

ដីកាចាត់ឱ្យស៊ើបសួរជំនួស ចំពោះមន្ត្រីនគរបាលយុត្តិធម៌ ត្រូវបានកំណត់សិទ្ធិមួយចំនួនដែលមន្ត្រីនគរបាលយុត្តិធម៌មិនអាចបំពេញបានគឺអំណាចក្នុងការសួរចម្លើយជនត្រូវចោទ ឬ ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី។[44]

នៅរាល់ការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ស្ថិតនៅក្រោម អំណាចរបស់ចៅក្រមស៊ើបសួរ និងត្រូវរាយការណ៍ជូនចំពោះតែចៅក្រមស៊ើបសួរតែប៉ុណ្ណោះ។ មន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់អំណាចរបស់ខ្លួនដែលទទួលបានតាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួសតាមរយៈ **(១.២.៣.១) ការស្តាប់ចម្លើយសាក្សី (១.២.៣.២) ការស្តាប់ទូរស័ព្ទ (១.២.៣.៣) ការធ្វើការឆែកឆេរ និងការចាប់យកវត្ថុតាង** និង **(១.២.៣.៤) ការឃាត់ខ្លួន**។[45]

---

[41] មាត្រា១៧៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[42] មាត្រា១៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[43] មាត្រា១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[44] មាត្រា១៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[45] មាត្រា១៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

### ១.២.៣.១. ការស្តាប់ចម្លើយសាក្សី

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការកោះហៅ និងស្តាប់ចម្លើយសាក្សីបាន។ ប៉ុន្តែមុនពេលស្តាប់ចម្លើយសាក្សីនោះត្រូវធ្វើសម្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថា និយាយតែការពិត លើកលែងតែបុគ្គលដែលមានរៀបរាប់នៅក្នុង មាត្រា ១៥៦ (សាក្សីដែលអនុញ្ញាតឱ្យរួចពីសម្បថ) ដែលត្រូវបានច្បាប់អនុញ្ញាតរួចផុតពីការធ្វើសម្បថមុនពេលឆ្លើយ។ នៅក្នុងពេលស្តាប់ចម្លើយសាក្សីណាម្នាក់ ប្រសិនជាការស្តាប់នោះលេចចេញនូវតម្រុយណាមួយដែលជាតម្រុយពិរុទ្ធភាពលើសាក្សីនោះ ការស្តាប់ចម្លើយត្រូវតែបញ្ចប់ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែរាយការណ៍ភ្លាមទៅកាន់ចៅក្រមស៊ើបសួរ ។ មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែដែលត្រូវបានស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថា ខ្លួននឹងជួយបកប្រែជូនតុលាការឱ្យ បានត្រឹមត្រូវ ។ លើសពីនេះរាល់បុគ្គលដែលត្រូវបានកោះហៅក្នុងឋានៈជាសាក្សី ត្រូវតែចូលបង្ហាញខ្លួន ។ ក្នុងករណីរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌អាចរាយការណ៍ជូនចៅក្រមស៊ើបសួរ ក្នុងករណីនេះចៅក្រមស៊ើបសួរអាចចេញ បញ្ជាឱ្យចូលខ្លួន ដោយមាន ចុះអត្តសញ្ញាណនៃសាក្សី ។ បញ្ជាឱ្យចូលខ្លួននេះត្រូវមានចុះកាលបរិច្ឆេទ និងហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង ។ នៅពេលដែលមានបញ្ជាឱ្យ ចូលបង្ហាញខ្លួន បញ្ជានេះអាចអនុញ្ញាតឱ្យ មន្ត្រីនគរបាលយុត្តិធម៌ ប្រើប្រាស់កម្លាំងសាធារណៈ ដើម្បីបង្ខំឱ្យ សាក្សីចូលបង្ហាញខ្លួនចំពោះមុខខ្លួនបាន ។[46] មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ ការពិនិត្យរបស់ខ្លួន[47] និងការស្តាប់ចម្លើយ[48]។

### ១.២.៣.២. ការស្តាប់ទូរស័ព្ទ

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស្តាប់ និងថតការសន្ទនាតាមទូរស័ព្ទ ឬ ការចាប់ និងការថតគ្រប់ការឆ្លើយឆ្លងតាមមធ្យោបាយទូរគមនាគមន៍ដូចជា សារតាមទូរស័ព្ទ ឬ សារតាមអិនធើណែត បានផងដែរ កាលណាកិច្ចនេះត្រូវបានចែងនៅក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួស។[49] កាលណាស្តាប់រួចរាល់ហើយ មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលការតែងតាំងតាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួសនោះត្រូវធ្វើការចម្លងសម្លេងដែលថតបាននោះ ទៅជាលាយលក្ខណ៍អក្សរ ដោយត្រូវសរសេរឱ្យបានត្រឹមត្រូវទៅតាមខ្លឹមសារទាំងស្រុងនៃសម្លេងដែលថតបាននោះឱ្យទៅចៅក្រមស៊ើបសួរ ។

### ១.២.៣.៣. ការធ្វើការឆែកឆេរ និងការចាប់យកវត្ថុតាង

មន្ត្រីនគរបាលយុត្តិធម៌ទទួលបាននូវសិទ្ធិអំណាចក្នុងការឆែកឆេរ និងចាប់យកវត្ថុតាង បានតាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស ។ ក្នុងករណីដែលមានការឆែកឆេរត្រូវប្រព្រឹត្តទៅ មន្ត្រីនគរបាលយុត្តិធម៌ត្រូវទទួល

---

[46] មាត្រា១៧៩ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[47] មាត្រា១៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[48] មាត្រា៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[49] មាត្រា១៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

ជាបឋមនូវការអនុញ្ញាតពីសំណាក់ចៅក្រមស៊ើបសួរ ។ ការឆែកឆេរត្រូវធ្វើឡើងនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬ បើគ្មានអ្នកកាន់កាប់ទីកន្លែងទេត្រូវធ្វើនៅចំពោះមុខ សាក្សី ២ (ពីរ) នាក់ដែលត្រូវបានចាត់តាំងដោយ មន្ត្រីនគរបាលយុត្តិធម៌។ សាក្សីដែលត្រូវបានចាត់តាំងនោះមិនអាចជានគរបាល ឬ ក៏ជាកងរាជអាវុធហត្ថដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ។ លើសពីនេះទៅទៀត ការឆែកឆេរមិនអាចប្រព្រឹត្តិទៅនៅមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និង ក្រោយម៉ោង ១៨ (ដប់ប្រាំបី) ឡើយ លើកលែងតែករណីពិសេសដែលមានកំណត់ដោយច្បាប់ប៉ុណ្ណោះ។[50] មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើកំណត់ហេតុស្តីពីការឆែកឆេរដែលមានចុះ៖

- ការអនុញ្ញាតរបស់ចៅក្រមស៊ើបសួរ ដោយប្រាប់ថ្ងៃ និងម៉ោងនៃការអនុញ្ញាតនេះ
- អត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ ។[51]

លើសពីនេះទៅទៀតនោះ មន្ត្រីនគរបាលយុត្តិធម៌ក៏អាចធ្វើការចាប់យកវត្ថុតាងបានផងដែរ ហើយត្រូវបិទស្លាកបោះត្រានៅលើវត្ថុតាងនោះ។ ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការបញ្ហាញវត្ថុតាងដែលចាប់នោះ ដល់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់មើលរួច និងធ្វើកំណត់ហេតុស្តីពីការចាប់យកដោយមានហត្ថលេខា ឬផ្តិតស្នាមម្រាមដៃដោយអ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់។[52]

### ១.២.៣.៤. ការឃាត់ខ្លួន

តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ទទួលបាននូវសិទ្ធិអំណាចក្នុងការឃាត់ខ្លួនជនត្រូវចោទ។ ជាក់ស្តែង នៅក្នុងអំឡុងពេលចុះប្រតិបត្តិការស៊ើបសួរ តាមដីកាចាត់ឱ្យស៊ើបសួរជំនួសរបស់ចៅក្រមស៊ើបសួរ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឃាត់ខ្លួនបុគ្គល ដែលខ្លួនសង្ស័យថាបានចូលរួមប្រព្រឹត្ត បទល្មើស។ លើសពីនេះទៅទៀត មន្ត្រីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួន បុគ្គលដែលខ្លួនយល់ឃើញថា អាចផ្តល់ព័ត៌មានទាំងឡាយ ដែលមានជាប់ពាក់ព័ន្ធនឹង រឿងហេតុដែលបានកើតឡើងបានផងដែរ ក្នុងករណីដែលលក្ខខណ្ឌខាងក្រោមត្រូវបានបំពេញ៖

- បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន
- មានការយល់ព្រមជាលាយលក្ខណ៍អក្សរឱ្យធ្វើការឃាត់ខ្លួនពីចៅក្រមស៊ើបសួរ។[53]

---

[50] មាត្រា១៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[51] មាត្រា៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[52] មាត្រា៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[53] មាត្រា៩៦ កថាខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

ការណ៍ដែលសំខាន់ នៅរាល់ពេលដែលមន្ត្រីនគរបាលយុត្តិធម៌ធ្វើការឃាត់ខ្លួនបុគ្គលណាម្នាក់ មន្ត្រីនគរបាល យុត្តិធម៌ត្រូវតែធ្វើនូវកិច្ចសំខាន់ចំនួន៣ទាក់ទងនឹងកំណត់ហេតុ ដែលមានដូចជា ការធ្វើកំណត់ហេតុស្តីពីការឃាត់ខ្លួន ការចុះការឃាត់ខ្លួនក្នុងបញ្ជីនៃការឃាត់ខ្លួន និងការធ្វើកំណត់ហេតុសរុបនៃការឃាត់ខ្លួន។ កិច្ចទាំងអស់នេះត្រូវបំពេញទៅតាមដំណាក់កាលនីមួយៗ ដែលមានន័យថានៅរាល់ពេលមន្ត្រីនគរបាលយុត្តិធម៌ធ្វើការឃាត់ខ្លួនបុគ្គលណាម្នាក់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើ កំណត់ហេតុស្តីពីការឃាត់ខ្លួនបុគ្គលនោះ។[54] ទន្ទឹមនឹងគ្នានោះ គ្រប់ការឃាត់ខ្លួនក៏ត្រូវ ធ្វើការចុះនៅក្នុង បញ្ជីស្តីពីការឃាត់ខ្លួនផងដែរ ដើម្បីទទួលជនដែលត្រូវឃាត់ខ្លួន ដោយត្រូវមានបញ្ជីស្តីពីការឃាត់ខ្លួនមួយ ដើម្បីរក្សាទុកសម្រាប់ជូនទៅអាជ្ញាធរតុលាការ ក្នុងករណីដែលត្រូវការ។[55] ជាមួយគ្នានោះដែរ មន្ត្រីនគរបាលយុត្តិធម៌ក៏ត្រូវធ្វើកំណត់ហេតុសរុបស្តីពីការឃាត់ខ្លួនផងដែរ ដើម្បីភ្ជាប់ជាមួយនឹងសំណុំរឿង។[56]

[54] មាត្រា៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[55] មាត្រា១០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[56] មាត្រា១០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

# ជំពូកទី២
# អំណាចរបស់ចៅក្រមស៊ើបសួរមុនពេលឃុំខ្លួនជនត្រូវចោទ

នៅក្នុងជំពូកនេះយើងនឹងធ្វើការសិក្សាទៅលើ (២.១) **អំណាចនៅក្នុងការប្រើប្រាស់វិធានការនិរន្តរាយ** និង (២.២) **អំណាចនៅក្នុងការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។**

## ២.១ អំណាចនៅក្នុងការប្រើប្រាស់វិធានការនិរន្តរាយ

### ២.១.១. ដីកាបង្គាប់ឲ្យចូលខ្លួន

#### ២.១.១.១ គោលបំណង

ចៅក្រមស៊ើបសួរនៅពេលដែលគាត់ចាប់ផ្តើម បើកការស៊ើបសួរដើម្បីធ្វើការស្រាវជ្រាវអំពី អត្ថិភាពឬនត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌ បើទោះបីជាការស្រាវជ្រាវនោះនាំឲ្យមានការដោះបន្ទុក ឬដាក់បន្ទុកទៅលើជនត្រូវចោទក៏ដោយ។[57] តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា[58] ចៅក្រមស៊ើបសួរត្រូវបានច្បាប់ផ្តល់អំណាចឲ្យគាត់យ៉ាងធំធេងនៅក្នុងការប្រើប្រាស់វិធានការនិរន្តរាយដែលកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា[59] ។

គោលបំណងដ៏សំខាន់នៅក្នុងការចេញដីកានេះគឺ ដើម្បីធ្វើការបង្គាប់ទៅដល់បុគ្គលជាជនត្រូវចោទដែលត្រូវបានព្រះរាជអាជ្ញាធ្វើការចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ឬក៏ជាការបង្គាប់ឲ្យបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាពក្នុងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ[60] ឲ្យចូលមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរដែលបានចេញដីកានោះផ្ទាល់ ដើម្បីធ្វើការសាកសួរពីដំណើររឿងនៃការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌទៅតាមកាលបរិច្ឆេទ និងពេលវេលាដូចដែលមានកំណត់នៅក្នុងដីកាបង្គាប់ឲ្យចូលខ្លួននោះ ។ ចំពោះដីកានេះ បើមើលពីចរិតលក្ខណៈរបស់វា ពុំមានលក្ខណៈដាច់ខាតនិងចាប់បង្ខំឲ្យជនត្រូវចោទដែលជាកម្មវត្ថុនៃការចេញដីកានេះចាំបាច់ត្រូវតែចូលខ្លួនមកចំពោះមុខចៅក្រមស៊ើបសួរនោះទេ ព្រោះនៅក្នុងការអនុវត្តជាក់ស្តែង ជនត្រូវចោទមិនបានចូលមកបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរទៅតាមកាលបរិច្ឆេទនិងពេលវេលាកំណត់នៅក្នុងដីកានេះនោះទេ ។ នៅក្នុងសំណុំរឿងព្រហ្មទណ្ឌខ្លះ ដីកានេះអាចចេញដោយចៅក្រមស៊ើបសួរចំពោះជនត្រូវចោទដែលជាកម្មវត្ថុនៃដីកានេះ ចំនួនពីរ ឬបីលើកបាន នៅក្នុងករណីដែលជនត្រូវចោទនោះមាន

---

[57] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា១២៧ ចៅក្រមស៊ើបសួរមានករណីកិច្ចស៊ើបសួរទាំងដាក់បន្ទុកនិងដោះបន្ទុកដើម្បីបង្ហាញអោយឃើញការពិតនូវអត្ថិភាពឬនត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌ។

[58] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា១២៤ ការស៊ើបសួរត្រូវបានបើកតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។

[59] ជំពូកទី៣ ផ្នែកទី១ ដីកាដែលចេញដោយចៅក្រមស៊ើបសួរ

[60] មាត្រា១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

ចេតនាគេចវេសមិនចូលមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ពេលនោះចៅក្រមស៊ើបសួរនឹងប្រើវិធានការមួយផ្សេងទៀតដែលមានចរិកលក្ខណៈដាច់ខាត និងចាប់បង្ខំឲ្យជនត្រូវចោទត្រូវគោរពតាម គឺដីកាបង្គាប់ឲ្យនាំខ្លួន ។

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យចូលខ្លួនគឺដើម្បី:

- បញ្ជាបុគ្គលណាម្នាក់ឲ្យចូលទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ[61]
- ចេញទៅលើជនត្រូវចោទ ឬ បុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព[62]
- ធ្វើការសួរចម្លើយជនត្រូវចោទ ។[63]

### ២.១.១.២. និទ្ទេសដែលត្រូវចុះនៅលើដីកាបង្គាប់ឲ្យចូលខ្លួន

ការចេញដីកាបង្គាប់ឲ្យចូលខ្លួន ត្រូវតែមាននិទ្ទេសកំណត់ដូចតទៅ៖

- អត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនោះ
- ថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែងដែលត្រូវបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ
- ឈ្មោះ និងឋានៈរបស់ចៅក្រមស៊ើបសួរដែលបានចេញដីកានេះ ។

ដីកាបង្គាប់ឲ្យចូលខ្លួនត្រូវតែមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។ [64]

### ២.១.១.៣. ការជូនដំណឹងអំពីដីកាបង្គាប់ឲ្យចូលខ្លួន

ដីកាបង្គាប់ឲ្យចូលខ្លួនអាចជូនដំណឹងទៅជនត្រូវចោទដោយ៖

- មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬ ដោយអាជ្ញាសាលា
- បុគ្គលដែលពាក់ព័ន្ធទទួលចុងដីកា ហើយត្រូវចុះហត្ថលេខានៅលើដើមដីកា ដែលត្រូវបង្វិលជូនទៅចៅក្រមស៊ើបសួរវិញ
- មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬ អាជ្ញាសាលាត្រូវតែជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីគ្រប់ការលំបាកនៅក្នុងការអនុវត្តបេសកកម្មរបស់ខ្លួន។[65]

---

[61] មាត្រា១៨៦ កថាខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[62] មាត្រា៩៧ កថាខណ្ឌ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[63] មាត្រា១៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[64] មាត្រា១៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[65] មាត្រា១៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

## ២.១.២. ដីកាបង្គាប់ឲ្យនាំខ្លួន

### ២.១.២.១. គោលបំណង

ដីកាបង្គាប់ឲ្យនាំខ្លួន គឺជាប្រភេទដីកាមួយនៃវិធានការនិរន្តរាយដែលច្បាប់បានផ្តល់សិទ្ធិអំណាចទៅឲ្យចៅក្រមស៊ើបសួរក្នុងការចេញដីកាបង្គាប់ឲ្យនាំខ្លួន[66] ក្នុងករណីដែលជនត្រូវចោទ ឬ បុគ្គលដែលមានតម្រុយពិរុទ្ធភាពមានចេតនារឹងរូស មិនចូលខ្លួនតាមដីកាបង្គាប់ឲ្យចូលខ្លួនរបស់ចៅក្រមស៊ើបសួរ បើទោះបីជាចៅក្រមស៊ើបសួរចេញដីកានេះជាច្រើនលើកក៏ដោយ។ ការនាំខ្លួនគឺជាវិធានការមួយដែលមានលក្ខណៈសំខាន់ ក្នុងការធានាដល់ការស៊ើបសួរ និងស្វែងរកការពិតនៅក្នុង នីតិវិធីរឿងក្តីព្រហ្មទណ្ឌ តាមរយៈការចេញលិខិតមួយហៅថា ដីកាកោះ ដែលកម្មវត្ថុនៃការចេញដីកានេះអាចចេញចំពោះ ជនសង្ស័យ ជនត្រូវចោទ សាក្សីដាក់បន្ទុក និងសាក្សីដោះបន្ទុកជាដើម ដើម្បីធានាផលប្រយោជន៍ក្នុងការស៊ើបអង្កេតស្វែងរកពិរុទ្ធភាពរបស់ជនល្មើស ។ មួយវិញទៀត ចៅក្រមស៊ើបសួរក៏អាចចេញដីកាបង្គាប់ឲ្យនាំខ្លួនជនត្រូវចោទ ឬបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាពភ្លាមផងដែរ ដោយមិនចាំបាច់ចេញដីកាបង្គាប់ឲ្យចូលខ្លួនជាមុននោះទេ នៅក្នុងករណីដែលចៅក្រមស៊ើបសួរយល់ឃើញថាជាការចាំបាច់ ។[67]

ការចេញដីកាបង្គាប់ឲ្យនាំខ្លួនដោយចៅក្រមស៊ើបសួរគឺ៖

- បញ្ជាដល់កងកម្លាំងសាធារណៈ ឲ្យចាប់ និងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ ។[68]
- អាចចេញទៅលើជនត្រូវចោទ ឬ ទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព ។[69]
- ត្រូវតែមានការចុះនិទ្ទេសលើដីកាបង្គាប់ឲ្យនាំខ្លួន ដូចមានចែងក្នុងមាត្រា១៩១ ។
- ចេញនៅក្នុងករណីមិនចូលខ្លួនតាមដីកាបង្គាប់ឲ្យចូលខ្លួន ឬ ក្នុងករណីចាំបាច់ផ្សេងទៀត ។[70]

### ២.១.២.២. និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឲ្យនាំខ្លួន

ដើម្បីធានាឲ្យការនាំខ្លួនប្រព្រឹត្តទៅដោយសុវត្ថិភាព ជាពិសេសជៀសវាងនូវ ការរំលោភបំពាននូវសិទ្ធិសេរីភាព និងប៉ះពាល់សណ្តាប់ធ្នាប់នៅក្នុងដំណើរការនីតិវិធី ដីកាបង្គាប់ឲ្យនាំខ្លួន ត្រូវមាននិទ្ទេសដែលកំណត់ដូចតទៅ ៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលបានកំណត់ និងបង្ក្រាបបទល្មើសនោះ

---

[66] មាត្រា១៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[67] នីតិវិធីព្រហ្មទណ្ឌ លោកសាស្ត្រាចារ្យ នុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត,២០១៣-២០១៤, ទំព័រ ៣៦

[68] មាត្រា១៩០ កថាខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[69] មាត្រា១៨៧ កថាខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[70] សាស្ត្រាចារ្យ គុប ឈុនហេង សៀវភៅមេរៀនស្តីពីប្រភេទដីកា និងគំរូដីកាក្នុងរឿងព្រហ្មទណ្ឌ ឆ្នាំ២០១៤ ទំព័រ ១១

• ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា ។

ដីកាបង្គាប់ឲ្យនាំខ្លួន ត្រូវតែមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង ។[71]

### ២.១.២.៣. ការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន

ការអនុវត្តបង្គាប់ឲ្យនាំខ្លួន ត្រូវប្រគល់ដោយមន្ត្រីនគរបាលយុត្តិធម៌ ។[72]

• នៅក្នុងករណីបន្ទាន់ ដីកាបង្គាប់ឲ្យនាំខ្លួន ត្រូវផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ ។

• ដើមដីកានេះ ត្រូវតែប្រគល់ជូនជាបន្ទាន់ដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួននេះ។

• មន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធ មុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានទេ។

• មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ ចៅក្រមស៊ើបសួរអំពីការលំបាកនៅក្នុង ការអនុវត្តបេសកកម្មរបស់ខ្លួន ។[73]

## ២.១.៣. ដីកាបង្គាប់ឲ្យចាប់ខ្លួន

### ២.១.៣.១. គោលបំណង

ដីកាបង្គាប់ឲ្យចាប់ខ្លួនគឺជាដីកាមួយប្រភេទ ដែលចេញដោយចៅក្រមស៊ើបសួរ មានលក្ខណៈជាការបញ្ជាទៅឲ្យកងកម្លាំងសាធារណៈ ក្នុងការស្វែងរកចាប់ខ្លួនជនដែលជាកម្មវត្ថុនៃ ការចេញដីកាបង្គាប់ឲ្យចាប់ខ្លួននៅពេលដែលជនល្មើសប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌរួច ហើយព្យាយាមរត់គេចខ្លួន។ ដោយហេតុថា ជននោះបាន គេចខ្លួនបាត់ និងមិនបានចូលខ្លួនមកចំពោះមុខ ចៅក្រមស៊ើបសួរក្រោយពីត្រូវបានចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទៅចៅក្រមស៊ើបសួរ។ ដីកាបង្គាប់ឲ្យចាប់ខ្លួនគឺអាចចេញតែទៅលើ ជនត្រូវចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធភាពតែប៉ុណ្ណោះ[74] ហើយបុគ្គលនោះទៀតសោធន៍បានរត់គេចខ្លួនដោយមានសាវតាជាតិ[75]គ្រប់គ្រាន់ទៀត ។ កម្មវត្ថុនៃការចេញដីកាបង្គាប់ឲ្យចាប់ខ្លួនគឺ មិនអាចអនុវត្ត

---

[71] មាត្រា១៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[72] មាត្រា១៩២ កថាខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[73] មាត្រា១៩២ កថាខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[74] មាត្រា១៩៦ កថាខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[75] សាវតាជាតិ គឺជាទិន្នន័យដែលនាំទៅដល់ការបង្ហាញឱ្យច្បាស់លាស់ពីអត្តសញ្ញាណរបស់បុគ្គលណាមួយ ដោយចែកដាច់រវាងបុគ្គលម្នាក់ ទៅបុគ្គលម្នាក់ទៀត។

ទៅលើសាក្សីណាមួយដែល ចៅក្រមស៊ើបសួរបានចេញដីកាកោះឲ្យចូលខ្លួនមកចំពោះមុខ ចៅក្រមស៊ើបសួរ ដើម្បីសាកសួរ និងបំភ្លឺការពិតពីដំណើររឿងនៃ ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនោះទេ ទោះបីជាជននោះមិនបាន ចូលខ្លួន ឬ រឹងទទឹងដោយចេតនាក្នុងការចូលខ្លួនមកចំពោះមុខចៅក្រមស៊ើបសួរក៏ដោយ។ ច្បាប់ក៏មិនបានផ្តល់ អំណាចដល់ចៅក្រមស៊ើបសួរឲ្យចេញដីកាបង្គាប់ឲ្យចាប់ខ្លួនសាក្សីដែលរឹងទទឹងមិនចូលខ្លួននោះដែរ ។

ចំពោះសាលក្រមកំបាំងមុខជនជាប់ចោទ ដែលចៅក្រមជំនុំជម្រះបានបើកសវនាការ ហើយសាលក្រម នោះបានសម្រេចផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារកំណត់យ៉ាងតិចចំនួន ១ (មួយ) ឆ្នាំ ក្រោយមកសាល ក្រមកំបាំងមុខនោះបានចូលជាស្ថាពរ ចៅក្រមជំនុំជម្រះមានសិទ្ធិនៅក្នុងការចេញដីកាបង្គាប់ឲ្យចាប់ខ្លួនទណ្ឌិត នោះទៅដាក់ពន្ធនាគារតាមអំណាចនៃសាលក្រមដែលចូលជាស្ថាពរនោះ ។[76] ចំពោះករណីមួយទៀត ដីកា បង្គាប់ឲ្យចាប់ខ្លួនក៏អាចចេញដោយព្រះរាជអាជ្ញាបានផងដែរ នៅពេលដែលទណ្ឌិតកំពុងអនុវត្តទោសនៅក្នុង ពន្ធនាគារ បានរត់គេចខ្លួនចេញពីពន្ធនាគារ[77]។ ហេតុនេះដីកាបង្គាប់ឲ្យចាប់ខ្លួនជា ការដាក់បញ្ជាអោយមន្ត្រី នគរបាលយុត្តិធម៌ស្វែងរកចាប់ខ្លួនទណ្ឌិតដែលរត់គេចចេញនោះ មកអនុវត្តទោសនៅក្នុងពន្ធនាគារឡើងវិញ ។

ចៅក្រមស៊ើបសួរដែលបានចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជនត្រូវចោទដែលរត់គេចខ្លួន នៅក្នុងការអនុវត្ត ដីកាបង្គាប់ឲ្យចាប់ខ្លួនគឺផ្តល់សិទ្ធិអំណាចទៅឲ្យមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីធ្វើការចុះចាប់ជនត្រូវចោទដែលជា កម្មវត្ថុនៃដីកាដែលចេញដោយចៅក្រមស៊ើបសួរ ។ មួយវិញទៀត ទោះបីជាមានការលំបាកនៅក្នុងការអនុវត្តដីកា នេះមានភាពលំបាក ស្មុគស្មាញយ៉ាងណាក៏ដោយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែរ៉ាប់រងនូវការអនុវត្តនេះឲ្យមាន ប្រសិទ្ធភាព ដើម្បីការពារផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងទប់ស្កាត់នូវការបង្កឲ្យមានការប៉ះពាល់ ទៅដល់នីត្យានុកូលភាពសង្គម ។ ផ្ទុយទៅវិញ មន្ត្រីនគរបាលនៅពេលទទួលបានដីកាបង្គាប់ឲ្យចាប់ខ្លួន គឺគាត់ មិនយកដីកានេះទៅអនុវត្តចាប់ខ្លួនជនត្រូវចោទភ្លាមនោះទេ ពេលខ្លះមន្ត្រីនគរបាលយុត្តិធម៌បានយកដីកានេះ ទៅជូនជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីសុំសោហ៊ុយខ្លះៗក្នុងការចុះទៅចាប់ជនត្រូវចោទដែលជាកម្ម វត្ថុនៃការចេញដីកា។ ប្រសិនជាគាត់បានសោហ៊ុយខ្លះនោះគាត់នឹងអនុវត្ត ដីកាបង្គាប់ឲ្យចាប់ខ្លួន និងបញ្ជូនទៅ តុលាការភ្លាម ហើយបើគាត់មិនទទួលបានសោហ៊ុយខ្លះនោះទេ គាត់មុខជាមិនចាប់តាមដីកានោះ ឬ ពន្យាការ អនុវត្តដីកានេះដោយមិនសមស្រប ព្រោះគាត់យល់ថាគាត់ជាអ្នកចាប់ បើគាត់មិនចាប់ឲ្យតុលាការ តុលាការ គ្មានសិទ្ធិធ្វើអ្វីលើសពីនេះទៀតទេ។ ហេតុនេះ នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌មិនអនុវត្តដីកានេះភ្លាមៗ នោះទេ ដោយទុកឲ្យមានរយៈពេលយូរទៅៗ ពេលនោះចៅក្រមស៊ើបសួរមិនអាចបង្អង់ទុកសំណុំរឿងឲ្យនៅយូរ បាននោះទេ គឺចៅក្រមស៊ើបសួរនឹងធ្វើការបញ្ជូនសំណុំរឿងពិនិត្យមូល ដោយជូនដំណឹងអំពីការបិទការស៊ើបសួរ

[76] មាត្រា៣៥៣ កថាខ័ណ្ឌទី១ វាក្យខ័ណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[77] មាត្រា៥១១ កថាខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

ដល់ព្រះរាជអាជ្ញា[78] តាមរយៈលិខិតមួយហៅថា លិខិតជូនដំណឹងអំពីការបិទការស៊ើបសួរ ដើម្បីអោយព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានជាស្ថាពរ រួចបញ្ជូនមកអោយចៅក្រមស៊ើបសួរវិញ ហើយចៅក្រមស៊ើបសួរនឹងបញ្ជូនរឿងទៅជំនុំជម្រះ ។ នៅពេលដែលសំណុំរឿងមកដល់ដៃចៅក្រមជំនុំជម្រះ ហើយចៅក្រមជំនុំជម្រះ បានបើកសវនាការសួរដេញដោលហើយ និងបានចេញសាលក្រមលើកលែងការចោទប្រកាន់ដល់ជនជាប់ចោទ ដោយសាលក្រមនោះមានអានុភាពបញ្ឈប់ការចាប់ខ្លួនជនជាប់ចោទ ហើយចៅក្រមបានបញ្ជូនដីកាបញ្ឈប់ការចាប់ខ្លួនជនជាប់ចោទ ដល់ពេលនោះមន្ត្រីនគរបាលយុត្តិធម៌ទើបតែទៅចាប់ខ្លួនជនជាប់ចោទត្រូវចោទតាមដីកាបង្គាប់ឲ្យចាប់ខ្លួនរបស់ចៅក្រមស៊ើបសួរ ជាលទ្ធផលជនជាប់ចោទនោះមានដីកាបញ្ឈប់ឲ្យចាប់ខ្លួនទៅវិញ ដែលធ្វើអោយមានភាពមិនប្រក្រតី និង មិនស៊ីសង្វាក់គ្នានៅក្នុងការអនុវត្តដីការបស់តុលាការចំពោះមន្ត្រីនគរបាលយុត្តិធម៌ ។[79]

ការចាប់ខ្លួនជនត្រូវចោទ គឺជាសិទ្ធិអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ ចៅក្រមស៊ើបសួរ នៅក្នុងការអនុវត្តនូវវិធានការចាប់ខ្លួន ទៅលើជនត្រូវចោទដើម្បីធ្វើយ៉ាងណាអោយជនត្រូវចោទមកបង្ហាញខ្លួននៅចំពោះមុខនគរបាល ចៅក្រម ឬ ព្រះរាជអាជ្ញាហើយក៏ជាវិធានការមួយដ៏សំខាន់ដើម្បីបង្ការ ទប់ស្កាត់ និងរារាំងមិនអោយជនត្រូវចោទ មានការរំខាន ឬ បង្កជាឧបសគ្គអ្វីមួយ ដល់ដំណើរការស៊ើបអង្កេត ព្រមទាំងធានាដល់ការជំនុំជម្រះក៏ដូចជាអនុវត្តសាលក្រមផលដែរ ។ សិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរ គឺជាសិទ្ធិអំណាចមួយដែលដកហូតនូវសិទ្ធិសេរីភាពរបស់ជនត្រូវចោទជាបណ្ដោះអាសន្ន ហេតុដូច្នេះការអនុវត្តនូវសិទ្ធិអំណាចនេះត្រូវតែអនុវត្តអោយបានត្រឹមត្រូវទៅតាមផ្លូវច្បាប់ ព្រោះច្បាប់ក៏បានចាត់ទុកថា ជាបទល្មើសធ្ងន់ធ្ងរនៅក្នុងករណីដែលនីតិវិធីនៃការចាប់ខ្លួនធ្វើឡើងដោយមិនស្របទៅតាមច្បាប់ ហើយច្បាប់តម្រូវអោយមានការទទួលខុសត្រូវ ឬ ដាក់ទណ្ឌកម្ម ចំពោះការរំលោភបំពាននីតិវិធីនៃការចាប់ខ្លួនជនត្រូវចោទ[80] ។ ដោយសារតែជាគោលការណ៍ច្បាប់រ៉ាប់រងធានានូវរាល់ ការឃាត់ខ្លួន ការចាប់ខ្លួន ការឃុំខ្លួន អាចនឹងធ្វើទៅបាន លុះត្រាតែធ្វើឡើងដោយត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។[81]

ការចេញដីកាបង្គាប់ឲ្យចាប់ខ្លួនដោយចៅក្រមស៊ើបសួរៈ

- អាចចេញទៅលើជនត្រូវចោទ ឬ បុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព ។[82]

---

[78] មាត្រា២៤៧ កថាខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[79] ហាម ម៉េងសែ សមត្ថកិច្ចចៅក្រមស៊ើបអង្កេត ឆ្នាំ២០០៤ ទំព័រ ៣៩

[80] ហាម ម៉េងសែ សមត្ថកិច្ចចៅក្រមស៊ើបអង្កេត ឆ្នាំ២០០៤ ទំព័រ ៣២

[81] មាត្រា៣៨ កថាខ័ណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣

[82] មាត្រា១៩៦ កថាខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

• អាចចេញបានលុះត្រាតែបទល្មើសដែលចោទប្រកាន់ជាបទល្មើសឧក្រិដ្ឋ ឬ បទមជ្ឈិម ដែលច្បាប់កំណត់ត្រូវដាក់ពន្ធនាគារ និង បុគ្គលដែលពាក់ព័ន្ធ បានគេចខ្លួនមិនដឹងស្ថិតនៅទីកន្លែងណា ឬ ស្ថិតនៅក្រៅដែនដីព្រះរាជាណាចក្រកម្ពុជា ។[83]

ដីកាបង្គាប់ឲ្យចាប់ខ្លួនគឺជាការបញ្ជាដល់៖

• កងកម្លាំងសាធារណៈឲ្យស្រាវជ្រាវរកចាប់ និងនាំខ្លួនបុគ្គលនោះ ទៅក្នុងពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន

• ដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនឲ្យទទួល និង ឃុំខ្លួនបុគ្គលនោះ ។[84]

ដីកាបង្គាប់ឲ្យចាប់ខ្លួនអាចចេញដោយចៅក្រមស៊ើបសួរបាន ដោយត្រូវទទួលយោបល់ជាមុនសិនពីសំណាក់ព្រះរាជអាជ្ញា ។ ចៅក្រមស៊ើបសួរត្រូវចេញដីកានេះដោយមានថែងមូលហេតុ ក្រោយពីទទួលយោបល់ពីព្រះរាជអាជ្ញា ។ ព្រះរាជអាជ្ញា ជាអ្នកធានារ៉ាប់រងផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន ។[85]

**២.១.៣.២. និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឲ្យចាប់ខ្លួន**

ដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវតែមាននិទ្ទេសដូចតទៅ៖

• អត្តសញ្ញារបស់បុគ្គលដែលពាក់ព័ន្ធ

• បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់បង្ក្រាបបទល្មើសនេះ

• ឈ្មោះ និង ឋានៈចៅក្រមដែលចេញដីកា ។

ដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងត្រូវមានបោះត្រាផង ។[86]

**២.១.៣.៣ ការផ្សព្វផ្សាយជាអន្តរជាតិនូវដីកាបង្គាប់ឲ្យចាប់ខ្លួន**

ចំពោះការផ្សព្វផ្សាយ ដីកាបង្គាប់ឲ្យចាប់ខ្លួន នៅក្នុងករណីចាំបាច់អាចត្រូវផ្សព្វផ្សាយជាអន្តរជាតិតាមរយៈក្រសួងយុត្តិធម៌ ដោយប្រើយន្តការនានាដែលមានប្រសិទ្ធភាព ។[87]

**២.១.៣.៤. ការបង្ហាញខ្លួនតាមដីកាបង្គាប់ឲ្យចាប់ខ្លួន**

ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ត្រូវតែទទួល និងឃុំខ្លួនជនត្រូវចោទដែលជាកម្មវត្ថុនៃដីកាបង្គាប់ឲ្យចាប់ខ្លួន ។ ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនត្រូវរក្សាទុកដីកាដើម ឬ ចុងដីកា ដែលមានបញ្ជាក់ថា ត្រឹមត្រូវតាមច្បាប់ដើម។ បុគ្គលដែលពាក់ព័ន្ធត្រូវនាំខ្លួនទៅបង្ហាញនៅចំពោះមុខចៅក្រមស៊ើបសួរ ឬ អ្នកជំនួសចៅក្រម

[83] មាត្រា១៩៦ កថាខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧
[84] មាត្រា១៩៦ កថាខណ្ឌ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧
[85] មាត្រា១៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧
[86] មាត្រា១៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧
[87] មាត្រា២០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

ស៊ើបសួរក្នុងរយៈពេលយ៉ាងខ្លីបំផុត ប្រសិនបើស្ថិតនៅក្នុងដំណាក់កាលស៊ើបសួរនៅឡើយ។ ប្រសិនបើការនាំខ្លួនទៅបង្ហាញនេះ តម្រូវអោយមានការផ្ទេរបុគ្គលដែលពាក់ព័ន្ធទៅពន្ធនាគារ ឬ ទៅមណ្ឌលឃុំខ្លួនមួយផ្សេងទៀត ការផ្ទេរនេះត្រូវតែចាត់ចែងដោយអយ្យការ។ ប្រសិនបើបុគ្គលដែលពាក់ព័ន្ធមិនត្រូវបាននាំខ្លួនទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬ អ្នកជំនួសចៅក្រមស៊ើបសួរ នៅថ្ងៃបន្ទាប់ពីការចាប់ខ្លួន បុគ្គលនោះត្រូវតែបានព្រះរាជអាជ្ញានាទីកន្លែងឃុំខ្លួនសួរចម្លើយ ។ ព្រះរាជអាជ្ញាធ្វើកំណត់ហេតុស្តីពីការស្តាប់ចម្លើយ ដែលកំណត់ហេតុត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ ។[88]

**១.១.៣.៥. ការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួន**

ការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវប្រគល់ឲ្យមន្ត្រីនគរបាលយុត្តិធម៌ ។ ដីកាបង្គាប់ឲ្យចាប់ខ្លួនអាចត្រូវផ្សព្វផ្សាយទៅតាមអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ តាមគ្រប់មធ្យោបាយ នៅក្នុងករណីបន្ទាន់ ។ ចំណែកដើមដីកា ត្រូវតែប្រគល់ក្នុងរយៈពេលយ៉ាងខ្លីបំផុតឲ្យដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកអនុវត្តដីកានោះ។ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាច បានទេ ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវឲ្យដំណឹងទៅដលចៅក្រមស៊ើបសួរ អំពីការលំបាកទាំងអស់ នៅក្នុងពេលអនុវត្តបេសកកម្មរបស់ខ្លួន ។[89]

## ២.២. អំណាចនៅក្នុងការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

**២.២.១. សញ្ញាណនៃការត្រួតពិនិត្យតាមផ្លូវតុលាការ**

ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាប្រភេទមួយនៃសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរនៅក្នុងការដកហូតនូវសេរីភាពរបស់ជនត្រូវចោទ ដែលមានចង្អុលបង្ហាញនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ដោយត្រូវគោរពនូវកាតព្វកិច្ចក្នុងរយៈពេលកំណត់ណាមួយរបស់ចៅក្រមស៊ើបសួរ ។ ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ជាវិធានការពិសេសមួយដែលត្រូវតែប្រើនៅក្នុងករណីដែលមិនអាចជៀសវាងបាន។ មូលហេតុនៃការដាក់កាតព្វកិច្ចនោះ ពោលគឺការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺមិនមែនគ្រប់ជនត្រូវចោទត្រូវទទួលបានការដាក់កាតព្វកិច្ចតាមការពិនិត្យនោះឡើយ ។ រដ្ឋធម្មនុញ្ញក៏បានកំណត់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋដែលមិនអាចរំលោភបំពានបាន

[88] មាត្រា២០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[89] មាត្រា១៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

ដោយខុសច្បាប់បានឡើយ[90]ដែលប្រទេសជាច្រើន នៅលើសកលលោក បានយកចិត្តទុកដាក់ជាខ្លាំងទៅលើសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ[91] ។

ការដកហូតសេរីភាពរបស់ប្រជាពលរដ្ឋ នៅក្នុងការអនុវត្តជាក់ស្តែងឃើញថា ការដកហូតនូវសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋបានកើតឡើងស្ទើរតែគ្រប់ករណី មិនត្រឹមតែការដកហូតសេរីភាពតាមរយៈការដាក់ឲ្យស្ថិតនៅក្រោមត្រួតពិនិត្យតាមផ្លូវតុលាការនោះទេ ថែមទាំងមានការដកហូតនូវសិទ្ធិសេរីភាពរបស់ ជនត្រូវចោទតាមរយៈការឃុំខ្លួនបណ្តោះអាសន្ន ករណីសំណុំរឿងព្រហ្មទណ្ឌជាបទល្មើសជាក់ស្តែង ។ ការដកហូតសិទ្ធិសេរីភាពរបស់ជនត្រូវចោទ បានក្លាយទៅជាវិធានការទូទៅមួយដែលចៅក្រមស៊ើបសួរសម្រេចប្រើប្រាស់នៅក្នុងការអនុវត្តដើម្បីបង្កាបញ្ហាផ្សេងៗទៀតដែលកើតមាន ។

ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺចាំបាច់ត្រូវតែធ្វើឡើងដោយ ការសម្រេចរបស់ចៅក្រមស៊ើបសួរនៅពេលណា ដែលចៅក្រមស៊ើបសួរយល់ថាមានភស្តុតាងច្បាស់លាស់ និង ស៊ីសង្វាក់គ្នា ក្នុងការទទួលខុសត្រូវខាងព្រហ្មទណ្ឌប្រឆាំងនឹងបុគ្គលដែលជាកម្មវត្ថុនៃការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ។[92]

### ២.២.១.១. គោលការណ៍សេរីភាពរបស់បុគ្គល

គ្រប់បុគ្គលទាំងអស់ ជាគោលការណ៍គឺត្រូវតែមានសេរីភាពនៅក្នុងការដើរហើរបានគ្រប់ទីកន្លែង ។ ជាករណីលើកលែង នៅពេលដែលចៅក្រមស៊ើបសួរមានមន្ទិលសង្ស័យអំពីពិរុទ្ធភាពនៃការប្រព្រឹត្តបទល្មើសរបស់បុគ្គលនោះជាដើម ចៅក្រមស៊ើបសួរអាចដកហូតនូវសិទ្ធិសេរីភាពបាន តាមរយៈការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬ ការឃុំខ្លួនបណ្តោះអាសន្ន ។ គោលការណ៍សេរីភាពរបស់បុគ្គល គឺជាគោលការណ៍មួយដ៏សំខាន់ដែលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាធ្វើយ៉ាងណាធានាមិនអោយមានការដកហូតនូវសេរីភាពរបស់ជនត្រូវចោទដោយខុសនីតិវិធីច្បាប់ ។

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ក៏បានគោរពនិងកំណត់យកនូវគោលការណ៍សេរីភាពបុគ្គលជាគោលការណ៍អាទិភាព[93] ហើយការត្រួតពិនិត្យតាមផ្លូវតុលាការគឺជាវិធានពិសេសមួយដោយ

---

[90] មាត្រា៤០ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានចែងថា ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិ។

[91] សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិ

[92] សេចក្តីពន្យល់នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចំពោះករណីយុត្តិសាស្រអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា និងអន្តរជាតិសម្រាំង ឆ្នាំ២០១៤ ទំព័រ ៤១

[93] មាត្រា២០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

ទៀត ដែលចៅក្រមស៊ើបសួរអាចអនុវត្តបានដោយត្រូវ អនុលោមទៅតាមនីតិវិធីច្បាប់ ឲ្យបានច្បាស់លាស់នៅក្នុងករណីដែលមានចាំបាច់ ។

តាមរយៈគោលការណ៍សេរីភាពរបស់បុគ្គលនេះហើយ ទើបក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់យកការត្រួតពិនិត្យតាមផ្លូវតុលាការ ជាវិធានការមួយដែលមានលក្ខណៈស្រាលអាចជំនួស វិធានការនៃការឃុំខ្លួនបណ្តោះអាសន្ន ។ មួយវិញទៀត ការត្រួតពិនិត្យតាមផ្លូវតុលាការជាវិធានការដ៏ល្អមួយ ព្រោះបើសិនជាគ្មានការប្រើវិធានការនេះទេ នោះវិធានការដែលចៅក្រមស៊ើបសួរប្រើដើម្បីធានាបាននូវកិច្ចស៊ើបសួរ មានតែវិធានការតែមួយគត់គឺការឃុំខ្លួនបណ្តោះអាសន្ន ហើយជាផលវិបាកនឹងនាំអោយមានកំណើនជនត្រូវចោទដែលនៅក្នុងឃុំតាមពន្ធនាគារនឹងកើនឡើងយ៉ាងគំហុក។

### ២.២.១.២. គោលការណ៍សន្មតទុកជាមុននូវភាពគ្មានទោស

គោលការណ៍សន្មតទុកជាមុននូវភាពគ្មានទោស គឺជាគោលការណ៍មួយដ៏សំខាន់ ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចំពោះជនត្រូវចោទគ្រប់រូបត្រូវតែចាត់ទុកថាជាមនុស្សគ្មានទោសដរាបណាគ្មានសេចក្តីសម្រេចរបស់តុលាការដែលបានកាត់ទោសចូលជាស្ថាពរ ។[94] គោលការណ៍នេះ គឺជាសិទ្ធិមូលដ្ឋានរបស់ជនត្រូវចោទគ្រប់រូប ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ហើយការដាក់ទោសគឺធ្វើឡើងដោយផ្អែកទៅលើច្បាប់ មិនមែនកាត់ទោសទៅតាមអំពើចិត្តចំពោះបទល្មើសដែលជនជាប់ចោទបានប្រព្រឹត្តនោះទេ ពោលគឺការកាត់ក្តីត្រូវធ្វើដោយតុលាការដែលមានសិទ្ធិជម្រះក្តី[95] ក្នុងការកំណត់ថាបុគ្គលនោះពិតជាមានទោស ។

ផ្ទុយទៅវិញ ទោះបីជាសិទ្ធិរបស់បុគ្គលឯកជនត្រូវធានាដោយរដ្ឋធមនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាក៏ដោយ ក៏អាចមានករណីដែលមានការដកហូតនូវសិទ្ធិសេរីភាព ដែលធ្វើអោយប៉ះពាល់ដល់គោលការណ៍មួយចំនួនជា សិទ្ធិមូលដ្ឋានរបស់បុគ្គលឯកជននោះ ក្នុងករណីមានភាពចាំបាច់ក្នុងវិធានការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរតាមការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាកានេះ។

### ២.២.១.៣. លក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោម ការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា នៅក្នុងករណីដែលជនត្រូវចោទនោះត្រូវបានចោទប្រកាន់ ពីបទល្មើសដែលត្រូវកំណត់ដាក់ពន្ធនាគារ[96]

[94] មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[95] មាត្រា១២៩ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[96] មាត្រា២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

ហើយជនត្រូវចោទនោះជាបុគ្គលដែលមានអាយុចាប់ពី ១៤ ឆ្នាំឡើងទៅ[97] ។ យើងឃើញថា ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាការដាក់កាតព្វកិច្ចដោយ ចៅក្រមស៊ើបសួរទៅលើបុគ្គលដែលមានអាយុចាប់ពី ១៤ឆ្នាំឡើងទៅ និងបុគ្គលណាត្រូវបានចោទប្រកាន់ពីបទល្មើសដែលត្រូវដាក់ពន្ធនាគារ ។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ពុំមានចែងកំណត់អំពីមូលហេតុក្នុង ការដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការទេ តែច្បាប់ទុកលទ្ធភាពអោយចៅក្រមស៊ើបសួរក្នុងការសម្រេចដោយឥស្សរចិត្តរបស់គាត់ ថាតើការដកហូតនូវសិទ្ធិសេរីភាពមួយចំនួនរបស់បុគ្គលជាជនត្រូវចោទ ជាវិធានការដែលចាំបាច់ហើយសមស្របទៅនឹងស្ថានភាពរបស់បុគ្គលដែលបានប្រព្រឹត្តបទល្មើសដែរ ឬទេ ។

ទោះបីជាមូលហេតុនៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការមិនបានកំណត់ ដូចមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នដែលមានចែងក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាក៏ដោយ មូលហេតុចម្បងនៃការដាក់ ជនត្រូវចោទឲ្យស្ថិតនៅក្រោមវិធានការនៃ ការត្រួតពិនិត្យតាមផ្លូវតុលាការ គឺដើម្បីធានានូវកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ។

### ២.២.២. នីតិវិធីនៃការត្រួតពិនិត្យតាមផ្លូវតុលាការ

ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាអំណាចមួយរបស់ចៅក្រមស៊ើបសួរដែលមានយុត្តាធិការទៅលើបទល្មើសដែលខ្លួនបំពេញកិច្ចស៊ើបសួរ[98] ។ ចៅក្រមស៊ើបសួរមានសិទ្ធិនៅក្នុងការដាក់កាតព្វកិច្ចមួយ ឬ ច្រើនទៅលើបុគ្គលជាជនត្រូវចោទនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលត្រូវចង្អុលបង្ហាញឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ (**២.២.២.១. ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ**) និងត្រូវមានការបង្ហាញខ្លួនលើកដំបូងនៅចំពោះមុខចៅក្រមស៊ើបសួរ (**២.២.២.២. ការបង្ហាញខ្លួនលើកដំបូង**) ។ លើសពីនេះ នៅក្នុងករណីដែលមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ឲ្យឃុំខ្លួនជនត្រូវចោទទៀត នោះចៅក្រមស៊ើបសួរត្រូវតែធ្វើការពិភាក្សាដេញដោលចំពោះមុខ (**២.២.២.៣. ការពិភាក្សាដេញដោលចំពោះមុខ**) និងត្រូវធ្វើកំណត់ហេតុសួរចម្លើយជនត្រូវចោទ (**២.២.២.៤. ការសួរចម្លើយជនត្រូវចោទ**) ទើបចៅក្រមអាចចេញ ដីកាសម្រេចដាក់ជនត្រូវចោទ ឲ្យស្ថិតនៅក្រោម ការត្រួតពិនិត្យតាមផ្លូវតុលាការ **(២.២.២.៥. ដីកាសម្រេចឲ្យដាក់ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ)** ដែលខាងលើនេះជានីតិវិធីសំ

[97] មាត្រា២២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[98] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា ១២២ បានកំណត់អំពីសមត្ថកិច្ចដែនដីរបស់ចៅក្រមស៊ើបសួររួមមាន " ចៅក្រមស៊ើបសួរនាទីកន្លែងប្រព្រឹត្តបទល្មើស ចៅក្រមស៊ើបសួរនាទៅលំនៅឋាន ឬ ទីសំណាក់របស់បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស និង ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស "។

ខាន់ៗ ដើម្បីអាចអោយចៅក្រមស៊ើបសួរឈានទៅដល់ការចេញដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន ។

### ២.២.២.១. ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ

ជាគោលការណ៍ ចៅក្រមស៊ើបសួរអាចបើកការស៊ើបសួរបានលុះត្រាតែមាន ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការជាមុនសិន[99] ។ តំណាងអយ្យការអាចជ្រើសរើសយកនូវជម្រើសនៃការចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដោយមានកំណត់នូវបទល្មើស និងបុគ្គល ឬ អញ្ញត្តជន ដើម្បីអោយចៅក្រមស៊ើបសួរបើកការស៊ើបសួរទៅលើកម្មវត្ថុដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[100] ។ ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺអាចដាក់ទៅលើបុគ្គលជាជនត្រូវចោទដែលមានអត្តសញ្ញាណហើយចង្អុលឈ្មោះនៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ ដើម្បីអនុវត្តនូវកាតព្វកិច្ចត្រូវបំពេញតាមការកំណត់របស់ចៅក្រមស៊ើបសួរ ដែលវិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការនេះមិនអាចអនុវត្តទៅលើអញ្ញត្តជនដែលពុំស្គាល់អត្តសញ្ញាណបាននោះទេ ព្រោះពុំមានអ្នកដែលត្រូវអនុវត្តនូវកាតព្វកិច្ចនោះទេ។ ក្នុងដំណាក់កាលដែល តំណាងអយ្យការបានចោទប្រកាន់ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដើម្បីអោយចៅក្រមស៊ើបសួរស្វែងរកពីអត្ថិភាព ឬ នត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌ ព្រោះចៅក្រមស៊ើបសួរធ្វើការស៊ើបសួរទាំងដោះបន្ទុកនិងដាក់បន្ទុកដែលមានប្រយោជន៍ដើម្បីបង្ហាញឲ្យឃើញពីការពិត[101] ជនដែលជាកម្មវត្ថុនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរមានឋានៈជាជនត្រូវចោទ ហើយចៅក្រមស៊ើបសួរ ត្រូវដាក់ជននោះឲ្យស្ថិតក្រោមការពិនិត្យពី បទល្មើសដែលតំណាងអយ្យការបានចោទប្រកាន់ ហើយគាត់ក៏មានអំណាចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលគ្រប់រូប ដែលមានតម្រុយច្បាស់លាស់ហើយមានការស៊ីសង្វាក់គ្នាថាបានចូលរួមប្រព្រឹត្តបទល្មើស ទោះបីគ្មានការចង្អុលបង្ហាញឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ក្នុងឋានៈជាចារី ឬអ្នកផ្តើមគំនិត ឬជាអ្នកសមគំនិតក៏ដោយ [102] ។ ចៅក្រមស៊ើបសួរ អាចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ចំពោះបុគ្គលដែលត្រូវដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ តែមិនមែនមានន័យថា ឲ្យតែបុគ្គលដែលដាក់ឲ្យស្ថិត នៅក្រោមការពិនិត្យសុទ្ធតែត្រូវដាក់កាតព្វកិច្ច នៃការត្រួត

[99] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា ៤៤ កថាខ័ណ្ឌទី២ និង មាត្រា១២៤ កថាខ័ណ្ឌទី៣ បានកំណត់ថា ការស៊ើបសួរត្រូវបើកតាមដីកាបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរដែលមានសមត្ថកិច្ច ហើយចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបាន ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួររបស់ព្រះរាជអាជ្ញាទេ ។

[100] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤៣ កថាខ័ណ្ឌទី១ និងមាត្រា១២៤ កថាខ័ណ្ឌទី២ វាក្យខ័ណ្ឌ ចែងថា ការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌអាចធ្វើតាមការបើកការស៊ើបសួរ ប្រឆាំងលើបុគ្គលម្នាក់ ឬ ច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬ ប្រឆាំងលើអញ្ញាតជន ។

[101] មាត្រា១២៧ កថាខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[102] មាត្រា១២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

ពិនិត្យតាមផ្លូវតុលាការនោះទេ លើកលែងតែមានករណីចាំបាច់ពិសេស ។

**២.២.២.២. ការបង្ហាញខ្លួនលើកដំបូង**

ចៅក្រមស៊ើបសួរត្រូវតែពិនិត្យអត្តសញ្ញាណរបស់ជនត្រូវចោទ ថាតើជនត្រូវចោទជាបុគ្គលដែលចង្អុលបង្ហាញនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការដែរឬទេ នៅពេលដែលជននោះចូលបង្ហាញខ្លួនលើកដំបូងនៅចំពោះមុខចៅក្រមស៊ើបសួរ ។[103] នៅពេលបង្ហាញខ្លួនភ្លាម ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុមួយ ហៅថាកំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាម ដោយចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទអំពីរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់ ដែលទាំងនេះជាការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យដល់ជនត្រូវចោទ ។ ចៅក្រមស៊ើបសួរ នៅពេលជនត្រូវចោទចូលបង្ហាញខ្លួន ត្រូវប្រាប់ដល់ជននោះនូវសិទ្ធិដែលជនត្រូវចោទមាននៅក្នុងដំណាក់កាលស៊ើបសួររួមមានសិទ្ធិដូចជា៖

• សិទ្ធិនៅស្ងៀមមិនផ្តល់ចម្លើយ៖ គឺជាសិទ្ធិដែលជនត្រូវចោទមិនត្រូវបានគេយកចម្លើយដោយការបង្ខិតបង្ខំ ការគំរាមកំហែង ឬឲ្យជនត្រូវចោទទទួលសារភាពដាក់បន្ទុកមកលើខ្លួនឡើយ[104] ហើយជនត្រូវចោទអាចឆ្លើយ ឬ មិនឆ្លើយដោយសេរី ។ បើសិនជនត្រូវចោទឆ្លើយ នោះចៅក្រមស៊ើបសួរត្រូវយកចម្លើយនោះភ្លាម ។

• សិទ្ធិទទួលបានមេធាវី៖ គឺជាសិទ្ធិដែលផ្តល់ទៅឲ្យជនត្រូវចោទក្នុងការទទួលបាននូវបុគ្គលដែលមានចំណេះដឹងផ្នែកច្បាប់មកការពារផលប្រយោជន៍របស់ខ្លួន ខណៈពេលដែលខ្លួនពុំមាន ចំណេះដឹងអំពីបញ្ហាផ្លូវច្បាប់ តាមរយៈការជ្រើសរើសមេធាវីដោយបុគ្គលជាជនត្រូវចោទ ឬ តាមយៈការស្នើសុំរបស់ចៅក្រមស៊ើបសួរឲ្យចាត់តាំងមេធាវីឲ្យខ្លួន ។ ចំពោះអនីតិជនវិញ ត្រូវតែមានមេធាវីនៅអមជានិច្ច[105]។

• សិទ្ធិទទួលជំនួយពីអ្នកបកប្រែ៖ គឺជាសិទ្ធិដែលជនត្រូវចោទអាចទទួលបានជំនួយពីអ្នកបកប្រែ នៅពេលដែលខ្លួនមិនអាចអាន ស្តាប់ និងនិយាភាសាខ្មែរបាន ។[106]

**២.២.២.៣. ការពិភាក្សាដេញដោលចំពោះមុខ**

ការពិភាក្សាចំពោះមុខ គឺជានីតិវិធីមួយដែលចៅក្រមស៊ើបសួរធ្វើការវិនិច្ឆ័យ និងស្តាប់ការសន្និដ្ឋានស្នើសុំរបស់តំណាងអយ្យការដែលត្រូវបង្ហាញមូលហេតុដើម្បីធ្វើអោយ ចៅក្រមស៊ើបសួរយល់ឃើញថា ការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន ជាវិធានការចាំបាច់នៅក្នុងរឿងនេះ និងពិនិត្យលើមធ្យោបាយមេធាវីការពាររបស់

[103] មាត្រា១៤៣ កថាខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[104] មាត្រា៣៨ កថាខ័ណ្ឌទី៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានកំណត់ថា ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី ឬ ផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ ។

[105] មាត្រា១៤៣ កថាខណ្ឌ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[106] មាត្រា១៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

ជនត្រូវចោទ[107] ចំពោះការសម្រេចអោយមាន ការឃុំខ្លួនជនត្រូវចោទដែលចង្អុលបង្ហាញនៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ឬ យោបល់ផ្ទាល់មាត់របស់ព្រះរាជអាជ្ញា ។

នៅក្នុងការអនុវត្តជាក់ស្តែង នៅពេលដែលព្រះរាជអាជ្ញាបានចោទប្រកាន់បុគ្គលណាម្នាក់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ហើយព្រះរាជអាជ្ញាស្នើសុំអោយ ចៅក្រមស៊ើបសួរធ្វើការឃុំខ្លួនបណ្ដោះអាសន្ន នោះចៅក្រមស៊ើបសួរត្រូវតែធ្វើនីតិវិធីនៃការដេញដោលពិភាក្សាចំពោះមុខ ដើម្បីសម្រេចថា តើគួរឃុំខ្លួន ឬ មិនគួរឃុំខ្លួនជនត្រូវចោទ ។ ចៅក្រមស៊ើបសួរ មានសិទ្ធិសម្រេចថាឃុំ ឬ មិនឃុំខ្លួនជននោះ។ បើសិនជាមិនឃុំចៅក្រមស៊ើបសួរត្រូវតែដាក់ ជននោះនូវ កាតព្វកិច្ចតាមផ្លូវតុលាការវិញជំនួសឲ្យ វិធានការនៃការឃុំខ្លួនបណ្ដោះអាសន្ន។ ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្នចំពោះជននោះទេ ចៅក្រមស៊ើបសួរអាចដាក់កាតព្វកិច្ចមួយ ឬ ច្រើនទៅលើជននោះ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាពុំមានមូលហេតុគ្រប់គ្រាន់សម្រាប់ធ្វើការឃុំខ្លួនជននោះ[108] ។

ការដេញដោលចំពោះមុខ ត្រូវធ្វើឡើងដោយមានកំណត់ហេតុមួយហៅថា កំណត់ហេតុស្ដីពីការពិភាក្សាដេញដោលចំពោះមុខ ដោយមានការចុះនិទ្ទេសទៅក្នុងកំណត់ហេតុនេះ ដែលមានសមាសភាពចូលរួមពីចៅក្រមស៊ើបសួរ តំណាងអយ្យការ និងជនត្រូវចោទ ហើយបើសិនជនត្រូវចោទមានមេធាវីការពារ គឺត្រូវមានវត្តមានមេធាវី ។

ផ្ទុយទៅវិញ នៅក្នុងករណីព្រះរាជអាជ្ញាមិនបានស្នើសុំចៅក្រមស៊ើបសួរអោយឃុំខ្លួនជនត្រូវចោទ តែព្រះរាជអាជ្ញាស្នើសុំឲ្យមានការដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការវិញ នោះនីតិវិធីនៃការពិភាក្សាចំពោះមុខនឹងមិនត្រូវយកមកអនុវត្តទេ ដោយហេតុតែនីតិវិធីដេញដោលពិភាក្សាចំពោះមុខ ត្រូវធ្វើឡើងក្នុងគោលបំណងពាក់ព័ន្ធនឹងវិធានការនៃការឃុំខ្លួនបណ្ដោះអាសន្នតែប៉ុណ្ណោះ ។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ វិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ពុំមានតម្រូវឲ្យចៅក្រមស៊ើបសួរត្រូវទទួលយោបល់ពីជនត្រូវចោទ ឬ ព្រះរាជអាជ្ញានោះទេ ។ នីតិវិធីនៃការពិភាក្សាដេញដោលចំពោះមុខមិនត្រូវយកមកអនុវត្តចំពោះវិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការទេ ដោយហេតុថាវិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការ មានការដកហូតនូវសិទ្ធិសេរីភាពរបស់ជនត្រូវចោទស្រាលជាងវិធានការឃុំខ្លួនបណ្ដោះអាសន្ន ហើយជាវិធានការនៃការធានាកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ។ លើសពីនេះទៅទៀត ជនត្រូវចោទ និង តំណាងអយ្យការក៏អាចប្ដឹងឧទ្ធរណ៍ចំពោះដីកានេះបានផងដែរ ។[109]

---

[107] មាត្រា២០៦ កថាខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[108] មាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[109] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា២៦៦ និងមាត្រា២៦៧ បានចែងថា គ្រប់ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរអាចជាកម្មវត្ថុ

### ២.២.២.៤ ការសួរចម្លើយជនត្រូវចោទ

ការសួរចម្លើយ គឺជាវិធានការមួយដើម្បីស្វែងរកការពិតនៅក្នុងដំណាក់កាលស៊ើបសួរ ហើយវាក៏ជាផ្នែកមួយដ៏សំខាន់ផងដែរ សម្រាប់ចៅក្រមស៊ើបសួរក្នុងការពិចារណាថាតើគួរដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬយ៉ាងណា ។

នៅពេលដែលមានការបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរ នឹងធ្វើការសួរចម្លើយអំពីរឿងរ៉ាវដែលពាក់ព័ន្ធនឹងរឿងក្ដីរបស់ ជនត្រូវចោទ ដែលវានឹងផ្ដល់ជាពត៌មានបន្ថែមសម្រាប់ ចៅក្រមស៊ើបសួរ ដើម្បីធ្វើការសម្រេច ។ នេះក៏ជាសិទ្ធិរបស់ជនត្រូវចោទមួយផងដែរ ដែលអាចឲ្យជនត្រូវចោទអាចធ្វើការបំភ្លឺអំពីអង្គហេតុ មុននឹងគេធ្វើការដកហូតនូវសិទ្ធិសេរីភាពរបស់គេ។ ការសួរចម្លើយជនត្រូវចោទ នឹងត្រូវបានកត់នូវរាល់សំណួរ និងចម្លើយនៅពេលដែលធ្វើការសាកសួរនោះចូលទៅក្នុងកំណត់ហេតុស្ដាប់ចម្លើយ។

### ២.២.២.៥. ដីកាសម្រេចឲ្យដាក់ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

នៅក្នុងករណីដែលចៅក្រមស៊ើបសួរ សម្រេចដាក់ជនត្រូវចោទជាកម្មវត្ថុនៃ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា តាមរយៈគំនិតផ្ដួចផ្ដើមរបស់ខ្លួនផ្ទាល់ ឬ តាមរយៈសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា[110] ចៅក្រមស៊ើបសួរត្រូវតែបញ្ជាក់ពីកាតព្វកិច្ចមួយ ឬ ច្រើន ដែលជនត្រូវចោទត្រូវគោរព នៅក្នុងដីកាសម្រេចដាក់ជនត្រូវចោទ ឲ្យស្ថិតនៅក្រោម ការត្រួតពិនិត្យតាមផ្លូវតុលាការ និងសំអាងហេតុនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន ។

ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់និទ្ទេសទូទៅសម្រាប់ចុះនៅក្នុងដីកាដែលជាកាតព្វកិច្ចរបស់ចៅក្រមស៊ើបសួររួមមានដូចជា ៖

- ឈ្មោះរបស់ចៅក្រមស៊ើបសួរ
- ឈ្មោះក្រឡាបញ្ជី
- លេខ ខែ ឆ្នាំ សំណុំរឿង
- កាលបរិច្ឆេទនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ
- ប្រភេទនៃបទល្មើស ដែលចង្អុលប្រាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ
- ការបរិច្ឆេទនៃការធ្វើកំណត់ហេតុ ។

---

នៃការប្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញា ហើយជនត្រូវចោទក៏មានសិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍ចំពោះដីការបស់ចៅក្រមស៊ើបសួរស្ដីពីរឿងឃុំខ្លួនបណ្ដោះអាសន្នក៏ដូចជាដីកាដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

[110] មាត្រា២២៦ កថាខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

ទំព័រនីមួយៗនៃកំណត់ហេតុ ត្រូវតែចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងដោយក្រឡាបញ្ជី ។ កំណត់ហេតុមិនត្រូវឲ្យមានចន្លោះបន្ទាត់ទេ ។ ការឆូតលុប ឬ ការយោងត្រូវមានបញ្ជាក់ដោយហត្ថលេខារបស់ចៅក្រមស៊ើបសួរ និង ក្រឡាបញ្ជី នៅរឹមទំព័រ ។[111]

**២.២.៣. អានុភាពនៃការត្រួតពិនិត្យតាមផ្លូវតុលាការ**

ជាគោលការណ៍ ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ មានអានុភាពទៅលើបុគ្គលជាជនត្រូវចោទដែលចង្អុលបង្ហាញនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ ។ ដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាការកំណត់នូវកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ មួយ ឬ ច្រើន សម្រាប់ជាវិធានការបង្ការទៅលើជនត្រូវចោទដើម្បីអនុវត្តកាតព្វកិច្ចនោះអោយបានខ្ជាប់ខ្ជួន ហើយការដាក់កាតព្វកិច្ចនោះអាចត្រូវបានធ្វើការកែប្រែ គ្រប់ពេលវេលាទៅតាមស្ថានភាពជាក់ស្តែង និងមានកំណត់នូវវិធានការត្រួតពិនិត្យ តាមដានការអនុវត្តការត្រួតពិនិត្យតាមផ្លូវតុលាការ នៅក្នុងករណីបុគ្គលនោះបានគេចវេសដោយចេតនាពី ការអនុវត្តកាតព្វកិច្ចកំណត់ដោយចៅក្រមស៊ើបសួរ ។ ដើម្បីយល់កាន់ច្បាស់ យើងនឹងសិក្សាអំពី **(២.២.៣.១) កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ និង (២.២.៣.២) ការកែប្រែកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ**

**២.២.៣.១. កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ**

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់នូវកាតព្វកិច្ចសម្រាប់តម្រូវឲ្យជនត្រូវចោទនៅក្នុងវិធានការនិរន្តរាយ ។ កាតព្វកិច្ចដែលដាក់ទៅលើជនត្រូវចោទ បានកំណត់ជាចំណុចគោលៗដើម្បីទុកលទ្ធភាពឲ្យចៅក្រមស៊ើបសួរ ធ្វើការបកស្រាយទៅតាមឆន្ទានុសិទ្ធិយកទៅអនុវត្តតាមករណី និងស្ថានភាពជាក់ស្តែង នៅក្នុងសំណុំរឿងនីមួយៗ ។ ចៅក្រមស៊ើបសួរអាចដាក់កាតព្វកិច្ចមួយ ឬ ច្រើន ទៅលើជនត្រូវចោទដែលចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ដើម្បីធានាបាននូវការអនុវត្តនីតិវិធីបន្តបន្ទាប់ដោយពុំមានការគេចវេះ ឬ ផលវិបាកសម្រាប់ដំណាក់កាលនៃនីតិវិធី។

ការត្រួតពិនិត្យតាមផ្លូវតុលាការ គឺពុំមានចែងពីមូលហេតុដែលចៅក្រមស៊ើបសួរត្រូវពិចារណាក្នុងការយកមកសំអាងហេតុនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនឲ្យបានច្បាស់លាស់ និងជាក់លាក់ឡើយ ។ ក៏ប៉ុន្តែ ការត្រួតពិនិត្យតាមផ្លូវតុលាការ គឺគ្រាន់តែមានចែងកាតព្វកិច្ចដែលត្រូវដាក់ទៅលើជនត្រូវចោទប៉ុណ្ណោះ ។ កាតព្វកិច្ចនីមួយៗ គឺជាមូលហេតុដែលអាចឲ្យចៅក្រមស៊ើបសួរធ្វើការពិចារណា ទៅលើការចេញដីកាសម្រេចដាក់ឲ្យស្ថិត

[111] មាត្រា២៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

នៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលកាតព្វកិច្ចទាំងនោះមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌរួមមាន ដូចជា ៖

- មិនត្រូវចេញពីព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ
- មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ
- មិនត្រូវទៅកាន់ទីកន្លែងខ្លះកំណត់ដោយចៅក្រមស៊ើបសួរ
- ត្រូវតែចូលបង្ហាញខ្លួនតាមការកំណត់ នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ
- ត្រូវឆ្លើយតបទៅតាមការកោះហៅពីបុគ្គលគ្រប់រូបដែលចាត់តាំងដោយចៅក្រមស៊ើបសួរ
- ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ
- មិនត្រូវបើកបររថយន្ត
- មិនត្រូវទទួល ឬ ជួបបុគ្គលមួយចំនួន ដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ
- ការដាក់ប្រាក់ធានាដែលចំនួនទឹកប្រាក់ធានា និងចិរវេលាបង់ប្រាក់នេះ ត្រូវកំណត់ដោយចៅក្រមស៊ើបសួរដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ
- មិនត្រូវកាន់កាប់ ឬ យកតាមខ្លួននូវអាវុធ ។ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់
- ត្រូវប្រគល់ខ្លួនឲ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុ ដាក់ឲ្យស្ថិតនៅក្រោមរបបព្យាបាលរោគនៅក្នុងមន្ទីរពេទ្យ
- មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ ។[112]

**២.២.៣.២. ការកែប្រែកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ**

ការដាក់កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការទៅលើជនត្រូវចោទ ជាវិធានការពិសេសកំណត់ដោយចៅក្រមស៊ើបសួរ ដោយពិចារណាទៅលើភាពចាំបាច់នៃការដាក់កាតព្វកិច្ចនីមួយៗដោយគិតទៅលើមូលហេតុនៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ គិតទៅលើស្ថានភាពដែលអាចអនុវត្តនូវកាតព្វកិច្ចដោយយោងទៅលើកត្តាសង្គម កត្តាភូមិសាស្ត្រ និងស្ថានភាពរបស់បុគ្គលជាជនត្រូវចោទនោះតែម្តង ។ ក៏ប៉ុន្តែកាតព្វកិច្ចដែលបានកំណត់នោះអាចនឹងរលត់ ហើយភាពចាំបាច់នៃការអនុវត្តកាតព្វកិច្ចក៏ត្រូវរលត់ដែរ តាមរយៈការកែប្រែរបស់ចៅក្រមស៊ើបសួរ (ក) **ការកែប្រែកាតព្វកិច្ចដោយចៅក្រមស៊ើបសួរ** តំណាងអយ្យការ (ខ) **ការកែប្រែ**

[112] មាត្រា២២៣ កថាខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

**កាតព្វកិច្ចដោយបណ្ដឹងសុំរបស់ព្រះរាជអាជ្ញា** និង ជនត្រូវចោទផ្ទាល់ (គ) **ការកែប្រែកាតព្វកិច្ចដោយបណ្ដឹងសុំរបស់ជនត្រូវចោទ។**

**ក. ការកែប្រែកាតព្វកិច្ចដោយចៅក្រមស៊ើបសួរ**

ចៅក្រមស៊ើបសួរនៅពេលសម្រេចដាក់កាតព្វកិច្ចទៅលើជនត្រូវចោទតាមរយៈដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការតាមមូលហេតុចាំបាច់នៃការចេញដីកាសម្រេចនោះ លោកអាចតាមដានកាតព្វកិច្ចដែលបានដាក់ទៅលើជនត្រូវចោទ ថាតើអាចអនុវត្តបានដែរ ឬទេ និងកាតព្វកិច្ចដែលបានដាក់នោះលែងមានភាពចាំបាច់ហើយ ឬនៅ ។ នៅក្នុងករណីដែលចៅក្រមស៊ើបសួរខ្លួនឯងយល់ឃើញថាលែងមានភាពចាំបាច់ដែលអោយជនត្រូវចោទអនុវត្តកាតព្វកិច្ចដែលបានដាក់នោះតទៅទៀត ឬ យល់ឃើញថាកាតព្វកិច្ចមួយផ្សេងទៀតដែលមានភាពចាំបាច់សមស្របជាមួយស្ថានភាពជាក់ស្ដែង នោះចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចថ្មីមួយទៀតសម្រាប់កែប្រែខ្លឹមសារ ឬ បញ្ចូលនូវកាតព្វកិច្ចថ្មីណាមួយទៀត[113]សម្រាប់ឲ្យជនត្រូវចោទនោះអនុវត្តបានគ្រប់ពេលវេលា[114] ។

ការចេញដីកាសម្រេចនេះ ត្រូវតែជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទដែលចាំបាច់ឲ្យព្រះរាជអាជ្ញា និងជនត្រូវចោទអាចអនុវត្តបាន ឬកែប្រែការអនុវត្តតាមដីកាសម្រេចថ្មីរបស់ចៅក្រមស៊ើបសួរនោះប្រកបដោយប្រសិទ្ធភាព ព្រោះដីកាខាងលើនេះមានគោលបំណងឲ្យ ជនត្រូវចោទធ្វើការអនុវត្តតាមវិធានការដែលចៅក្រមស៊ើបសួរបានដាក់ចេញ ហើយបើមិនជូនដំណឹងទៅអ្នកចាត់ចែងអនុវត្ត និងអ្នកត្រូវទទួលអនុវត្ត នោះដីកាសម្រេចថ្មីដែលចេញមកនឹងមិនអាចអនុវត្តបាននោះទេ។

**ខ. ការកែប្រែកាតព្វកិច្ចដោយបណ្ដឹងសុំរបស់ព្រះរាជអាជ្ញា**

ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ក៏បានផ្ដល់សិទ្ធិទៅឱ្យ តំណាងអយ្យការដូចចៅក្រមស៊ើបសួរដែរ ក្នុងការស្នើសុំអោយមានការលើកលែង ឬ កែប្រែកាតព្វកិច្ចដែលដាក់ទៅលើជនត្រូវចោទបានគ្រប់ពេលវេលា[115] ដោយតាមការដាក់ពាក្យបណ្ដឹងសុំ។ ច្បាប់ពុំបានកំណត់ពី មូលហេតុដែលនាំអោយតំណាងអយ្យការដាក់ពាក្យសុំនោះទេ តែច្បាប់បានផ្ដល់សិទ្ធិសេរីភាពតាមការយល់ឃើញ និងការចាត់ចែងការអនុវត្តតាមកាលៈទេសៈជាក់ស្ដែងនៃការអនុវត្តយន្តការនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ។ នៅពេលមានពាក្យសុំតាមបណ្ដឹងរបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវតែសម្រេចនៅក្នុងរយៈពេល ០៥ថ្ងៃ ហើយបើសិនចៅក្រមស៊ើប

[113] មាត្រា២២៣ កថាខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[114] មាត្រា២២៧ កថាខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[115] មាត្រា២២៨ កថាខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

ស្នួរមិនបានសម្រេចនៅក្នុងរយៈពេលកំណត់នេះទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យសុំទៅសភាស៊ើបសួរឲ្យសម្រេចជំនួសចៅក្រមស៊ើបសួរ[116] ។

នៅក្នុងករណីចៅក្រមស៊ើបសួរមិនព្រមធ្វើតាមបណ្ដឹងសុំរបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវចេញដីកាដោយមានសំអាងហេតុ[117] ដោយហេតុថាច្បាប់បានគោរពគោលការណ៍សេរីភាពបុគ្គលជាធំ ដែលការដាក់ពាក្យសុំលើកលែង ឬ កែប្រែ មិនទាមទារសំអាងហេតុ ហើយបើសម្រេចយល់ព្រមតាមការលើកលែង ឬ កែប្រែក៏មិនទាមទារសំអាងហេតុដែរ គឺមានតែដីកាសម្រេចមិនឲ្យលើកលែង ឬកែប្រែទេដែលត្រូវតែមានសំអាងហេតុជាចាំបាច់ ។

## គ. ការកែប្រែកាតព្វកិច្ចដោយបណ្ដឹងសុំរបស់ជនត្រូវចោទ

ជាទូទៅ នៅពេលដែលបុគ្គលណាម្នាក់ត្រូវបានទទួលរងនូវការរំលោភនូវសិទ្ធិសេរីភាព ដែលធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់គេ នោះគេក៏អាចធ្វើការតវ៉ាដើម្បីសុំឲ្យមានការលើកលែងបានផងដែរ ។ ជនត្រូវចោទអាចធ្វើការដាក់ពាក្យសុំទៅចៅក្រមស៊ើបសួរបានគ្រប់ពេលវេលា ដើម្បីសុំឲ្យចៅក្រមស៊ើបសួរដែលដាក់កាតព្វកិច្ចឲ្យរូបគេត្រូវគោរពនោះ ធ្វើការកែប្រែកាតព្វកិច្ចនោះ បើខ្លួនយល់ឃើញថាកាតព្វកិច្ចនោះលែងមានភាពចាំបាច់ សម្រាប់ដាក់មកលើខ្លួនទៀត ហើយគប្បីឲ្យចៅក្រមស៊ើបសួរ សម្រេចលុបចោលនូវកាតព្វកិច្ចដែលបានដាក់នោះ[118]។

នៅពេលដែលមានបណ្ដឹងសុំឲ្យកែប្រែកាតព្វកិច្ចដោយជនត្រូវចោទ ចៅក្រមស៊ើបសួរត្រូវតែបញ្ជូនពាក្យសុំនោះភ្លាមទៅព្រះរាជអាជ្ញា និងសុំយោបល់ និងជូនសំណុំរឿងទៅឲ្យព្រះរាជអាជ្ញាពិនិត្យ តាមរយៈដីកាបញ្ជូនឲ្យឆ្លើយ ហើយព្រះរាជអាជ្ញាត្រូវតែធ្វើការផ្ដល់យោបល់តាមរយៈចំណារលើដីកាបញ្ជូនឲ្យឆ្លើយនោះ ជូនមកចៅក្រមស៊ើបសួរដើម្បីពិនិត្យ និងសម្រេចអនុលោមទៅតាមច្បាប់ ។

ព្រះរាជអាជ្ញាត្រូវតែបំពេញកិច្ចនេះឲ្យបានលឿនបំផុត ដោយហេតុថាបើសិនជា ចៅក្រមស៊ើបសួរមិនបានចេញដីកាសម្រេច ចំពោះពាក្យសុំរបស់ជនត្រូវចោទ ក្នុងរយៈពេល ០៥ ថ្ងៃទេនោះជនត្រូវចោទអាចដាក់ពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរបាន[119]។ ចំពោះការសម្រេចលើពាក្យសុំរបស់ជនត្រូវចោទ គឺមានលក្ខណៈដូចគ្នាទៅនឹង ពាក្យសុំរបស់ព្រះរាជអាជ្ញាផងដែរ បើសិនជាចៅក្រមស៊ើបសួរសម្រេចមិនកែប្រែតាមពាក្យសុំ ចៅក្រមស៊ើបសួរត្រូវតែមានសំអាងហេតុ ។

[116] មាត្រា២២៨ កថាខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[117] មាត្រា២២៨ កថាខណ្ឌ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[118] មាត្រា២២៩ កថាខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[119] មាត្រា២២៩ កថាខណ្ឌ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

### ២.២.៤ ការបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ

យើងដឹងហើយថាចៅក្រមស៊ើបសួរមានសិទ្ធិអំណាចនៅក្នុងការកែប្រែកាតព្វកិច្ច អាចលុបចោល ឬ បញ្ចូលកាតព្វកិច្ចថ្មីបានគ្រប់ពេលវេលា ហើយចៅក្រមស៊ើបសួរក៏មានសិទ្ធិអំណាចអាចបញ្ចប់ ការត្រួតពិនិត្យតាមផ្លូវតុលាការបានផងដែរ[120] ។ ចៅក្រមមានសិទ្ធិអំណាចនៅក្នុងការបញ្ចប់នូវដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានដោយឯកឯង និងដោយពិនិត្យឃើញថា ការដាក់កាតព្វកិច្ចទាមទារអោយមានសំអាងហេតុ ហើយចំពោះ ការបញ្ចប់ដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោម ការត្រួតពិនិត្យតាមផ្លូវតុលាការ មិនទាមទារឲ្យចៅក្រមស៊ើបសួរសម្រេចដោយមានសំអាងហេតុឡើយ ។ ដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនឹងបញ្ចប់ដោយស្វ័យប្រវត្តិ បើសិនជាចៅក្រមស៊ើបសួរពុំបានសម្រេចរក្សាដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោម ការត្រួតពិនិត្យតាមផ្លូវតុលាការ តាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ[121] ។ ហេតុនេះនៅក្នុងករណីដែលចៅក្រមស៊ើបសួរបានចេញដីកាដំណោះស្រាយក៏ដោយ ក៏ការដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនៅតែមានអានុភាពបន្តទៅទៀតដែរ បើសិនជាចៅក្រមស៊ើបសួរចេញសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយហៅថា "**ដីកាបង្គាប់ឲ្យរក្សាជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ** "។

[120] មាត្រា២២៧ កថាខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[121] មាត្រា២២៩ កថាខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

# ជំពូកទី៣
# អំណាចនៅក្នុងការសម្រេចឃុំខ្លួនជនត្រូវចោទដោយចៅក្រមស៊ើបសួរ

នៅក្នុងជំពូកនេះយើងនឹងធ្វើការសិក្សាទៅលើ (៣.១) **អំណាចក្នុងការចេញដីកាបង្គាប់ឲ្យឃុំខ្លួនជនត្រូវចោទ (៣.២) ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន និង (៣.៣) អំណាចរបស់ចៅក្រមស៊ើបសួរក្រោយពេលសម្រេចឃុំខ្លួនបណ្តោះអាសន្ន។**

## ៣.១. អំណាចក្នុងការចេញដីកាបង្គាប់ឲ្យឃុំខ្លួនជនត្រូវចោទ

### ៣.១.១ គោលបំណងនៃការចេញដីកាបង្គាប់ឲ្យឃុំខ្លួន

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់ សិទ្ធិអំណាចទៅឲ្យចៅក្រមស៊ើបសួរនៅក្នុងការសម្រេចឲ្យជនត្រូវចោទនៅក្រៅឃុំ ឬ ត្រូវឃុំខ្លួនបណ្តោះអាសន្ន ក្រោយពីជនត្រូវចោទចូលខ្លួនជាលើកដំបូងនៅចំពោះមុខចៅក្រមស៊ើបសួរ។ ច្បាប់បានផ្តល់សិទ្ធិឲ្យចៅក្រមស៊ើបសួរ ធ្វើការពិចារណាទៅលើសំណុំរឿងរបស់ជនត្រូវចោទ ប្រសិនបើគាត់យល់ឃើញថា បើសិនជាទុកជនត្រូវចោទឲ្យនៅក្រៅឃុំ នោះវានឹងអាចបង្កឲ្យមានគ្រោះថ្នាក់ដល់សាក្សី ឬ បង្កអោយមានភាពស្មុគស្មាញដល់នីតិវិធីនៃកិច្ចស៊ើបសួរ ឬ ជនត្រូវចោទអាចរត់គេចខ្លួន ដែលជាហេតុនាំអោយចៅក្រមស៊ើបសួរធ្វើការសម្រេចនៅក្នុង ការឃុំខ្លួនជននោះមួយរយៈជាបណ្តោះអាសន្នសិន ដើម្បីធានាកិច្ចស៊ើបសួររបស់ខ្លួន។ នៅក្នុងករណីដែល ចៅក្រមស៊ើបសួរយល់ឃើញថា វិធានការនៃការឃុំខ្លួនបណ្តោះអាសន្នមិនមានភាពចាំបាច់នោះទេ ដោយហេតុថាប្រភេទនៃបទល្មើសប្រព្រឹត្តដោយជនត្រូវចោទមិនមានភាពស្មុគស្មាញ ហើយមិនប៉ះពាល់ដល់ដំណើរកាលនៃកិច្ចស៊ើបសួររបស់ខ្លួន នោះចៅក្រមស៊ើបសួរអាចសម្រេចដាក់ជននោះឲ្យនៅក្រៅឃុំបានតាមឆន្ទានុសិទ្ធិរបស់ខ្លួន ។

ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ ទៅតាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ ឬ ឃុំខ្លួនតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ហើយចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅឲ្យជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជនត្រូវចោទ បើសិនជាជនត្រូវចោទមានមេធាវីអមផងនោះ មេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួន[122] ។ ចៅក្រមស៊ើបសួរក៏ត្រូវជូនដំណឹងផងដែរ ទៅដល់ព្រះរាជអាជ្ញា ដើម្បីទទួលយោបល់ និងធ្វើការកត់សម្គាល់ផ្សេងៗទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ននោះ[123] ។ ប្រសិនបើចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទ ចៅក្រមស៊ើបសួរត្រូវចេញដីកាចំនួនពីរគឺ: **ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាន្ន** និង ដី**កាបង្គាប់ឲ្យឃុំខ្លួន** ។ ដីកាបង្គាប់ឲ្យឃុំខ្លួន ជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួល និងឲ្យឃុំ

[122] មាត្រា២០៦ កថាខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[123] មាត្រា២០៦ កថាខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

ខ្លួនជនត្រូវចោទ[124] ដែលមានកំណត់នៅក្នុងដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្ន ។ ដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្ន ត្រូវជូនដំណឹងទៅដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ ។

នៅក្នុងករណីដែលមានបណ្ដឹងសុំឲ្យឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ន តាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវចេញក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ថាតើសម្រេចឃុំ ឬ មិនឃុំខ្លួនជនត្រូវចោទ ។ បើសិនជាចៅក្រមស៊ើបសួរមិនព្រមធ្វើតាមការសុំឃុំរបស់ព្រះរាជអាជ្ញាទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាមួយហៅថា ដីកាសម្រេចមិនឃុំខ្លួនជនត្រូវចោទ ដោយមិនចាំបាច់មានសំអាងហេតុនោះទេ[125] ព្រោះជាគោលការណ៍ជនត្រូវចោទត្រូវតែមានសេរីភាព[126] ។ បើសិនជាចៅក្រមស៊ើបសួរមិនសម្រេចនៅក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ តាមដីកាសន្និដ្ឋានឲ្យឃុំខ្លួនរបស់ព្រះរាជអាជ្ញាទេ នោះព្រះរាជអាជ្ញាអាចធ្វើពាក្យប្ដឹងទៅសភាស៊ើបសួរ ដែលនឹងសម្រេចជំនួស ចៅក្រមស៊ើបសួរ[127] ។ បើសិនជាចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទ តាមរយៈដីកាសន្និដ្ឋានឲ្យឃុំខ្លួនបណ្ដោះអាសន្ន ចៅក្រមស៊ើបសួរត្រូវចេញដីកាដោយមានសំអាងហេតុ ហើយជូនដំណឹងទៅព្រះរាជអាជ្ញា និងជនត្រូវចោទ[128] ។

ការសម្រេចឃុំខ្លួនជនត្រូវចោទ ត្រូវតែមានសំអាងហេតុដូចមានកំណត់នៅក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៅក្នុងដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្ននូវមូលហេតុដែលនាំឲ្យ ឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ន[129] មានដូចជា ៖

១. ដើម្បីបញ្ចប់បទល្មើស និងបង្ការបទល្មើសកុំឲ្យកើតជាថ្មី ។

២. ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬ ជនរងគ្រោះ ឬ ដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត ។

៣. ដើម្បីរក្សាភស្តុតាង ឬ តម្រុយជាសម្ភារៈ ។

៤. ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី ។

៥. ដើម្បីការពារសន្តិសុខដល់ជនត្រូវចោទ ។

៦. ដើម្បីធានារក្សាសណ្ដាប់ធ្នាប់សាធារណៈ និងបង្ការកុំឲ្យមានភាពច្របូកច្របល់ ដែលបណ្ដាលមក

[124] នីតិវិធីព្រហ្មទណ្ឌ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត,២០១៣-២០១៤, ទំព័រ ៣៨

[125] មាត្រា២០៧ កថាខណ្ឌ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[126] មាត្រា២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[127] មាត្រា២០៧ កថាខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[128] មាត្រា២០៦ កថាខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[129] ការឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងដំណាក់កាលស៊ើបសួរ, កើត រិទ្ធ ទំព័រ២

ពីបទល្មើស ។[130]

### ៣.១.២. លក្ខខ័ណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន

#### ៣.១.២.១. គោលការណ៍នៃការឃុំខ្លួនបណ្តោះអាសន្ន

ក្រមនីតិវិធីព្រហ្មទណ្ឌ ក៏គោរពនូវគោលការណ៍សេរីភាពរបស់បុគ្គលឯកជន ដូចមានចែង នៅក្នុងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា[131] ដែលបុគ្គលគ្រប់រូបត្រូវតែមានសេរីភាព មិនឲ្យមានការរំលោភបំពានលើរូបរាងកាយរបស់ខ្លួនតាមគ្រប់រូបភាព ជាពិសេសបុគ្គលនោះមិនត្រូវទទួលរងនូវការចាប់ ឬ ឃុំខ្លួន ដោយផ្ទុយពីបញ្ញត្តិច្បាប់នោះឡើយ ។ ហេតុនេះហើយបានជា ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ថា បើសិនជាវិធានការពិសេសតម្រូវ ជនត្រូវចោទអាចត្រូវបានឃុំខ្លួនជាបណ្តោះអាសន្នសិនបាន នៅក្នុងតែលក្ខខណ្ឌដែលបានចែងនៅក្នុងច្បាប់តែប៉ុណ្ណោះ[132] ។ ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ការចោទប្រកាន់ ការចាប់ ឬ ការឃុំខ្លួន ដែលធ្វើឡើងមិនស្របទៅតាមបទបញ្ញត្តិច្បាប់ ត្រូវតែទទួលទោសនៅចំពោះមុខច្បាប់[133] ចំពោះសកម្មភាពដែលខ្លួនបានប្រព្រឹត្ត[134] ។

#### ៣.១.២.២. ករណីនៃការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្នដោយចៅក្រមស៊ើបសួរ អាចអនុវត្តបានតែចំពោះជនត្រូវចោទដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដែលច្បាប់បានកំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ១ (មួយ) ឆ្នាំ[135] ហេតុនេះការឃុំខ្លួនបណ្តោះអាសន្នដោយចៅក្រមស៊ើបសួរ នឹងមិនត្រូវយកមកអនុវត្តចំពោះបទលហុ ក៏ដូចជាមិនត្រូវអនុវត្តទៅលើជនត្រូវចោទដែលប្រព្រឹត្តបទល្មើសដែលត្រូវផ្តន្ទាទោសក្រោម ១ (មួយ) ឆ្នាំឡើយ ។

ការឃុំខ្លួនបណ្តោះអាសន្នក៏អាចធ្វើឡើងចំពោះ បុគ្គលទាំងឡាយណាដែលមានចង្អុលបង្ហាញនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ ដែលបុគ្គលនោះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ ឬ មានតម្រុយច្បាស់លាស់ពិរុទ្ធភាពច្បាស់លាស់ និងស៊ីសង្វាក់គ្នាយ៉ាងខ្លាំងថាបុគ្គលនោះបានចូលរួមប្រព្រឹត្តបទល្មើស ។ ការឃុំខ្លួនបណ្តោះអាសន្នចំពោះបុគ្គលទាំងនេះ អាចធ្វើបានតែចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលច្បាប់បានកំណត់ដាក់ពន្ធនាគារស្មើ ឬលើសពី ១ (មួយ) ឆ្នាំ ។

130 មាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

131 មាត្រា១៥២ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

132 មាត្រា២០៣ វាក្យខ័ណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

133 មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

134 មាត្រា២៤ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

135 មាត្រា២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

មួយវិញទៀត ការឃុំខ្លួនបណ្ដោះអាសន្នក៏អាចយកទៅអនុវត្តទៅលើជនត្រូវចោទដែលចៅក្រមស៊ើបសួរសម្រេចចេញដីកាដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានផងដែរ នៅក្នុងករណីដែលជនត្រូវចោទដែលត្រូវអនុវត្តកាតព្វកិច្ចដែលកំណត់ដោយចៅក្រមស៊ើបសួរនោះ មានចេតនាគេចវេស មិនព្រមអនុវត្តនូវកាតព្វកិច្ចនោះ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចឲ្យឃុំខ្លួនជនត្រូវចោទនោះ ហើយត្រូវជូនដំណឹងទៅដល់ជនត្រូវចោទ និងទទួលការកត់សំគាល់របស់ជននោះ បើសិនជននោះមានមេធាវីអមផងនោះ មេធាវីត្រូវបង្ហាញមធ្យោបាយដើម្បីការពារកូនក្តីរបស់ខ្លួន[136] ។ ចៅក្រមស៊ើបសួរត្រូវចេញដីកាដោយមានសំអាងហេតុ ហើយជូនដំណឹងភ្លាមទៅដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ[137] ហើយការឃុំខ្លួនដែលសម្រេចតាមមាត្រានេះមិនអាចឲ្យលើសពី ៤ (បួន) ខែ ចំណោះនីតិជន និង ២ (ពីរ) ខែ ចំពោះអនីតិជន[138] ។ ដូចនិយាយខាងលើម្តងរួចហើយ ដើម្បីអាចឃុំខ្លួនជនត្រូវចោទបាន ចៅក្រមស៊ើបសួរត្រូវតែចេញ ដីកាបង្គាប់ឲ្យឃុំខ្លួន ដែលជាការបញ្ជាដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ឲ្យទទួល និងឃុំខ្លួនជនត្រូវចោទ[139]ដែលជាកម្មវត្ថុនៃដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្ន ។

ដីកាបង្គាប់ឲ្យឃុំខ្លួនត្រូវតែមានចុះនិទ្ទេសដូចតទៅ ៖

- អត្តសញ្ញាណរបស់ជនត្រូវចោទ
- ប្រភេទនៃបទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា ។[140]

ដីកាបង្គាប់ឲ្យឃុំខ្លួន ត្រូវតែមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។ ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនត្រូវទទួល និងឃុំខ្លួនបុគ្គលដែលមានដីកាបង្គាប់ឲ្យឃុំខ្លួនរហូតទាល់តែបានទទួលដំណឹងអំពីការដោះលែងជនត្រូវចោទឲ្យមានសេរីភាពវិញ[141] តាមរយៈដីកាមួយហៅថា **ដីកាបង្គាប់ឲ្យដោះលែង** ។

[136] មាត្រា២៣០ កថាខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[137] មាត្រា២៣០ កថាខណ្ឌ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[138] មាត្រា២៣០ កថាខណ្ឌ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[139] មាត្រា២២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[140] មាត្រា២២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[141] មាត្រា២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

## ៣.២. ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន

### ៣.២.១. ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះបទឧក្រិដ្ឋ និង បទមជ្ឈិម

នៅក្នុងករណីដែល ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួន ជនត្រូវចោទបណ្ដោះអាសន្ន ការឃុំខ្លួនបណ្ដោះអាសន្ននោះត្រូវតែស្ថិតនៅក្នុងថិរវេលាដែលកំណត់ដោយច្បាប់ ។ ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន នឹងត្រូវបានគិតបញ្ចូលទាំងស្រុងទៅក្នុង ថិរវេលានៃទោសដែលត្រូវបានប្រកាសដោយតុលាការ ឬ ជាយថាហេតុនៃថិរវេលាសរុបនៃទោសត្រូវទទួលរង បន្ទាប់ពីការស្រូបទោសបញ្ចូលគ្នា។[142] ថិរវេលានេះនឹងប្រែប្រួលទៅតាមប្រភេទនៃបទល្មើសដែលចោទប្រកាន់ថា តើបទល្មើសដែលចោទប្រកាន់ជាបទល្មើសឧក្រិដ្ឋ (៣.២.១.១) **ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋ** ឬ បទមជ្ឈឹម (៣.២.១.២) **ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទមជ្ឈឹម** និងអាយុរបស់ជនត្រូវចោទដែលត្រូវឃុំខ្លួនថាតើជនត្រូវចោទនោះជានីតិជន ឬ ជាអនីតិជន[143] ។

#### ៣.២.១.១. ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋ

នៅក្នុងផ្នែកស្ដីពីការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋ យើងនឹងធ្វើការបែងចែកចេញជាការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋចំពោះនីតិជន (ក) **ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋចំពោះនីតិជន** និងការឃុំខ្លួនបណ្ដោះអាសន្នចំពោះអនីតិជន (ខ) **ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋចំពោះអនីតិជន** ។

##### ក. ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋចំពោះនីតិជន

ចំពោះបុគ្គលជានីតិជនដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ការឃុំខ្លួនបណ្ដោះអាសន្នមិនត្រូវលើសពី ៦ (ប្រាំមួយ) ខែបាននោះទេ ។ ប៉ុន្តែ នៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចធ្វើការពន្យាការឃុំខ្លួនបណ្ដោះអាសន្នម្ដងបាន ៦ (ប្រាំមួយ) ខែ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ ។ ចៅក្រមស៊ើបសួរអាចសម្រេចពន្យាការឃុំខ្លួនបណ្ដោះអាសន្នចំបានតែ ២ (ពីរ) ដងគត់ ។[144]

##### ខ. ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋចំពោះអនីតិជន

ចំពោះអនីតិជនដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ យើងនឹងធ្វើការបែងចែកប្រភេទអនីតិជនជា៣ធំៗះ

- អនីតិជនអាយុក្រោម១៤ឆ្នាំ : អនីតិជនដែលមានអាយុក្រោម១៤ (ដប់បួន) ឆ្នាំ មិនអាចជាកម្មវត្ថុនៃការឃុំខ្លួនបណ្ដោះអាសន្ននោះទេ ទាំងបទឧក្រិដ្ឋ និងបទមជ្ឈឹម ។ ចៅក្រមស៊ើបសួរត្រូវតែសម្រេចប្រគល់អនីតិ

[142] មាត្រា៥០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[143] សាស្ត្រាចារ្យ រុន ពុណ្ណរិទ្ធ សៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០១៣ ទំព័រ៣៩

[144] មាត្រា២០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

ជននេះទៅឲ្យឪពុកម្តាយ អ្នកអាណាព្យាបាល ឬ ក្នុងករណីគ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្ន រង់ចាំសេចក្តីសម្រេចចេញពីតុលាការ ។[145]

• អនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ : ការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជនអាយុចាប់ពី១៤ (ដប់បួន)ឆ្នាំ ដល់ក្រោម១៦ (ដប់ប្រាំមួយ)ឆ្នាំ គឺមិនត្រូវលើសពី៤ (បួន) ខែបាននោះទេ ។

• អនីតិជនអាយុចាប់ពី១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម១៨ (ដប់ប្រាំបី) ឆ្នាំ : ការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជនអាយុចាប់ពី១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម១៨ (ដប់ប្រាំបី) ឆ្នាំគឺមិនត្រូវលើសពី៦ (ប្រាំមួយខែ) ខែបាននោះទេ ។

### ៣.២.១.២. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទមជ្ឈឹម

នៅក្នុងផ្នែកស្តីពីការឃុំខ្លួនបណ្តោះអាសន្នក្នុងបទមជ្ឈឹម យើងក៏នឹងធ្វើការបែងចែកចេញជាការឃុំខ្លួនបណ្តោះអាសន្នក្នុងបទមជ្ឈឹមចំពោះនីតិជន **(ក. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទមជ្ឈឹមចំពោះនីតិជន)** និង ការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជន **(ខ. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទមជ្ឈឹមចំពោះអនីតិជន)** ។

#### ក. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទមជ្ឈឹមចំពោះនីតិជន

ចំពោះបុគ្គលជានីតិជនដែលត្រូវបានចោទប្រកាន់ពីបទមជ្ឈឹម ការឃុំខ្លួនបណ្តោះអាសន្នមិនត្រូវលើសពី៤ (បួន) ខែបាននោះទេ ។ ប៉ុន្តែ នៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចធ្វើការពន្យាការឃុំខ្លួនបណ្តោះអាសន្នម្តងគត់មិនឲ្យលើសពី ២ (ពីរ) ខែ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ ។ ចំពោះថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នខាងលើនេះ មិនត្រូវលើសពីពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់នោះទេ ។[146]

#### ខ. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទមជ្ឈឹមចំពោះអនីតិជន

• អនីតិជនអាយុចាប់ពី១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម១៦ (ដប់ប្រាំមួយ) ឆ្នាំ : ការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជនអាយុចាប់ពី១៤ (ដប់បួន)ឆ្នាំ ដល់ក្រោម១៦ (ដប់ប្រាំមួយ)ឆ្នាំ គឺមិនត្រូវលើសពី ២ (ពីរ) ខែបាននោះទេ ។

[145] មាត្រា២១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[146] មាត្រា២០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

• អនីតិជនអាយុចាប់ពី១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម១៨ (ដប់ប្រាំបី) ឆ្នាំ : ការឃុំខ្លួនបណ្តោះអាសន្ន ចំពោះអនីតិជនអាយុចាប់ពី១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម១៨ (ដប់ប្រាំបី) ឆ្នាំ គឺមិនត្រូវលើសពី ៤ (បួន) ខែ បាននោះទេ ។

ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នតាមចំណុចទី១ និង ចំណុចទី២ ខាងលើនេះ មិនត្រូវលើសពីពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ ។[147]

## ៣.២.២. ថិរវេលាចំពោះការឃុំខ្លួនបណ្តោះអាសន្នក្នុងករណីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ

ក្នុងករណីបុគ្គលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋប្រល័យពូជសាសន៍ ឬ បទឧក្រិដ្ឋសង្គ្រាម ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ១ (មួយ) ឆ្នាំបាននោះទេ ។ ប៉ុន្តែ នៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចធ្វើការពន្យាការឃុំខ្លួនបណ្តោះអាសន្នម្តងបាន ១ (មួយ) ឆ្នាំ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ចៅក្រមស៊ើបសួរអាចពន្យាការឃុំខ្លួនបណ្តោះអាសន្នបានតែ២(ពីរ)ដងគត់ ។[148]

ចំពោះការពន្យាពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ចំពោះបទល្មើសខាងលើនេះទាំងបទឧក្រិដ្ឋក៏ដូចជាបទមជ្ឈឹម ចៅក្រមស៊ើបសួរត្រូវតែឲ្យដំណឹងទៅដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជននោះ ។ កាលណាជននោះមានមេធាវីអមនោះ មេធាវីត្រូវបង្ហាញមធ្យោបាយការពារកូនក្តីរបស់ខ្លួន ។ ចៅក្រមស៊ើបសួរមានអំណាចនៅក្នុង ការពន្យាការឃុំខ្លួនបណ្តោះអាសន្ន តាមដីកាមួយដោយមានសំអាងហេតុគឺ **ដីកាសម្រេចពន្យាការឃុំខ្លួនបណ្តោះអាសន្ន** ។ នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរត្រូវយោងទៅតាមបទបញ្ញត្តិនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) នៃក្រមនេះ ។ ដីកានេះត្រូវឲ្យដំណឹងជាបន្ទាន់ដល់ជនត្រូវចោទ ។[149] ការពន្យាការឃុំខ្លួនបណ្តោះអាសន្ន មិនត្រូវយកអនុវត្តចំពោះជនត្រូវចោទដែលជាអនីតិជនបានទេ ។[150]

យើងក៏ត្រូវធ្វើការសម្គាល់ផងដែរថា ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នដោយចៅក្រមស៊ើបសួរអាចអនុវត្តបានចំពោះជនត្រូវចោទដោយយោងតាមបញ្ញត្តិមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌតែប៉ុណ្ណោះ ។ ប៉ុន្តែបើចៅក្រមស៊ើបសួរសម្រេចធ្វើការឃុំជនត្រូវចោទបណ្តោះអាសន្ន តាមបទបញ្ញត្តិនៃមាត្រា២៣០នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលជនត្រូវចោទមានចេតនាគេចវេសពីកាតព្វកិច្ចកំណត់ដោយចៅក្រមស៊ើបសួរតាមដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោម ការត្រួតពិនិត្យតាមផ្លូវតុលាការដូចមានចែងក្នុង មាត្រា២២៦នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

[147] មាត្រា២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧
[148] មាត្រា២១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧
[149] មាត្រា២១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧
[150] ការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងដំណាក់កាលស៊ើបសួរ, កើត រិទ្ធ ទំព័រ ៥

ក្នុងករណីនេះចៅក្រមស៊ើបសួរអាចសម្រេចឲ្យឃុំខ្លួនជនត្រូវចោទនោះ ទោះបីទោសដែលជាប់ពន្ធនាគារដែលទទួលមានថិរវេលាប៉ុន្មានក៏ដោយ ហើយទោះបីជាជនត្រូវចោទត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន អស់រយៈពេលអតិបរមាដែលមានចែងចាប់ពីមាត្រា២០៨ ដល់មាត្រា២១០ មាត្រា២១៣ និងមាត្រា២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌក៏ដោយ។ ការឃុំខ្លួនបណ្ដោះអាសន្នដែលសម្រេចតាមមាត្រានេះមិនត្រូវឲ្យលើសពី ៤ (បួន) ខែ ចំពោះនីតិជន និង ២ (ពីរ) ខែ ចំពោះអនីតិជន ។[151]

## ៣.៣ អំណាចរបស់ចៅក្រមស៊ើបសួរក្រោយពេលសម្រេចឃុំខ្លួនបណ្ដោះអាសន្ន

ចៅក្រមស៊ើបសួរមានតួនាទីយ៉ាងសំខាន់នៅក្នុងការសម្រេចដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ នៅក្នុងករណីដែលជនត្រូវចោទត្រូវបានជាប់ឃុំបណ្ដោះអាសន្ន ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់យ៉ាងជាក់លាក់អំពីនីតិវិធីនៅក្នុងការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំវិញដោយត្រូវអនុវត្តទៅតាមវិធីបីយ៉ាងដូចជា៖ **(៣.៣.១) ការដោះលែងជនត្រូវចោទអោយនៅក្រៅឃុំដោយចៅក្រមស៊ើបសួរ (៣.៣.២) ការដោះលែងជនត្រូវចោទអោយនៅក្រៅឃុំតាមបណ្ដឹងរបស់ព្រះរាជអាជ្ញា និង (៣.៣.៣) ការដោះលែងជនត្រូវចោទអោយនៅក្រៅឃុំតាមពាក្យសុំរបស់ជនត្រូវចោទ។**

### ៣.៣.១ ការដោះលែងជនត្រូវចោទអោយនៅក្រៅឃុំដោយចៅក្រមស៊ើបសួរ

នៅក្នុងករណីដែលចៅក្រមស៊ើបសួរមានបំណងចង់ដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ ចៅក្រមស៊ើបសួរត្រូវចេញដីកាបញ្ជូនឱ្យឆ្លើយ ដល់ព្រះរាជអាជ្ញា ដើម្បីជូនព័ត៌មាន និងសុំយោបល់ ដោយត្រូវភ្ជាប់ជាមួយសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ ទាក់ទិនទៅនឹងបំណងរបស់ចៅក្រមស៊ើបសួរក្នុងការដោះលែងជនត្រូវចោទឱ្យមានសេរីភាពវិញ ។ ក្នុងករណីនេះព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់ជូនចៅក្រមស៊ើបសួរវិញក្នុងរយៈពេលយ៉ាងខ្លីបំផុត បន្ទាប់ពីបានបញ្ជូនសំណុំរឿងជូនព្រះរាជអាជ្ញាពិនិត្យរួចហើយ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេលយ៉ាងយូរបំផុត ៥ ថ្ងៃថាត្រូវដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ ឬ បន្តឃុំខ្លួន។ ជាធម្មតាចៅក្រមស៊ើបសួរត្រូវរង់ចាំទទួលបានយោបល់ពីព្រះរាជអាជ្ញាជាមុនសិន មុនសម្រេចថាដោះលែងជនត្រូវចោទ ប៉ុន្តែប្រសិនជាស្ថិតក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងជនត្រូវចោទបានភ្លាមៗ ដោយចង្អុលបង្ហាញប្រាប់អំពីមូលហេតុនៃភាពបន្ទាន់នេះនៅក្នុងដីកាសម្រេចរបស់ខ្លួន។[152] មូលហេតុនៃការបន្ទាន់នេះអាចជា ជនត្រូវចោទត្រូវបញ្ជូនទៅព្យាបាលនៅក្រៅប្រទេសភ្លាមៗ ដោយមិនអាចរង់ចាំបាន ដោយយោងទៅលើស្ថានភាពជម្ងឺ និងភាពធ្ងន់ធ្ងររបស់ជនត្រូវចោទ ហើយពុំអាចព្យាបាលបាននៅក្នុងប្រទេសជាដើម។[153]

[151] ការឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងដំណាក់កាលស៊ើបសួរ, កើត រិទ្ធ ទំព័រ ៥

[152] មាត្រា២១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[153] នីតិវិធីព្រហ្មទណ្ឌ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, ២០១៣-២០១៤, ទំព័រ៤០

### ៣.២.២ ការដោះលែងជនត្រូវចោទអោយនៅក្រៅឃុំតាមបណ្តឹងរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាអាចសុំឱ្យដោះលែងជនត្រូវចោទបានគ្រប់ពេលវេលា ។ ក្រោយមានការស្នើសុំឱ្យដោះលែងពីព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ថាព្រមដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ ឬ មិនព្រមដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ។ ការសម្រេចរបស់ចៅក្រមស៊ើបសួរអាចជា ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ ឬ ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំ។ ប្រសិនដីកានោះជាដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំ ដីកានោះត្រូវតែមានសំអាងហេតុច្បាស់លាស់។ ក្នុងករណីដែលរយៈពេល ៥ (ប្រាំ) ថ្ងៃបានកន្លងផុត ហើយចៅក្រមស៊ើបសួរពុំបានសម្រេចនោះទេ ព្រះរាជអាជ្ញាអាចប្តឹងទៅសភាស៊ើបសួរ ដើម្បីសម្រេចជំនួសចៅក្រមស៊ើបសួរបាន។[154]

### ៣.៣.៣. ការដោះលែងជនត្រូវចោទអោយនៅក្រៅឃុំ តាមពាក្យសុំរបស់ជនត្រូវចោទ

ក្នុងករណីដែលទទួលបានពាក្យសុំដោះលែងឱ្យនៅក្រៅឃុំពីជនត្រូវចោទ ចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យសុំនោះទៅកាន់ព្រះរាជអាជ្ញាភ្លាម ដើម្បីសុំយោបល់ និងបញ្ជូនសុំណុំរឿងជូនព្រះរាជអាជ្ញាពិនិត្យ។ ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់ក្នុងរយៈពេលខ្លីបំផុតជូនចៅក្រមស៊ើបសួរ ចំណែងឯ ចៅក្រមស៊ើបសួរត្រូវធ្វើការសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីពេលបញ្ជូនសុំណុំរឿងទៅព្រះរាជអាជ្ញា ថាព្រមដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ ឬ មិនព្រមដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ។ ការសម្រេចរបស់ចៅក្រមស៊ើបសួរអាចជា ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ ឬ ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំ។ ប្រសិនដីកានោះជាដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំ ដីកានោះត្រូវតែមានសំអាងហេតុច្បាស់លាស់។ ក្នុងករណីដែលរយៈពេល ៥ (ប្រាំ) ថ្ងៃបានកន្លងផុត ហើយចៅក្រមស៊ើបសួរពុំបានសម្រេចនោះទេ ជនត្រូវចោទអាចធ្វើពាក្យប្តឹងផ្ទាល់ទៅសភាស៊ើបសួរ ដើម្បីសម្រេចជំនួសចៅក្រមស៊ើបសួរបាន។

ប្រសិនបើចៅក្រមស៊ើបសួរបានចេញ ដីកាសម្រេចមិនព្រមដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំម្តងរួចហើយនោះ ជនត្រូវចោទអាចដាក់ពាក្យសុំឱ្យដោះលែងសារជាថ្មីម្តងទៀត ក្នុងរយៈពេល ១ (មួយ) ខែ បន្ទាប់ពីមានសេចក្តីសម្រេចបដិសេធពាក្យសុំលើកមុន។ ចៅក្រមស៊ើបសួរ ឬ សភាស៊ើបសួរត្រូវសម្រេចលើពាក្យសុំនេះក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃបន្ទាប់ពីបានទទួលពាក្យសុំ។[155]

សរុបមក បើសិនជាចៅក្រមស៊ើបសួរសម្រេចដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ ទោះតាមបំណងចៅក្រមស៊ើបផ្ទាល់ តាមបណ្តឹងរបស់ព្រះរាជអាជ្ញា និងតាមបណ្តឹងរបស់ជនត្រូវចោទក៏ដោយ ចៅក្រមស៊ើបសួរ

---

[154] មាត្រា២១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[155] មាត្រា២១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

ត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន។ ប៉ុន្តែប្រសិន ចៅក្រមស៊ើបសួរចេញដីកាមិនព្រមដោះលែងឱ្យនៅក្រៅឃុំវិញ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។[156]

[156] មាត្រា២១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

# ជំពូកទី៤
# អំណាចនៅក្នុងការបិទការស៊ើបសួរតាមដីកាដំណោះស្រាយ

## ៤.១. នីតិវិធីនៃការបិទការស៊ើបសួរ

### ៤.១.១. សញ្ញាណទូទៅនៃការបិទការស៊ើបសួរ

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នៅពេលដែលសំណុំរឿងបានមកដល់ដំណាក់កាលចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរមានអំណាចយ៉ាងពេញលេញក្នុងការស៊ើបសួរទាំងការស៊ើបសួរដាក់បន្ទុក ឬ ដោះបន្ទុកជនត្រូវចោទ ដើម្បីបង្ហាញឲ្យឃើញពីអត្ថិភាព ឬ នត្ថិភាពនៃពិរុទ្ធភាពរបស់ជនត្រូវចោទ ។[157] ចំពោះកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ ច្បាប់ពុំបានកំណត់ចិរវេលាដែលចៅក្រមស៊ើបសួរត្រូវតែសម្រេចធ្វើការបិទការស៊ើបសួរ ហើយក៏មិនមែនមានន័យថាចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរដោយមិនគិតពីចិរវេលានោះដែរ ។ ចៅក្រមស៊ើបសួរត្រូវតែធ្វើការបិទការស៊ើបសួរ ក្នុងរយៈពេលមួយដែលមិនយូរពេក ឬ រហ័សពេកក្នុងការប្រមូលភស្តុតាងដែលមានប្រយោជន៍បង្ហាញពីភាពមានទោស ឬ ភាពគ្មានទោសរបស់ជនត្រូវចោទ ។ បើសិនជាចៅក្រមស៊ើបសួរយល់ឃើញថា ភស្តុតាងមានគ្រប់គ្រាន់ហើយ ដោយមិនចាំបាច់ធ្វើការស្រាវជ្រាវបន្ថែមទៀតនោះទេ ចៅក្រមស៊ើបសួរមានឆន្ទានុសិទ្ធយ៉ាងពេញលេញក្នុងការសម្រេចចិត្តបិទការស៊ើបសួរ តែបើសិនជាចៅក្រមស៊ើបសួរយល់ថា មិនទាន់មានភស្តុតាងគ្រប់គ្រាន់ក្នុងការបិទការស៊ើបសួរទេ ចៅក្រមស៊ើបសួរនឹងបន្តកិច្ចស៊ើបសួរនោះទៅតាមករណីចាំបាច់ ។

ទោះបីជាចិរវេលានៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ពុំបានកំណត់រយៈពេលដែលចៅក្រមនោះត្រូវបិទការស៊ើបសួរក៏ដោយ ការស៊ើបសួរមិនត្រូវឲ្យលើសពីចិរវេលានៃការឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ន ដែលតាមរយៈការឃុំខ្លួនបណ្ដោះអាសន្ននេះបានកំណត់ឲ្យ ចៅក្រមស៊ើបសួរនោះត្រូវតែ បំពេញកិច្ចស៊ើបសួរឲ្យបានឆាប់ដើម្បីកុំឲ្យកិច្ចស៊ើបសួរនោះលើសរយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន ។ ការដាក់កំហិតនេះ ក៏អាចជាសម្ពាធដែលជម្រុញឲ្យ ចៅក្រមស៊ើបសួរត្រូវតែសកម្មនៅក្នុងសំណុំរឿងនោះ ដោយពុំត្រូវទុកសំណុំរឿងឲ្យមានភាពអសកម្មយូរពេក ដែលនាំឲ្យប៉ះពាល់ទៅដល់ គោលការណ៍យុត្តិធម៌ និងស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយចៅក្រមនោះត្រូវតែយកចិត្តទុកដាក់ និងប្រុងប្រយ័ត្នលើកិច្ចស៊ើបសួររបស់ខ្លួន។

ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចក្នុងការសម្រេចបិទ ឬ បន្តការស៊ើបសួរ ប៉ុន្តែការសម្រេចបិទ ឬ បន្តនោះ មិនត្រូវអូសបន្លាយពេលវេលានៃការស៊ើបសួរដែល ជះផលអវិជ្ជមាន និងដំណើរការល្អនៃ កិច្ចស៊ើបសួរបានឡើយ។ ក្រមនីតិវិធីព្រហ្មទណ្ឌក៏បានផ្ដល់សិទ្ធិឲ្យជនត្រូវចោទ និង ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការដាក់ពាក្យសុំ

[157] មាត្រា១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

ទៅចៅក្រមស៊ើបសួរដើម្បីឲ្យចៅក្រមស៊ើបសួរ បំពេញកិច្ចស៊ើបសួរនោះឲ្យបានឆាប់រហ័ស ឬ បិទការស៊ើបសួរតែម្តង ។[158] ក្រោយពីការស៊ើបសួរត្រូវបានបើកតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដោយតំណាងអយ្យការ បើសិនជាចៅក្រមស៊ើបសួរបានបំពេញកិច្ចស៊ើបសួររបស់ខ្លួនផុតរយៈពេល១ឆ្នាំ គិតចាប់ពីថ្ងៃចោទប្រកាន់[159] ជនត្រូវចោទ និង ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិដាក់ពាក្យសុំទៅចៅក្រមស៊ើបសួរដើម្បីសុំឲ្យចៅក្រមស៊ើបសួរបិទការស៊ើបសួរ ។ ចៅក្រមស៊ើបសួរត្រូវតែសម្រេចចំពោះពាក្យសុំនោះ ក្នុងរយៈពេល១ខែ ក្រោយពីជនត្រូវចោទ និង ដើមបណ្តឹងរដ្ឋប្បវេណីដាក់ពាក្យសុំបិទសំណុំរឿងនោះ ។ បើសិនជាចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល១ខែ ក្រោយមានការដាក់ពាក្យសុំទេ ជនត្រូវចោទ និង ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងទៅប្រធានសភាស៊ើបសួរ ដែលនឹងធ្វើអធិបញ្ញាដល់ចៅក្រមស៊ើបសួរឲ្យសម្រេចចំពោះពាក្យសុំនោះ ។ ទោះបីជាច្បាប់តាមរយៈមាត្រា២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់សិទ្ធិឲ្យទៅជនត្រូវចោទ និង ដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ក្នុងការអនុវត្តជាក់ស្តែងកម្រមានការប្រើប្រាស់សិទ្ធិអំណាចតាមមាត្រានេះណាស់ ។ សំណុំរឿងព្រហ្មទណ្ឌខ្លះ ចៅក្រមស៊ើបសួរបានធ្វើការស៊ើបសួរលើសពី១ឆ្នាំទៅទៀត តែពុំមានការប្តឹងមកចៅក្រមស៊ើបសួរដោយជនត្រូវចោទ និង ដើមបណ្តឹងរដ្ឋប្បវេណីឲ្យបិទការស៊ើបសួរនោះទេ ។

បន្ថែមពីបណ្តឹងសុំបិទសំណុំរឿងដោយជនត្រូវចោទ ក៏ដូចជាដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរខ្លួនឯងក៏អាចសម្រេចដោយឆន្ទានុសិទ្ធិដើម្បីធ្វើការបិទការស៊ើបសួរ នៅពេលដែលខ្លួនយល់ឃើញថាការស៊ើបសួរទៅលើសំណុំរឿងដែលខ្លួនទទួលបន្ទុក មានភស្តុតាងគ្រប់គ្រាន់ គ្រប់ជ្រុងជ្រោយ ហើយកិច្ចនីតិវិធីបានបំពេញទៅតាមច្បាប់រួចរាល់ នោះចៅក្រមស៊ើបសួរនឹងធ្វើការបិទការស៊ើបសួរ ហើយធ្វើការជូនដំណឹងអំពីការបិទការស៊ើបសួរទៅដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី[160] ។ ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចនៅក្នុងការបិទការស៊ើបសួរ នៅពេលដែលកិច្ចនីតិវិធីនោះបានចប់ទាំងស្រុងដោយមានភស្តុតាងត្រូវបានវាយតម្លៃថា មានលក្ខណៈគ្រប់គ្រាន់ហើយ ។

### ៤.១.២ លក្ខខណ្ឌដើម្បីបិទការស៊ើបសួរ

ជាការពិតណាស់ ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចយ៉ាងពេញលេញក្នុងការសម្រេចថាបន្ត ឬ បិទការស៊ើបសួរ ប៉ុន្តែចៅក្រមស៊ើបសួរក៏មិនត្រូវបិទបញ្ចប់ការស៊ើបសួរទាំងមិនមានភស្តុតាងគ្រប់គ្រាន់ ឬ កិច្ចស៊ើបសួរពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ ហើយធ្វើការបិទការស៊ើបសួរទាំងប្រថុយប្រថាននោះទេ ដែលនាំឲ្យមាន

[158] មាត្រា២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[159] ការចោទប្រកាន់នេះ ត្រូវគិតចាប់ពីពេលដែលជនសង្ស័យត្រូវបានតំណាងអយ្យការចោទប្រកាន់ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ អនុលោមតាមមាត្រា៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[160] មាត្រា២៤៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

ការប៉ះពាល់ទៅដល់យុត្តិធម៌របស់ភាគី និងដំណើរការល្អនៃកិច្ចស៊ើបសួររបស់ខ្លួនដែរ ។ ហេតុនេះហើយ ចៅក្រមស៊ើបសួរអាចសម្រេចបិទការស៊ើបសួរ នៅក្នុងករណីដែលគាត់យល់ឃើញថា កិច្ចនីតិវិធីនៃការស៊ើបសួរបានបំពេញរួចរាល់ (**៤.១.២.១ កិច្ចនីតិវិធីត្រូវបំពេញ** ) និង ភស្តុតាងដែលប្រមូលបានមានភាពគ្រប់គ្រាន់ និងពេញលេញ (**៤.១.២.២ ភាពពេញលេញនៃការប្រមូលភស្តុតាង** ) ។

### ៤.១.២.១. កិច្ចនីតិវិធីត្រូវបំពេញ

ចៅក្រមស៊ើបសួរត្រូវតែបំពេញកិច្ចស៊ើបសួរនេះអោយបានគ្រប់គ្រាប់ និងទៅតាមបទបញ្ញត្តិច្បាប់ មុនពេលខ្លួនសម្រេចបិទការស៊ើបសួរ ។ នៅក្នុងសំណុំរឿងខ្លះ ចៅក្រមស៊ើបសួរចាំបាច់ត្រូវចេញដីកាចាត់ឲ្យស៊ើបសួរជំនួស នៅពេលដែលជនត្រូវចោទគ្មានសាវតាជាតិគ្រប់គ្រាន់ ក្នុងការផ្តល់សិទ្ធិឲ្យអាជ្ញាធរមានសមត្ថកិច្ចបំពេញកិច្ចស៊ើបសួរនេះជំនួសខ្លួន ដើម្បីធ្វើការស្វែងរកសាវតាជាតិលើជនត្រូវចោទ ឬករណីដែលជនត្រូវចោទនោះមានសាវតាជាតិគ្រប់គ្រាន់ហើយ តែជននោះបានរត់គេចខ្លួន ពេលនោះចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជននោះតែម្តង ។ ក៏ប៉ុន្តែមានករណីមួយចំនួន ដែលចៅក្រមស៊ើបសួរមិនចាំបាច់ប្រើប្រាស់វិធានការទាំងអស់នេះនោះទេ ដោយហេតុថាជនត្រូវចោទ បានចូលបំភ្លឺនៅគ្រប់ដំណាក់កាលនៃនីតិវិធីរបស់តុលាការ ។ បើទោះបីជាចៅក្រមស៊ើបសួរបានធ្វើការស្រាវជ្រាវសាវតាជាតិរបស់ជនត្រូវចោទយ៉ាងណាក៏ដោយ តែនៅតែរកមិនឃើញ ឬជននោះបានរត់គេចខ្លួនបាត់ ហើយចៅក្រមស៊ើបសួរបានចេញដីកាបង្គាប់ឲ្យចាប់ខ្លួន ហើយនៅតែមិនអាចចាប់បានទៀត ចៅក្រមស៊ើបសួរនឹងសម្រេចបិទការស៊ើបសួរតាមរយៈដីកាដំណោះស្រាយ ដែលអាចជាដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់[161] ហើយត្រូវជូនដំណឹងទៅអោយភាគីដែលពាក់ព័ន្ធ ។

### ៤.១.២.២. ភាពពេញលេញនៃការប្រមូលភស្តុតាង

ដូចបាននិយាយខាងដើមរួចមកហើយថា ចៅក្រមស៊ើបសួរមានកាតព្វកិច្ចស៊ើបសួរទាំងដាក់បន្ទុក ក៏ដូចជាដោះបន្ទុកដើម្បីបង្ហាញពីអត្ថិភាព ឬ នត្ថិភាពពិរុទ្ធភាពរបស់ជនត្រូវចោទតាមរយៈភស្តុតាងទាំងអស់ដែលមានប្រយោជន៍សម្រាប់បង្ហាញឲ្យឃើញពីការពិត ។ បើសិនជាចៅក្រមស៊ើបសួរខ្លួនឯងយល់ឃើញថា កិច្ចស៊ើបសួរដើម្បីប្រមូលនូវភស្តុតាងមានលក្ខណៈគ្រប់គ្រាន់ និងគ្រប់ជ្រុងជ្រោយ ហើយចំពោះសំណុំរឿងដែលខ្លួនមានសមត្ថកិច្ចបំពេញកិច្ចស៊ើបសួរនោះ ចៅក្រមស៊ើបសួរនឹងសម្រេចធ្វើ ការបិទការស៊ើបសួរដោយមិនអោយអូស

[161] មាត្រា២៤៧ កថាខ័ណ្ឌទី១, នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

បន្ទាយនីតិវិធីឡើយ ដើម្បីគោរពគោលការណ៍យុត្តិធម៌ និងភាពឆាប់រហ័សនៃសំណុំរឿងហើយសំណុំរឿងនឹងត្រូវបញ្ជូនបន្តទៅឲ្យចៅក្រមជំនុំជម្រះ[162]ដើម្បីសម្រេច និងផ្តន្ទាទោសជនជាប់ចោទនោះទៅតាមច្បាប់កំណត់[163] ។

**៤.១.៣. ការជូនដំណឹងស្តីពីការបិទការស៊ើបសួរ**

កាលណាចៅក្រមស៊ើបសួរសម្រេចបិទការស៊ើបសួរតាមដីកាដំណោះស្រាយ ដោយមានភស្តុតាងពេញលេញ និងបានបំពេញកិច្ចស៊ើបសួរគ្រប់ជ្រុងជ្រោយរួចហើយ ចៅក្រមស៊ើបសួរត្រូវតែជូនដំណឹងស្តីពីការបិទការស៊ើបសួរទៅដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី ។ នៅក្នុងការអនុវត្តជាក់ស្តែងយើងឃើញថា ចៅក្រមស៊ើបសួរជូនដំណឹងទៅព្រះរាជអាជ្ញានៅពេលដែលខ្លួនបានសម្រេចបិទការស៊ើបសួរតាមលិខិតមួយហៅថា **លិខិតជូនដំណឹងស្តីពីការបិទការស៊ើបសួរ** ពោលគឺចៅក្រមពុំធ្វើការជូនដំណឹងអំពីការបិទការស៊ើបសួរនោះដោយផ្ទាល់មាត់ ឬ តាមសារអេឡិចត្រូនិច ឬ ទូរស័ព្ទនោះទេ ។ សំណុំរឿងត្រូវតែបញ្ជូនទៅឲ្យព្រះរាជអាជ្ញាពិនិត្យនៅក្នុងរយៈពេល២ថ្ងៃ ក្រោយចៅក្រមស៊ើបសួរសម្រេចបិទការស៊ើបសួរ[164] ។ ការជូនដំណឹងអំពីការបិទការស៊ើបសួរនេះគឺ ដើម្បីឲ្យព្រះរាជអាជ្ញាបានជ្រាបពីការបិទការស៊ើបសួរ ហើយបើសិនជាព្រះរាជអាជ្ញាយល់ឃើញថា ការស៊ើបសួរមិនមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងចង់ទាមទារឲ្យមានការស៊ើបសួរបន្ថែមទៀតនោះព្រះរាជអាជ្ញាក៏មានសិទ្ធិនៅក្នុងការដាក់ពាក្យស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម[165]មកចៅក្រមស៊ើបសួរ ហើយចៅក្រមស៊ើបសួរត្រូវតែសម្រេចនៅក្នុងរយៈពេល១៥ថ្ងៃ[166] ។

បើសិនជាព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរ ចំពោះការបិទការស៊ើបសួរចប់សព្វគ្រប់ហើយ ព្រះរាជអាជ្ញាត្រូវចេញដីកាសន្និដ្ឋានស្ថាពរ ជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ក្នុងចិរវេលា១៥ថ្ងៃ បើសិនជាជនត្រូវចោទនៅក្នុងឃុំ និងក្នុងរយៈពេល១ខែ បើសិនជាជនត្រូវចោទនៅក្រៅឃុំ។ ព្រះរាជអាជ្ញាត្រូវបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ[167] ដោយមានដីកាសន្និដ្ឋានស្ថាពរផង ។ ព្រះរាជអាជ្ញា អាចប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់ ។ ចៅក្រមស៊ើបសួរមិនមានកាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញានោះទេ ចៅក្រមស៊ើបសួរអាចសម្រេចផ្ទុយពីការយល់ឃើញរបស់ព្រះរាជអាជ្ញាបានតាមដីកាដំណោះស្រាយដោយមានសំអាងហេតុ[168] ។

[162] មាត្រា២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧
[163] មាត្រា១២៩ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
[164] មាត្រា២៤៧ កថាខ័ណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧
[165] មាត្រា១៣២ កថាខ័ណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧
[166] មាត្រា១៣២ កថាខ័ណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧
[167] មាត្រា២៤៦ កថាខ័ណ្ឌទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧
[168] ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០១៣

## ៤.២. ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ

### ៤.២.១. ប្រភេទនៃដីកាដំណោះស្រាយ

ដីកាដំណោះស្រាយ គឺជាសេចក្ដីសម្រេចចុងក្រោយរបស់ចៅក្រមស៊ើបសួរដែលមានសមត្ថកិច្ចលើសំណុំរឿងដែលខ្លួនទទួលបន្ទុកនោះ ថាតើគាត់សម្រេចបញ្ជូនជនត្រូវចោទទៅតុលាការជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់ចំពោះអំពើដែលគេប្រព្រឹត្តនោះ។ ដីកាដំណោះស្រាយអាចជាដីកាដែលបញ្ជូនជនត្រូវចោទទៅចៅក្រមជំនុំជម្រះ ( **៤.២.១.១. ដីកាបញ្ជូនទៅជំនុំជម្រះ** ) ឬ លើកលែងការចោទប្រកាន់លើជនត្រូវចោទ[169] ( **៤.២.១.២. ដីកាលើកលែងការចោទប្រកាន់** ) ។

#### ៤.២.១.១. ដីកាបញ្ជូនទៅជំនុំជម្រះ

ដីកាបញ្ជូនទៅជំនុំជម្រះ គឺជាប្រភេទនៃដីកាមួយរបស់ចៅក្រមស៊ើបសួរក្នុងការបញ្ជូនជនត្រូវចោទទៅចៅក្រមជំនុំជម្រះ ដើម្បីធ្វើការផ្ដន្ទាទោសចំពោះអំពើដែលជនត្រូវចោទនោះបានប្រព្រឹត្ត ។ បើសិនជាចៅក្រមស៊ើបសួរយល់ឃើញថា អំពើដែលបង្កើតជាបទល្មើសនោះជា បទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ ចៅក្រមស៊ើបសួរត្រូវតែសម្រេចបញ្ជូន ជនត្រូវចោទនោះទៅមុខតុលាការជំនុំជម្រះ[170] ដោយត្រូវរៀបរាប់ពីអំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់ ព្រមទាំងមានសំអាងហេតុនៅក្នុងដីកានោះផងដែរ ។

ចៅក្រមស៊ើបសួរមុននឹងសម្រេចចេញ ដីកាបញ្ជូនទៅជំនុំជម្រះ ចាំបាច់ណាស់ត្រូវតែធានាឲ្យបាននូវភាពពេញលេញ និងការបំពេញកិច្ចស៊ើបសួរឲ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីបង្ហាញឲ្យឃើញអំពីពិរុទ្ធភាពរបស់ជនត្រូវចោទ ។ នៅពេលណាដែលចៅក្រមស៊ើបសួរសម្រេចបិទការស៊ើបសួរដោយចេញដីកាបញ្ជូនទៅជំនុំជម្រះ ក៏ប៉ុន្តែបើសិនការបិទការស៊ើបសួរនោះពុំមាន ភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទៅលើ ជនត្រូវចោទក្នុងការបង្ហាញពីភាពមានទោសដោយជម្រះឲ្យអស់នូវមន្ទិលសង្ស័យទេ។ ការបិទការស៊ើបសួរដោយដីកាបញ្ជូនទៅជំនុំជម្រះដោយគ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់នេះ មានលទ្ធភាពធ្វើឲ្យជនត្រូវចោទនោះអាចរួចផុតពី ការទទួលខុសត្រូវខាងបទព្រហ្មទណ្ឌចំពោះអំពើដែលគេបានប្រព្រឹត្ត[171] ។

#### ៤.២.១.២ ដីកាលើកលែងការចោទប្រកាន់

ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចយ៉ាងពេញលេញ នៅក្នុងការសម្រេចឲ្យជនត្រូវចោទត្រូវបានលើកលែងពីបទចោទប្រកាន់ នៅក្នុងករណីដូចជា ៖

១. អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ

២. ជនដែលប្រព្រឹត្តនោះនៅតែគេមិនស្គាល់

---

[169] ច្បាប់ស្ដីពីវិសោធនកម្មមាត្រា២៤៧ កថាខ័ណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[170] ច្បាប់ស្ដីពីវិសោធនកម្មមាត្រា២៤៧ កថាខ័ណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[171] មាត្រា៣៨ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

៣. គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ

៤. ករណីបណ្តឹងអាជ្ញារលត់[172] ។

ចៅក្រមស៊ើបសួរក៏មានសិទ្ធិអំណាចនៅក្នុង ការលើកលែងការចោទប្រកាន់ចំពោះបុគ្គលមួយចំនួនជាជនត្រូវចោទ ដោយហេតុថាចៅក្រមយល់ឃើញថាអំពើរបស់បុគ្គលនោះមិនមាន ការជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស ឬ ការចូលរួមប្រព្រឹត្តបទល្មើស[173] ហើយបន្តការស៊ើបសួរចំពោះអង្គហេតុផ្សេងទៀត ក៏ដូចជាស្វែងរកអត្តសញ្ញាណជនល្មើសបន្តទៀតបាន ។

**៤.២.២. លក្ខណៈរួមនៃដីកាដំណោះស្រាយ**

បើយើងនិយាយអំពីលក្ខណៈរួមនៃដីកាដំណោះស្រាយ យើងនឹងពិនិត្យឃើញថាដីកាដំណោះស្រាយមានលក្ខណៈរួមសំខាន់ៗចំនួន២ដែលយើងអាចសន្និដ្ឋាន ៖

១. នៅពេលដែលចៅក្រមស៊ើបសួរសម្រេចចេញ ដីកាដំណោះស្រាយ គឺចៅក្រមស៊ើបសួរពុំមានចងកាតព្វកិច្ចដោយដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញានោះទេ មានន័យថាចៅក្រមស៊ើបសួរមានសិទ្ធិអំណាចក្នុងការចេញដីកាដំណោះស្រាយទៅតាមការយល់ឃើញរបស់ខ្លួន ថាតើគួរចេញដីកាដំណោះស្រាយនេះដូច ឬផ្ទុយទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា ។ ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា មិនទាមទារដាច់ខាត ឬ ដាក់កាតព្វកិច្ចឲ្យចៅក្រមស៊ើបសួរត្រូវតែចេញ ដីកាដំណោះស្រាយឲ្យដូចទៅនឹងដីកាសន្និដ្ឋានស្ថាពរនោះទេ ។[174]

២. ការបិទការស៊ើបសួរតាមរយៈ ដីកាដំណោះស្រាយ នាំឲ្យចៅក្រមស៊ើបសួរដែលមានសមត្ថកិច្ចទៅលើសំណុំរឿងដែលខ្លួនទទួលបន្ទុកនោះ ត្រូវបានបិទបញ្ចប់ ហើយសំណុំរឿងនឹងត្រូវបានបញ្ជូនទៅចៅក្រមផ្សេងទៀតនៅក្នុងដំណាក់កាលជំនុំជម្រះ ។ ចៅក្រមស៊ើបសួរដែលបានបំពេញកិច្ចស៊ើបសួរលើសំណុំរឿងនោះ នឹងមិនអាចចូលរួមជំនុំជម្រះលើរឿងក្តីដែលខ្លួនបានស៊ើបសួរហើយចេញសាលក្រម ឬសាលដីកាក្នុងឋានៈចៅក្រមជំនុំជម្រះបានឡើយ ។ មុខងារធ្វើបណ្តឹងអាជ្ញា មុខងារស៊ើបសួរ និងមុខងារជំនុំជម្រះ ត្រូវបែងចែកឲ្យដាច់ពីគ្នា ។ ចៅក្រមណាម្នាក់ដែលបានទទួលបន្ទុកចាត់ការរឿងក្តីក្នុងឋានៈជាតំណាងអយ្យការ ឬ ចៅក្រមស៊ើបសួររួចហើយ មិនអាចជំនុំជម្រះ ឬចូលរួមជំនុំជម្រះលើរឿងក្តីដែលខ្លួនទទួលចាត់ការនោះទេ បើពុំដូច្នោះទេ សាលក្រម

[172] ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ កថាខ័ណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[173] ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ កថាខ័ណ្ឌទី៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[174] មាត្រា២៤៧ កថាខ័ណ្ឌទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

ឬ សាលដីកានឹងត្រូវទុកជាមោឃៈ ។[175]

## ៤.៣. អានុភាពគតិយុត្តនៃការបិទការស៊ើបសួរ

ចៅក្រមស៊ើបសួរ នៅពេលដែលសម្រេចបិទបញ្ចប់កិច្ចស៊ើបសួររួចមក ចៅក្រមស៊ើបសួរត្រូវតែបញ្ជូនសំណុំរឿងនោះទៅប្រធានតុលាការជាបន្ទាន់ ដើម្បីកំណត់ពេលសវនាការជំនុំជម្រះ[176] ។ ក៏ប៉ុន្តែបើចៅក្រមស៊ើបសួរសម្រេចលើកលែងការចោទប្រកាន់ ចៅក្រមនោះត្រូវចេញដីកាលើកលែងការចោទប្រកាន់ ។ នៅពេលដែលដីកាដំណោះស្រាយ អាចជាដីកាលើកលែងការចោទប្រកាន់ ឬ ដីកាបញ្ជូនទៅជំនុំជម្រះ បានចូលជាស្ថាពរហើយ ដីកានោះនឹងបង្កើតឲ្យមាននូវអានុភាពគតិយុត្តរួមមាន បញ្ចប់កិច្ចស៊ើបសួរលើសំណុំរឿងនោះ **(៤.៣.១. បញ្ចប់កិច្ចស៊ើបសួរ)**មិនផ្តល់នូវភាពដាច់ខាតនៃការបញ្ចប់នីតិវិធី **(៤.៣.២.ភាពមិនដាច់ខាតនៃការបញ្ចប់នីតិវិធី)** និង មិនអាចជាកម្មវត្ថុនៃការជំទាស់ ( **៤.៣.៣. តម្លៃគតិយុត្តនៃការបញ្ចប់កិច្ចស៊ើបសួរ** ) ។

### ៤.៣.១. បញ្ចប់កិច្ចស៊ើបសួរ

នៅពេលដែលកិច្ចស៊ើបសួរត្រូវបានបិទបញ្ចប់ យុត្តាធិការរបស់ចៅក្រមស៊ើបសួរនៅក្នុងការបំពេញកិច្ចស៊ើបសួរក៏បានបញ្ចប់តាមរយៈដីកាដំណោះស្រាយដែលបានចូលជាស្ថាពរ ។ តាមន័យខាងលើឃើញថា ដីកាដំណោះស្រាយដែលបានចូលជាស្ថាពរប្រៀបបានជាស្ពាន សម្រាប់ដើរឆ្លងពីយុត្តាធិការមួយទៅយុត្តាធិការមួយទៀត ពោលគឺពីយុត្តាធិការស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ ទៅយុត្តាធិការមួយទៀតដែលស្ថិតនៅក្រោមអំណាចរបស់ចៅក្រមជំនុំជម្រះថ្មីមួយទៀតចំពោះសំណុំរឿងដដែល ។

#### ៤.៣.១.១ មិនបញ្ចប់នីតិវិធីស៊ើបសួរ

នៅក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចបិទការស៊ើបសួរ តាមរយៈដីកាដំណោះស្រាយរួមមាន ដីកាលើកលែងការចោទប្រកាន់ ឬ ដីកាបញ្ជូនទៅជំនុំជម្រះ នោះកិច្ចនីតិវិធីស៊ើបសួរនឹងត្រូវបិទបញ្ចប់ទាំងស្រុងដោយស្វ័យប្រវត្តិ ហើយចៅក្រមស៊ើបសួរនោះក៏លែងមាន អំណាចទៅលើសំណុំរឿងដែលគាត់បានបំពេញកិច្ចស៊ើបសួរនោះដែរ នៅពេលដីកាដំណោះស្រាយនោះបានចូលជាស្ថាពរ ។ បើសិនជាចៅក្រមស៊ើបសួរចេញដីកាលើកលែងការចោទប្រកាន់ មានន័យថាចៅក្រមស៊ើបសួរសម្រេចមិនធ្វើការចោទប្រកាន់ហើយជននោះក៏មិនត្រូវបានបញ្ជូនទៅចំពោះមុខចៅក្រមជំនុំជម្រះនោះដែរ ។ ទោះបីចៅក្រមស៊ើបសួរមានភស្តុតាងថ្មី ឬ ចង់ស៊ើបសួរបន្តលើសំណុំរឿងដែលខ្លួនបានបិទការស៊ើបសួរ ក៏ការស៊ើបសួរមិនអាចធ្វើបានដែរ លើកលែងតែចៅក្រមស៊ើបសួរនោះស្នើសុំបើកការស៊ើបសួរថ្មីមួយទៀត[177] តាមគំនិតផ្តួចផ្តើមរបស់ព្រះរាជអាជ្ញា ។ ចៅក្រមជំនុំជម្រះនឹងធ្វើ

[175] មាត្រា៧៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ឆ្នាំ២០១៤

[176] មាត្រា២៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[177] មាត្រា២៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

ការជំនុំជម្រះទៅលើសំណុំរឿងដែលចៅក្រមស៊ើបសួរបញ្ជូនទៅឲ្យ តាមអង្គហេតុ និង បុគ្គលដែលមានចង្អុលបង្ហាញនៅក្នុងដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ[178] ។

ដីកាដំណោះស្រាយ ឬ ដីកាលើកលែងការចោទប្រកាន់ដែលបានចូលជាស្ថាពរហើយ មានអានុភាពនាំឲ្យសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរត្រូវបានកាត់ផ្តាច់ ពោលគឺចៅក្រមស៊ើបសួរនោះលែងមានអំណាចចាត់ការលើសំណុំរឿងក្តីនោះតទៀតហើយ យុត្តាធិការស៊ើបសួរត្រូវបានបញ្ចប់នៅពេលដែលចេញដីកាដំណោះស្រាយនេះតែម្តង លើកលែងតែមានការស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែមដោយតំណាងអយ្យការ ។

**៤.៣.១.២ ការបញ្ចប់វិធាននៃការអនុវត្តភាពឲ្យកិច្ច**

ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ហើយថា នៅពេលដែលចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយ ពេលនោះអានុភាពនៃ ដីកាខាងលើនេះនឹងបញ្ចប់នូវ ការឃុំខ្លួនបណ្តោះអាសន្ន និងការត្រួតពិនិត្យតាមផ្លូវតុលាការ[179] នៅពេលរយៈពេលប្តឹងឧទ្ធរណ៍ចំពោះដីកាខាងលើនេះបានកន្លងផុត[180] ។ បើសិនជាចៅក្រមស៊ើបសួរសម្រេចដោះលែងជនត្រូវចោទដែលជាប់ឃុំបណ្តោះអាសន្ន ជនត្រូវចោទនោះត្រូវរក្សាទុកក្នុងពន្ធនាគារក្នុងរយៈពេលដែលព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍នឹងដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ[181] ។ ជនត្រូវចោទនោះត្រូវតែស្ថិតនៅក្នុងពន្ធនាគារក្នុងអំឡុងពេលនោះបើសិនជាមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា រហូតដល់មានសេចក្តីសម្រេចដោយសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ចំពោះបណ្តឹងរបស់ព្រះរាជអាជ្ញានោះ ។

ប៉ុន្តែតាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរក៏មានសិទ្ធិអំណាចនៅក្នុងការបន្តរក្សាជនត្រូវចោទឲ្យស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន ឬ ការត្រួតពិនិត្យតាមផ្លូវតុលាការ[182] រហូតដល់ពេលជននោះចូលមកបង្ហាញខ្លួននៅចំពោះមុខតុលាការ ។ នៅក្នុងការអនុវត្តជាក់ស្តែង នៅពេលដែលជននោះត្រូវបានចៅក្រមស៊ើបសួរសម្រេចបន្តឲ្យជនត្រូវចោទនៅជាប់ឃុំបណ្តោះអាសន្នបន្តទៀត ចៅក្រមស៊ើបសួរនោះតែងតែចេញដីកាចំនួន២គឺ មួយហៅថា **ដីកាសម្រេចរក្សាជនត្រូវចោទក្នុងឃុំបណ្តោះអាសន្ន** ហើយមួយទៀតគឺ **ដីកាបញ្ជូនទៅជំនុំជម្រះ** ។ នៅក្នុងដីកានោះក៏មានយោងមូលហេតុតាមលក្ខខណ្ឌនៃមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំពោះសេចក្តីសម្រេចដោយឡែកនៃ ដីកាដំណោះស្រាយលែងមានអានុភាពនៅក្នុងរយៈ

---

[178] មាត្រា៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[179] មាត្រា២៤៩ កថាខ័ណ្ឌទី១និងទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[180] មាត្រា២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[181] មាត្រា២៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[182] មាត្រា២៤៩ កថាខ័ណ្ឌទី២និងទី៣, នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

ពេល៤ (បួន) ខែ[183] ដូចគ្នាទៅនឹងវិធានផ្ទៃក្នុងនៃ អ.វ.ត.ក ពាក់ព័ន្ធនឹងសេចក្ដីសម្រេចរក្សាទុកជនត្រូវចោទនៅក្នុងឃុំបណ្ដោះអាសន្ន ឬ រក្សាលក្ខខណ្ឌនៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ[184] ។

**៤.៣.១.៣. សម្រេចទៅលើវត្ថុដែលចាប់យក**

នៅក្នុងដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរ ត្រូវធ្វើការសម្រេចអំពីការប្រគល់សងទៅឲ្យម្ចាស់ដើមវិញនូវវត្ថុដែលប្រគល់សងទៅ ឲ្យម្ចាស់ដើមវិញ[185] នូវវត្ថុដែលចាប់យក បើវត្ថុដែលបានចាប់យកនោះពុំមានប្រយោជន៍សម្រាប់សំដែងការពិត ហើយកម្មសិទ្ធិលើវត្ថុនោះគ្មានការជំទាស់ផងដែរ[186] ។ ចៅក្រមស៊ើបសួរក៏មានសិទ្ធិអំណាចនៅក្នុងប្ដឹងសុំទៅតុលាការព្រហ្មទណ្ឌ ប្រសិនបើចៅក្រមស៊ើបសួរ មានការសង្ស័យថា ឧបករណ៍ សម្ភារៈ មូលនិធិ និង ផលទុន ឬទ្រព្យសម្បត្តិនោះមានការជាប់ទាក់ទងទៅនឹងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ។

ការចេញដីកាដំណោះស្រាយ ក៏ជាលក្ខខណ្ឌមួយដែល ជម្រុញឲ្យចៅក្រមស៊ើបសួរធ្វើការសម្រេចថា តើគួរប្រគល់ ឬ មិនប្រគល់ វត្ថុដែលរឹបអូសនោះទៅឲ្យម្ចាស់ដើមវិញ តែច្បាប់ពុំបានដាក់កាតព្វកិច្ចដល់ចៅក្រមស៊ើបសួរត្រូវតែសម្រេច ឬមិនធ្វើការសម្រេចពាក់ព័ន្ធនឹង ការប្រគល់វត្ថុដែលចាប់យកឲ្យម្ចាស់ដើមវិញនោះទេ ។ ក៏ប៉ុន្តែបើសិនជា ចៅក្រមស៊ើបសួរមិនបានសម្រេចអំពីវត្ថុដែលចាប់យកទៅឲ្យម្ចាស់ដើមវិញ នោះភាគីដែលមានប្រយោជន៍ចំពោះវត្ថុនោះអាចប្ដឹងបន្តទៅ ចៅក្រមជំនុំជម្រះ ដើម្បីសម្រេចចំពោះការប្រគល់វត្ថុនោះ[187]។

**៤.៣.២. ភាពមិនដាច់ខាតនៃការបញ្ចប់នីតិវិធី**

ដូចនិយាយខាងលើរួចមកហើយថា នៅពេលដែលដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរបានចូលជាស្ថាពរ នោះអានុភាពរបស់ដីកានឹងនាំឲ្យបញ្ចប់នូវកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរដោយស្វ័យប្រវត្តិ ក៏ប៉ុន្តែក្រមនីតិវិធីមិនបានផ្ដល់នូវភាពដាច់ខាតនៃការបញ្ចប់នីតិវិធីស៊ើបសួរនោះទេ ពោលគឺការស៊ើបសួរអាចនឹងធ្វើឡើងម្ដងទៀតនៅក្នុងលក្ខខណ្ឌដែលកំណត់ដោយច្បាប់គឺការស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរ ។

**៤.៣.២.១ គ្មានអាជ្ញាអស់ជំនុំ**

មុននឹងនិយាយអំពីភាពគ្មានអាជ្ញាអស់ជំនុំនៃដីកាដំណោះស្រាយ យើងក៏ត្រូវធ្វើការកត់សម្គាល់ផងដែរថា ប្រទេសកម្ពុជាទទួលស្គាល់និងគោរពសិទ្ធិមនុស្សដូចមានចែងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងកាតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស

[183] មាត្រា២៤៩ទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[184] វិធាន៦៨ កថាខណ្ឌទី៣ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញតុលាការកម្ពុជា

[185] មាត្រា២៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[186] មាត្រា១៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[187] មាត្រា៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

សិទ្ធិនារី និងសិទ្ធិកុមារ[188] ។ គោលការណ៍អជ្ញាអស់ជំនុំនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ មានមូលដ្ឋានចេញពីកាតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[189] ដែលប្រទេសកម្ពុជាបានក្លាយជារដ្ឋភាគីនៃកាតិកាសញ្ញានេះនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩២ ។ តាមក្រមនីតិវិធីព្រហ្មទណ្ឌ គោលការណ៍អាជ្ញាអស់ជំនុំ ឬ គោលការណ៍មិនកាត់ទោសពីរដងចំពោះបទល្មើសតែមួយ គឺសំដៅទៅលើកាលៈទេសៈមួយ ដែលជនម្នាក់ដែលត្រូវបានតុលាការសម្រេចឲ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវបានចោទប្រកាន់ទៀតទេចំពោះអំពើដដែលនោះ ទោះបីក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ[190] ។ តាមរយៈនិយមន័យខាងលើនេះយើងឃើញថា អាជ្ញាអស់ជំនុំ អាចអនុវត្តបានតែចំពោះសេចក្តីសម្រេចចុងក្រោយ របស់តុលាការតែប៉ុណ្ណោះ ពោលគឺមិនអាចយកមកអនុវត្តចំពោះដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរទេ បើទោះបីដីកាដំណោះស្រាយនេះបានចូលជាស្ថាពររួចហើយក៏ដោយ ។ លើសពីនេះនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌក៏បានបញ្ជាក់បន្ថែមថា ចំពោះដីកាលើកលែងការចោទប្រកាន់ដែលជាប្រភេទមួយនៃដីកាដំណោះស្រាយគ្មានអាជ្ញាអស់ជំនុំនោះទេ ដោយហេតុថាការបើកការស៊ើបសួរ ថ្មីក្នុងករណីលេចឡើងបន្ទុកថ្មីអាចបើកឡើងបាន បើសិនជាមានគំនិតផ្តួចផ្តើមចេញពីព្រះរាជអាជ្ញា[191] ។ យើងអាចធ្វើការវាយតម្លៃបានថា ដីកាលើកលែងការចោទប្រកាន់ដែលបានចូលជាស្ថាពរ ពុំមានអាជ្ញាអស់ជំនុំនោះទេ ពោលគឺគោលការណ៍អាជ្ញាអស់ជំនុំនេះអាចយកទៅអនុវត្តបានតែ ចំពោះសាលក្រមដែលសម្រេចឲ្យរួចខ្លួនហើយបានចូលជាស្ថាពរតែប៉ុណ្ណោះ ។

**៤.៣.២.២. ការបើកការស៊ើបសួរជាថ្មី**

ក្នុងករណីដែលចៅក្រមស៊ើបសួរចេញដីកាសម្រេចលើកលែងការចោទប្រកាន់ ហើយដីកានោះបានចូលជាស្ថាពរ ការស៊ើបសួរក៏អាចចាប់ផ្តើមបើកឡើងវិញបាននៅពេលដែលមានបន្ទុកថ្មីណាមួយបានលេចឡើង តាមរយៈគំនិតផ្តួចផ្តើមរបស់ព្រះរាជអាជ្ញា ។ ចៅក្រមស៊ើបសួរដែលបានចេញដីកាលើកលែងការចោទប្រកាន់នោះ ពុំមានអំណាចក្នុងការបើកការស៊ើបសួរឡើងវិញបានដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាននោះទេ ដរាបណាគ្មានគំនិតផ្តួចផ្តើមពីព្រះរាជអាជ្ញា ព្រោះការបិទការស៊ើបសួរតាមដីកាដំណោះស្រាយនាំឲ្យចៅក្រមស៊ើបសួរនោះលែងមានសិទ្ធិអំណាចទៅលើសំណុំរឿងដែលខ្លួនបានស៊ើបសួរនោះ ។

ការបើកការស៊ើបសួរដោយចៅក្រមស៊ើបសួរដែលបានចេញដីកាដំណោះស្រាយ មានមធ្យោបាយតែមួយគត់ គឺការស្នើសុំពីព្រះរាជអាជ្ញា ហើយបើសិនជាព្រះរាជអាជ្ញាយល់ថាមិនគួរបើកការស៊ើបសួរជាថ្មីទេ ចៅក្រមស៊ើបសួរ

---

[188] មាត្រា៣១ កថាខណ្ឌទី១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

[189] មាត្រា១៤ កថាខណ្ឌទី៧ នៃកាតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

[190] មាត្រា១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[191] មាត្រា២៥១, នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

ប្រាកដជាមិនអាចស៊ើបសួរលើសំណុំរឿងនោះឡើងវិញនោះទេ យោងតាមមាត្រា២៩១នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ នៅក្នុងករណីដែលព្រះរាជអាជ្ញាយល់ឃើញថា ជនត្រូវចោទដែលត្រូវបានចៅក្រមស៊ើបសួរចេញដីកាលើកលែងការចោទប្រកាន់ ហើយមានលេចចេញបន្ទុកថ្មីមួយឡើង នោះការបើកការស៊ើបសួរជាថ្មីអាចធ្វើបានតាមមាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌដោយព្រះរាជអាជ្ញាត្រូវចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរចំពោះសំណុំរឿងដដែលនោះ។ ហេតុនេះហើយបានជាការបិទការស៊ើបសួរតាមរយៈដីកាដំណោះស្រាយ មិនមានអានុភាពគតិយុត្តិដាច់ខាតនោះទេ ព្រោះការបើកការស៊ើបសួរសារជាថ្មីនៅតែអាចធ្វើបាន តាមគំនិតផ្តួចផ្តើមរបស់តំណាងអយ្យការ ។

### ៤.៣.៣. តម្លៃគតិយុត្តិនៃការបិទបញ្ចប់ការស៊ើបសួរ

ដីកាដំណោះស្រាយដែលបានចូលជាស្ថាពរ ហើយបានបិទបញ្ចប់នីតិវិធីនៃការស៊ើបសួរ មិនអាចក្លាយជាកម្មវត្ថុនៃការប្តឹងជំទាស់បានទៀតនោះទេ ។ ដីកាដំណោះស្រាយនោះ បានកាត់ផ្តាច់កិច្ចនីតិវិធីរបស់ចៅក្រមស៊ើបសួរ ហើយយុត្តាធិការត្រូវធ្លាក់បន្តទៅសមត្ថកិច្ចរបស់ចៅក្រមជំនុំជម្រះវិញម្តង ដែលជាដំណាក់កាលដ៏សំខាន់ក្នុងការប្រកាសទោសចំពោះជនជាប់ចោទ ដែលត្រូវបានបញ្ជូនដោយដីកាដំណោះស្រាយហើយចូលជាស្ថាពរនេះ មកចៅក្រមជំនុំជម្រះ ។

#### ៤.៣.៣.១. ចំណងភាពព្វកិច្ចចៅក្រមជំនុំជម្រះ

ចៅក្រមជំនុំជម្រះត្រូវបានចងសមត្ថកិច្ចដោយដីកាបញ្ជូនរឿងឲ្យស៊ើបសួររបស់ចៅក្រមស៊ើបសួរ ឬ សាលដីកាបញ្ជូនរបស់សភាស៊ើបសួរ[192] មានន័យថាចៅក្រមស៊ើបសួរធ្វើការជំនុំជម្រះទៅលើអង្គហេតុដែលបានបញ្ជូនមកតាមរយៈដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ ហើយការជំនុំជម្រះ មិនអាចយកអង្គហេតុរកឃើញថ្មីដែលបានរកឃើញនៅពេលជំនុំជម្រះនោះឡើយ ។ នៅក្នុងករណីដែលចៅក្រមស៊ើបសួរចេញដីកាបញ្ជូនទៅជំនុំជម្រះ ហើយជាបទឧក្រិដ្ឋដែលត្រូវសម្រេចដោយមានសមាសភាពចៅក្រមចំនួន ៣ ( បី ) រូប តែអង្គហេតុដែលប្តឹងសុំនោះត្រូវបានក្រុមប្រឹក្សាជំនុំជម្រះយល់ថាជាបទមជ្ឈិម ឬ បទលហុ នោះក្រុមប្រឹក្សាជំនុំជម្រះអាចធ្វើការជំនុំជម្រះបាន[193] ។ ប៉ុន្តែបើសិនជាចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងទៅជំនុំជម្រះជាបទមជ្ឈិម ដែលនឹងត្រូវបានជំនុំជម្រះដោយចៅក្រមតែម្នាក់ ហើយគាត់យល់ថាអង្គហេតុនេះបង្កើតបានជាបទឧក្រិដ្ឋ នោះចៅក្រមជំនុំជម្រះ ត្រូវតែបង្វិលសំណុំរឿងជូនព្រះរាជអាជ្ញា ដើម្បីបើកការស៊ើបសួរពាក់ព័ន្ធនឹងអង្គហេតុនោះ[194] ។

លើសពីនេះចៅក្រមជំនុំជម្រះ មិនអាចធ្វើការជំនុំជម្រះទៅលើ បុគ្គលដែលគ្មានចង្អុលបង្ហាញឈ្មោះនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរនោះទេ ព្រោះថាតុលាការអាចធ្វើការជំនុំជម្រះបានតែ ចំពោះបុគ្គលដែលបានបញ្ជូនមក

[192] មាត្រា២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[193] មាត្រា៣៤៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[194] មាត្រា៣៤៨ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

ចំពោះមុខខ្លួនក្នុងឋានៈជាជនជាប់ចោទតែប៉ុណ្ណោះ[195] ។ មួយវិញទៀត បុគ្គលដែលត្រូវបានកោះហៅក្នុងឋានៈជាសាក្សី ហើយតុលាការយល់ឃើញថាគួរតែចោទប្រកាន់ក្នុងឋានៈជាជនដៃដល់ ឬ អ្នកសមគំនិត ជននោះអាចនឹងជំនុំជម្រះបានលុះត្រាតែមានការចោទប្រកាន់ដោយតំណាងអយ្យការជាមុនសិន[196] ។

**៤.៣.៣.២ លុបលាងមោឃភាពនៃកិច្ចនីតិវិធី**

បើយើងនិយាយអំពីអានុភាពនៃដីកាដំណោះស្រាយឃើញថា នៅពេលណាដែលដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរបានចូលជាស្ថាពរ នោះកិច្ចនីតិវិធីដែលត្រូវបំពេញដោយចៅក្រមស៊ើបសួរ នឹងមិនអាចក្លាយជាកម្មវត្ថុនៃការប្តឹងសុំមោឃភាពនៃកិច្ចដែលបានបំពេញចប់សព្វគ្រប់នោះទេ[197] ។ នៅក្នុងន័យនេះ ឃើញថាទោះបីកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរបានធ្វើខុសនីតិវិធីច្បាប់យ៉ាងណាក៏ដោយ ហើយជាមូលហេតុតាមផ្លូវច្បាប់ក្នុងការប្តឹងសុំមោឃភាពបានក៏ដោយ គ្មានការលើកឡើងនូវមោឃភាពដោយភាគីនៅចំពោះមុខចៅក្រមជំនុំជម្រះបាននោះឡើយ បើសិនជាដីកាដំណោះស្រាយនោះបានចូលជាស្ថាពរ ។ ហេតុនេះទោះបីជាកិច្ចស៊ើបសួរដែលត្រូវបំពេញដោយចៅក្រមស៊ើបសួរបានធ្វើខុសនីតិវិធីច្បាប់ ហើយគ្មានការលើកឡើងពីការសុំប្តឹងមោឃភាពចំពោះកិច្ចស៊ើបសួរ នៅពេលដីកាដំណោះស្រាយមិនទាន់ចូលជាស្ថាពរ ពេលនោះកិច្ចស៊ើបសួរដែលបំពេញនោះនឹងត្រូវបានចាត់ទុកថាបានធ្វើត្រឹមត្រូវទៅតាមនីតិវិធីច្បាប់ ។

---

[195] មាត្រា៣៤៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[196] មាត្រា៣៤៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

[197] មាត្រា២៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤, ១០ សីហា ២០០៧

# សេចក្តីសន្និដ្ឋាន

សរុបមកយើងឃើញថាការបំពេញកិច្ចស៊ើបសួរអាចធ្វើឡើងដោយចៅក្រមស៊ើបសួរដោយខ្លួនឯងផ្ទាល់ ឬ ការចេញដីកាចាត់ឲ្យស៊ើបសួរជំនួសនៅក្នុងចិរវេលាមួយជាក់លាក់ទៅចៅក្រមស៊ើបសួរមួយផ្សេងទៀត មន្ត្រីនគរបាលយុត្តិធម៌ ឬ អង្គភាពនគរបាលយុត្តិធម៌ ដើម្បីបំពេញកិច្ចស៊ើបសួរជំនួសខ្លួនក្នុងការស្វែងរកបទល្មើស និង ស្រាវជ្រាវអត្តសញ្ញាណរបស់ជនល្មើសជាដើម ។

មួយវិញទៀត ចៅក្រមស៊ើបសួរក៏មានអំណាចប្រើប្រាស់នូវវិធានការនិរន្តរាយ ដើម្បីធ្វើការចេញបញ្ជាទៅដល់ជនត្រូវចោទឲ្យចូលខ្លួន ឬ ករណីរឹងទទឹងមិនព្រមចូលខ្លួន ត្រូវចេញបញ្ជាឲ្យនាំខ្លួនដោយកងកម្លាំងសាធារណៈ ឬ បុគ្គលនោះបានរត់គេចខ្លួនមិនដឹងស្ថិតនៅទីកន្លែងណា ដើម្បីចូលខ្លួនមកចំពោះមុខខ្លួនដើម្បីធ្វើការសាកសួរពីដំណើររឿងនៃការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ។ បន្ថែមពីលើអំណាចក្នុងការប្រើប្រាស់វិធានការនិរន្តរាយ ចៅក្រមស៊ើបសួរនោះក៏មានអំណាចនៅក្នុងការថ្លឹងថ្លែង ពិចារណា ថាតើគួរឃុំខ្លួនបុគ្គលជនត្រូវចោទបណ្តោះអាសន្ន ឬ សម្រេចមិនឃុំខ្លួន តែជំនួសមកវិញដោយដាក់បុគ្គលនោះឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដោយត្រូវគោរពកាតព្វកិច្ចមួយ ឬ ច្រើន ។ បើសិនជាជម្រើសរបស់ចៅក្រមស៊ើបសួរនោះ គឺការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន ចៅក្រមស៊ើបសួរ ត្រូវគោរពចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នទៅតាមប្រភេទនៃបទល្មើសដែលត្រូវចោទប្រកាន់ ក៏ដូចជាអាយុរបស់បុគ្គលជាជនត្រូវចោទនោះ ។

ចៅក្រមស៊ើបសួរមានអំណាចនៅក្នុងការបិទការស៊ើបសួរតាមរយៈដីកាដំណោះស្រាយ ។ នៅក្នុងករណីដែលចៅក្រមស៊ើបសួរ យល់ឃើញថាខ្លួនបានបំពេញកិច្ចស៊ើបសួរនោះចប់សព្វគ្រប់ហើយ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី ដោយព្រះរាជអាជ្ញាត្រូវបង្វិលសំណុំរឿងនោះមកចៅក្រមស៊ើបសួរវិញដោយភ្ជាប់ជាមួយដីកាសន្និដ្ឋានស្ថាពរ ។ ចៅក្រមស៊ើបសួរ ក៏មានអំណាចក្នុងការសម្រេចថាតើលើកលែងការចោទប្រកាន់ឲ្យ ជននោះមានសេរីភាព ឬ បញ្ជូនសំណុំរឿងទៅជំនុំជម្រះ ប៉ុន្តែគាត់មិនមានកាតព្វកិច្ចត្រូវតែគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញានោះទេ ។ លើសពីនេះទៅទៀត ចៅក្រមស៊ើបសួរក៏មានអំណាចក្នុងការសម្រេចអំពីរឿងដោះលែងជនត្រូវចោទឲ្យមានសេរីភាព បើសិនជាជននោះត្រូវបានចៅក្រមស៊ើបសួរចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន នៅពេលណាដែលមានបណ្តឹងពីព្រះរាជអាជ្ញា ឬ បណ្តឹងរបស់ជនត្រូវចោទ ឬ ចៅក្រមស៊ើបសួរខ្លួនឯងផ្ទាល់ ដោយត្រូវជូនដំណឹងនិងបញ្ជូនសំណុំរឿងដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ពាក់ព័ន្ធនឹងការដោះលែងនោះ ។ ចៅក្រមស៊ើបសួរត្រូវតែសម្រេចអំពីការដោះលែងជននោះឲ្យមានសេរីភាពឡើងវិញ ព្រោះបើសិនជាចៅក្រមស៊ើបសួរមិនបានសម្រេចនៅក្នុងអំឡុងពេលដែលកំណត់ដោយច្បាប់ទេនោះព្រះរាជអាជ្ញា ឬ ជនត្រូវចោទ អាចប្តឹងសុំទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ដែលនឹងសម្រេចអំពីការដោះលែងឲ្យនៅក្រៅឃុំនេះ ជំនួសចៅក្រមស៊ើបសួរ។

# អនុសាសន៍

បើទោះបីជាក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អំណាចយ៉ាងទូលំទូលាយទៅដល់ចៅក្រមស៊ើបសួរដើម្បីបំពេញកិច្ចស៊ើបសួរក៏ពិតមែន ក៏យើងសង្កេតឃើញថានៅក្នុងការអនុវត្តជាក់ស្តែងចៅក្រមស៊ើបសួរមិនអាចប្រើអំណាចទាំងអស់ដែលគាត់មានដើម្បីបំពេញកិច្ចស៊ើបសួរឲ្យមានប្រសិទ្ធភាព និងយុត្តិធម៌ទៅដល់ភាគីជា ជនរងគ្រោះបានដូចបំណងនោះទេ ដោយសារភាពអសកម្មមួយចំនួនដែលកើតមានឡើង ។ ហេតុនេះហើយ ដើម្បីអាចឲ្យចៅក្រមស៊ើបសួរប្រើប្រាស់អំណាចទាំងអស់ដែលច្បាប់បានប្រគល់ឲ្យ ក្នុងការបំពេញកិច្ចស៊ើបសួរឲ្យមាន តម្លាភាព ប្រសិទ្ធភាព ក៏ដូចជាយុត្តិធម៌ចំពោះភាគីក្នុងសំណុំរឿងព្រហ្មទណ្ឌ យើងខ្ញុំសូមជូននូវអនុសាសន៍ដែលមានប្រយោជន៍មួយចំនួនដូចខាងក្រោម ៖

**១.** សំណូមពរឲ្យមានការផ្តល់ជាធនធានហិរញ្ញវត្ថុ នៅតាមសាលាដំបូងរាជធានី ខេត្តឲ្យបានគ្រប់គ្រាន់ជាពិសេសចំពោះការបំពេញមុខងារជាចៅក្រមស៊ើបសួរ ព្រោះបើសិនជាពុំមានថវិកាគ្រប់គ្រាន់ក្នុងការចំណាយទេនោះ ចៅក្រមស៊ើបសួរពិតជាមិនអាចអនុវត្តអំណាចពេញលេញដូចមានកំណត់នៅក្នុងច្បាប់បាននោះទេ ។ ជាក់ស្តែងពាក់ព័ន្ធនឹងការចេញដីកាបង្គាប់ឲ្យចាប់ខ្លួនដែលបញ្ជាឲ្យ មន្ត្រីនគរបាលយុត្តិធម៌ចាប់ខ្លួនបុគ្គលដែលជាកម្មវត្ថុនៃដីកា មន្ត្រីនគរបាលយុត្តិធម៌នោះមិនបានយកដីកាទៅអនុវត្តភ្លាមៗដើម្បីចាប់ខ្លួនជនត្រូវចោទនោះទេ តែបែជាមន្ត្រីនគរបាលយុត្តិធម៌រូបនោះទៅសុំសោហ៊ុយពីជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការចុះទៅចាប់ជនត្រូវចោទ ។ បើសិនជាគាត់ទទួលបានសោហ៊ុយខ្លះ នោះគាត់នឹងចាប់បញ្ជូនជននោះភ្លាមទៅតុលាការ តែបើមិនបានសោហ៊ុយខ្លះនោះទេ គាត់មិនចាប់តាមដីកានោះទេ ព្រោះបើសិនជាគាត់មិនចាប់ក៏តុលាការមិនអាចធ្វើអ្វីបាននោះដែរ ។ ហេតុនេះហើយ គប្បីឲ្យមានកញ្ចប់ថវិកាល្មមនឹងអាចអនុវត្តចំពោះបញ្ហានេះ ក្នុងការសម្រេចឲ្យបាននូវដីកាបង្គាប់ឲ្យចាប់ខ្លួន ដើម្បីភាពឆាប់រហ័សនៃនីតិវិធី ក៏ដូចជាយុត្តិធម៌របស់ភាគីនៅក្នុងសំណុំរឿង ។

**២.** សំណូមពរឲ្យចៅក្រមស៊ើបសួរ មុននឹងចេញដីកាដំណោះស្រាយដើម្បីបញ្ចប់ការស៊ើបសួរ ទាមទារឲ្យមានភស្តុតាងឲ្យមានភាពពេញលេញ និង មានលក្ខណៈគ្រប់គ្រាន់ ពោលគឺមិនត្រូវចេញដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ខណៈការស៊ើបសួរចំពោះពិរុទ្ធភាពរបស់ ជនត្រូវចោទនោះ មិនលើសពី វិមតិសង្ស័យរបស់ជនត្រូវចោទមានន័យថា ការស៊ើបសួរត្រូវតែលើសពីវិមតិសង្ស័យ ក៏ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង ចំពោះសំណុំរឿងមួយចំនួន ឃើញថាការស៊ើបសួរនៅមានលក្ខណៈមិនគ្រប់ជ្រុងជ្រោយ ស្រពិចស្រពិលគ្មានសាវតាជាតិជនត្រូវចោទច្បាស់លាស់ តែចៅក្រមស៊ើបសួរនោះនៅតែចេញដីកាដំណោះស្រាយបញ្ចប់ការស៊ើបសួរ ហើយបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ដែលធ្វើឲ្យជនត្រូវចោទមានលទ្ធភាពច្រើន ក្នុងការគេចផុតពីការ

ទទួលខុសត្រូវខាងព្រហ្មទណ្ឌ ព្រោះវិមតិសង្ស័យជាប្រយោជន៍របស់ជនត្រូវចោទជានិច្ច ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

៣. សំណូមពរឲ្យចៅក្រមស៊ើបសួរ ប្រើប្រាស់នូវវិធានការនៃការដកហូតសិទ្ធិសេរីភាពរបស់ជនត្រូវចោទតាមរយៈការឃុំខ្លួនបណ្ដោះអាសន្ន ជាយន្តការចុងក្រោយហើយត្រូវតែអនុវត្តឲ្យបានត្រឹមត្រូវបំផុតដោយយោងតាមគោលការណ៍ដែលធានាដោយរដ្ឋធម្មនុញ្ញគឺ គោលការណ៍សន្មតទុកជាមុននូវភាពគ្មានទោស ឬ ការអាចជំនួសវិធានការមួយទៀតដែល ដកហូតនូវសិទ្ធិសេរីភាពដូចគ្នាតែមាន លក្ខណៈស្រាលជាងការឃុំខ្លួនបណ្ដោះអាសន្ន គឺការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬ វិធានការនៃការដាក់ប្រាក់តម្កល់ និងធានាចំពោះការសម្រេចឲ្យនៅក្រៅឃុំរបស់ចៅក្រមស៊ើបសួរផ្អែកទៅតាមធនធានរបស់បុគ្គលជាជនត្រូវចោទនោះ ។

៤. សំណូមពរឲ្យមានការផ្សព្វផ្សាយឲ្យបានទូលំទូលាយ ទៅដល់ប្រជាពលរដ្ឋខ្មែរទាំងអស់ ឲ្យមានការយល់ដឹងអំពីច្បាប់គោលសំខាន់ៗរួមមាន ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាថាប្រជាពលរដ្ឋមានការយល់ដឹង និងចូលរួមក្នុងការអនុវត្តច្បាប់ឲ្យកាន់តែមានប្រសិទ្ធភាព ។

# ឯកសារយោង

## ១. ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តិ

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ។
- ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ឆ្នាំ២០០៧ ។
- ក្រមព្រហ្មទណ្ឌ, លេខ រស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ឆ្នាំ២០០៩ ។
- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ ១៤៩/០០៣/២០១៤, ០២ កក្កដា ឆ្នាំ២០១៤ ។
- វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា,វិសោធនកម្មលើកទី៨,០៣ សីហា ឆ្នាំ២០១១។
- សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស, ១០ ធ្នូ ១៩៤៨ ។
- កាតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ២៣ មីនា ឆ្នាំ១៩៧៦ ។

## ២. សៀវភៅ និង ស្នាដៃនិពន្ធ

- មេរៀននីតិវិធីព្រហ្មទណ្ឌ, រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ឆ្នាំ២០០៧ ។
- ឯកឧត្តម កើត រិទ្ធ, ការឃុំខ្លួនបណ្តោះអាសន្ននៅដំណាក់កាលស៊ើបសួរ, ឆ្នាំ២០១៤ ។
- លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, ២០១៣-២០១៤, នីតិវិធីព្រហ្មទណ្ឌ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។
- លោក ហម ម៉េងសែ, សមត្ថកិច្ចចៅក្រមស៊ើបអង្កេតឆ្នាំ, ២០១៤ ។
- សេចក្តីពន្យល់ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចំពោះករណីយុត្តិសាស្ត្រអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា និងអន្តរជាតិសម្រាំង ឆ្នាំ២០១៤ ។
- លោកសាស្ត្រាចារ្យ គុប ឈុនហេង, សៀវភៅមេរៀនស្តីពីប្រភេទនៃដីកា និងគំរូដីកានៅក្នុងរឿងព្រហ្មទណ្ឌ, ឆ្នាំ២០១៤

## ៣. ប្រភពផ្សេងៗ

- លោក អៀវ សំណាង, នីតិវិធីព្រហ្មទណ្ឌស្តីពីគម្រូរបមន្តសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ ។

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ


| | |
|---|---|
| **ឧបសម្ព័ន្ធ ១** | ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ |
| **ឧបសម្ព័ន្ធ ២** | ដីកាចាត់ឱ្យស៊ើបសួរជំនួស |
| **ឧបសម្ព័ន្ធ ៣** | ដីកាបង្គាប់ឱ្យចូលខ្លួន |
| **ឧបសម្ព័ន្ធ ៤** | ដីកាបង្គាប់ឱ្យនាំខ្លួន |
| **ឧបសម្ព័ន្ធ ៥** | ដីកាបង្គាប់ឱ្យចាប់ខ្លួន |
| **ឧបសម្ព័ន្ធ ៦** | កំណត់ហេតុស្ដីពីការពិភាក្សាដេញដោលចំពោះមុខ |
| **ឧបសម្ព័ន្ធ ៧** | កំណត់ហេតុស្ដីពីការសួរចម្លើយតទល់ |
| **ឧបសម្ព័ន្ធ ៨** | កំណត់ហេតុស្ដីពីការសួរចម្លើយជនត្រូវចោទ |
| **ឧបសម្ព័ន្ធ ៩** | កំណត់ហេតុស្ដីពីការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី |
| **ឧបសម្ព័ន្ធ ១០** | កំណត់ហេតុស្ដីពីការស្ដាប់ចម្លើយសាក្សី |
| **ឧបសម្ព័ន្ធ ១១** | កំណត់ហេតុស្ដីពីការធ្វើសម្បថ |
| **ឧបសម្ព័ន្ធ ១២** | ដីកាចាត់ឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម |
| **ឧបសម្ព័ន្ធ ១៣** | ដីកាចាត់ឱ្យឆែកឆេរលំនៅឋានជំនួស |
| **ឧបសម្ព័ន្ធ ១៤** | ដីកាសម្រេចប្រគល់វត្ថុដែលចាប់យកឱ្យម្ចាស់គេវិញ |
| **ឧបសម្ព័ន្ធ ១៥** | ដីកាចាត់តាំងអ្នកជំនាញ |
| **ឧបសម្ព័ន្ធ ១៦** | ដីកាបង្គាប់ឱ្យឃុំខ្លួន |
| **ឧបសម្ព័ន្ធ ១៧** | ដីកាបង្គាប់ឱ្យពន្យាពេលឃុំខ្លួនបណ្ដោះអាសន្ន |
| **ឧបសម្ព័ន្ធ ១៨** | ដីកាបង្គាប់ឱ្យដោះលែង |
| **ឧបសម្ព័ន្ធ ១៩** | ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ |
| **ឧបសម្ព័ន្ធ ២០** | ដីកាបញ្ជូនឆ្លើយ |
| **ឧបសម្ព័ន្ធ ២១** | ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការពិនិត្យតាមផ្លូវតុលាការ |
| **ឧបសម្ព័ន្ធ ២២** | ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន |
| **ឧបសម្ព័ន្ធ ២៣** | ដីកាសម្រេចពន្យាពេលឃុំខ្លួនបណ្ដោះអាសន្ន |
| **ឧបសម្ព័ន្ធ ២៤** | ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ |
| **ឧបសម្ព័ន្ធ ២៥** | ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំ |

**ឧបសម្ព័ន្ធ ២៦** លិខិតជូនដំណឹងស្តីពីការបញ្ចប់ការស៊ើបសួរដល់ព្រះរាជអាជ្ញា

**ឧបសម្ព័ន្ធ ២៧** ដីកាសន្និដ្ឋានស្ថាពរ

**ឧបសម្ព័ន្ធ ២៨** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

**ឧបសម្ព័ន្ធ ២៩** ដីកាលើកលែងចោទប្រកាន់

គំរូដីកាប្រព្រឹត្តកម្ម      គំរូបាំងតំណាងអយ្យការ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធ ១

អយ្យការ

អមសាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ: ..............

ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២

លេ.........................អ.យ.

# ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

យើង ៖ តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ របាយការណ៍សំយោគលេខ: ......................... រ.ប.ក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១២ របស់អធិការដ្ឋាននគរបាលខណ្ឌមានជ័យ។

-បានឃើញ មាត្រា ៤៤ និងមាត្រា ១២៤ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

## យល់ឃើញថា

១. ឈ្មោះ សៅ ភេទប្រុស អាយុ១៩ឆ្នាំ (នៅលីវ) ជាតិខ្មែរ មុខរបរកម្មករ ទីកន្លែងកំណើត ភូមិព្រៃប្រង់ ស្រុកបាភ្នំ ខេត្តព្រៃវែង , ទីលំនៅបច្ចុប្បន្ន ផ្ទះជួល ផ្លូវលេខ៣៥៧ ភូមិដើមស្លែង សង្កាត់ច្បារអំពៅ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ សំ សៅ ។- ម្តាយឈ្មោះ ធៀន សុះ ។- , ទោសពីមុនគ្មាន , ជានីតិជន ។

២. ឈ្មោះ សុខ ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន ផ្ទះជួល ផ្លូវលេខ៣៥៧ ភូមិដើមស្លែង សង្កាត់ច្បារអំពៅ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ជានីតិជន។

-បានប្រព្រឹត្តអំពើដូចតទៅ[១] ៖ កាលពីថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១២ វេលាម៉ោងប្រហែល១១និង០០នាទី នៅចំណុច ផ្ទះជួល ផ្លូវលេខ៣៥៧ ភូមិដើមស្លែង សង្កាត់ច្បារអំពៅ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ មានឈ្មោះ សែម ហៅ សេត (ជនរងគ្រោះ) និងឈ្មោះ សៅ និងឈ្មោះ សុខ (ជនសង្ស័យ) ព្រមទាំងមិត្តភក្តិពីរនាក់ទៀត នាំគ្នាផឹកស៊ី ពេលនោះជនរងគ្រោះ និងជនសង្ស័យឈ្មោះ សុខ មានទំនាស់ពាក្យសំដីគ្នាហើយជនសង្ស័យឈ្មោះ សៅ បានដាល់ទៅលើជនរងគ្រោះចំនួន០៤ដៃបណ្តាលឱ្យមានរបួសភ្នែកខាងឆ្វេងហើមប៉ោង ហើយជនសង្ស័យឈ្មោះ សុខ បានយកដំបងឈើជ្រុងវាយទៅលើជនរងគ្រោះចំក្បាលពីក្រោយ បណ្តាលឱ្យរបួស ហើយទំលាក់ឈើជ្រុងចោលរួចនាំគ្នារត់គេចខ្លួន ចំណែកជនរងគ្រោះបានក្រុមគ្រួសារបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យ។ លុះដល់វេលាម៉ោង ១៦និង៣០នាទីថ្ងៃខែឆ្នាំដដែល ក្រុមគ្រួសារជនរងគ្រោះបានឃើញជនសង្ស័យឈ្មោះ សៅ ក៏ឃាត់ខ្លួនយកទៅប្រគល់ ឱ្យនគរបាលប៉ុស្តិ៍ច្បារអំពៅ២តែម្តង ចំណែកជនសង្ស័យឈ្មោះ សុខ គេចខ្លួនបាត់។

អំពើរបស់ឈ្មោះ សៅ ភេទប្រុស អាយុ១៩ឆ្នាំ (មានខ្លួន) , ឈ្មោះ សុខ ភេទប្រុស អាយុ២១ឆ្នាំ (គេចខ្លួន) ជាបទល្មើស ៖ ហិង្សាដោយចេតនាមានស្ថានទម្ងន់ ប្រព្រឹត្តនៅចំណុច ផ្ទះជួល ផ្លូវលេខ៣៥៧ ភូមិដើមស្លែង

[១] សេចក្តីសង្ខេបអង្គហេតុ

សង្កាត់ច្បារអំពៅ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១២ តាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះ

បើកការស៊ើបសួរលើអង្គហេតុខាងលើ និង ៖

☑ ដាក់ឲ្យស្ថិតក្រោមការពិនិត្យ[២] ៖

១.ឈ្មោះ សៅ ភេទប្រុស អាយុ១៩ឆ្នាំ (មានខ្លួន)

២. ឈ្មោះ សុខ ភេទប្រុស អាយុ២១ឆ្នាំ (គេចខ្លួន)

☐ ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[៣]៖.......................................................................

☑ ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្ន លើឈ្មោះខាងលើដើម្បីបង្ការ ឬបញ្ឈប់បទល្មើស កុំឱ្យកើតឡើងជាថ្មី និងធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី៕

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី....... ខែមិថុនា ឆ្នាំ២០១២

**តំណាងអយ្យការ**

---

[២] ឈ្មោះជនត្រូវចោទ

[៣] កាតព្វកិច្ចណាមួយដែលបានចែងក្នុងមាត្រា ២២៣

នីតិវិធីព្រហ្មទណ្ឌ

នីតិជាតិសាធារណៈ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធ ២

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ក"

លេខ ...................... តព្រ

## ដីកាចាត់ឱ្យស៊ើបសួរបន្ថែម

យើង ឥ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

បានឃើញមាត្រា ១៣១ មាត្រា ១៧៣ មាត្រា ១៧៤ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ.......... ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៦ ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ................. ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦ ។

ដែលទាក់ទងនឹងឈ្មោះ៖

១. វណ្ណនី ហៅ ស ភេទស្រី អាយុ ៣៧ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន ភូមិគ្រោះ ផ្លូវ៦ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប និង ២. សុវណ្ណ ភេទប្រុស គ្មានអត្តសញ្ញាណ និងគូកន ពីបទមនុស្សឃាតដោយចេតនា ។ ប្រព្រឹត្តនៅផ្លូវជាតិលេខ៣ ភូមិព្រៃកី សង្កាត់ភ្លើងឆេះរទេះ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤ នៃច្បាប់ស្តីពីស្ពានទម្ងន់ទោស នៃបទឧក្រិដ្ឋ ។

## សំអាងហេតុ

- តាមរយៈពាក្យបណ្តឹងចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៦ របស់ឈ្មោះ កាន ត្រូវជាឪពុករបស់សពជនរងគ្រោះឈ្មោះ បាន បានបញ្ជាក់ថាឈ្មោះ សុវណ្ណ ប្រើប្រាស់លេខទូរស័ព្ទ ០១២ ៧៦៦ ៥៣៣ ។

- ឈ្មោះ សុវណ្ណ ខាងលើតុលាការនៅតែពុំទាន់ស្គាល់អត្តសញ្ញាណ ច្បាស់លាស់នៅឡើយ ។

## ហេតុដូច្នេះសម្រេច

ប្រគល់សិទ្ធិឱ្យ ឯកឧត្តមប្រធាននាយកដ្ឋាន សន្តិសុខផ្ទៃក្នុង នៃក្រសួងមហាផ្ទៃ ដើម្បីជួយសម្រួលដល់ការបំពេញកិច្ចស៊ើបសួរ ស្វែងរកអត្តសញ្ញាណឈ្មោះ ដែលមានទំនាក់ទំនងនឹងលេខទូរស័ព្ទ ៣៤៤ ខាងលើនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី...... ខែធ្នូ ឆ្នាំ២០១១

**ចៅក្រមស៊ើបសួរ**

ជូនភ្ជាប់មកជាមួយ៖

- ពាក្យបណ្តឹង ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៦ ថតចម្លង ០១ច្បាប់
- ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ.......... អ.យ.យ ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០០៦ ថតចម្លង ០១ច្បាប់

ឧបសម្ព័ន្ធ ៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ភ"

លេខ.............................. តព្រ

## ដីកាបង្គាប់ឱ្យចូលខ្លួន

យើង ភ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

បានឃើញមាត្រា ១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ .......... ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១១ ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ..................ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១១។

ចោទប្រកាន់លើឈ្មោះ សៅ ហៅ វែង ភេទ ប្រុស អាយុ ២៣ឆ្នាំ ពីបទ អំពើលួច ដែលបានប្រព្រឹត្តនៅផ្ទះលេខ១២ ផ្លូវ១២៣ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីខែមិថុនា ឆ្នាំ ២០១០ តាមមាត្រា ៣៥៣, ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

បង្គាប់មកឈ្មោះ សៅ ហៅ វែង ភេទ ប្រុស អាយុ ២៣ឆ្នាំ សញ្ជាតិ ខ្មែរ ទីលំនៅផ្លូវលំ ក្រុម ១ភូមិ១ ឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ មុខរបរ បើកបររថយន្តក្រុមហ៊ុនវីង។

ឱ្យចូលខ្លួនមកកាន់សាលាដំបូងរាជធានីភ្នំពេញ បន្ទប់ស៊ើបសួរ "ភ" នៅថ្ងៃទី.........ខែកញ្ញា ឆ្នាំ២០១១ វេលាម៉ោង ៨: ៣០ ព្រឹក ដើម្បីសួរចម្លើយ ពីដំណើររឿង អំពើលួច ។

សាមីខ្លួនត្រូវយកលិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើនេះមកជាមួយផង ប្រសិនបើមាន ។

ក្នុងករណីមិនចូលខ្លួនតាមកាលកំណត់ខាងលើនេះទេ **<u>យើងនឹងចេញដីកាបង្គាប់ឱ្យនាំខ្លួន</u>** ។

រាជធានីភ្នំពេញ. ថ្ងៃទី ........ខែ សីហា ឆ្នាំ ២០១១

**ចៅក្រមស៊ើបសួរ**

ឧបសម្ព័ន្ធ ៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ភ"

លេខ .................. តព្រ

## ដីកាបង្គាប់ឱ្យនាំខ្លួន

យើង ក ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

បានឃើញមាត្រា ១៨៩ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ................ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ............ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ។

ដែលចោទប្រកាន់លើឈ្មោះ សាន់ ភេទប្រុស អាយុ ៤១ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ នាយកក្រុមហ៊ុនចំរើនកសិឧស្សាហកម្ម អភិវឌ្ឍន៍ (កម្ពុជា) អ៊ឹមផត អិចផត ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ២២B ផ្លូវលេខ ០១ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ពីបទ ឆបោក ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩ តាមមាត្រា ៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

បានឃើញ ចំណារលើដីកាបង្គាប់ឲ្យចូលខ្លួន លើកទី៤ លេខ.......... ត.ព្រ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ របស់លោក ខ នាយរងប៉ុស្តិ៍ចោមចៅ ។

យល់ឃើញថា :
- ជនត្រូវចោទ គេចវេសមិនព្រមទទួល ដីកាបង្គាប់ឲ្យចូលខ្លួនរបស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ចំនួន ៤ លើកមកហើយ ។
- ជនត្រូវចោទមានអត្តសញ្ញាណច្បាស់លាស់ ។
- ជនត្រូវចោទរឹងទទឹង មិនព្រមចូលខ្លួនមកតុលាការ តាមដីកាបង្គាប់ឲ្យចូលខ្លួន ។

ដើម្បីធានាដល់ការស៊ើបសួរឱ្យបានពេញលេញ គប្បីសម្រេចនាំខ្លួនឈ្មោះ សាន់ ភេទប្រុស អាយុ ៤១ឆ្នាំ មកចំពោះមុខចៅក្រមស៊ើបសួរដើម្បីបំភ្លឺការពិត ។

## ហេតុដូច្នេះសម្រេច

១. ឱ្យនាំខ្លួនឈ្មោះ សាន់ ដែលមានអត្តសញ្ញាណខាងលើនេះ ។

២. បង្គាប់មកកងកម្លាំងសាធារណៈ ឱ្យចាប់ និងនាំខ្លួនឈ្មោះខាងលើនេះមកប្រគល់ជូន សាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមច្បាប់ ។

រាជធានីភ្នំពេញ, ថ្ងៃទី ......ខែកុម្ភៈ ឆ្នាំ២០១២

ចៅក្រមស៊ើបសួរ

នីតិវិធីព្រហ្មទណ្ឌ

នីតិជាតិសាធារណៈ

ឧបសម្ព័ន្ធ ៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ភ"

លេខ .................... តព្រ

## ដីកាបង្គាប់ឱ្យចាប់ខ្លួន

យើង ភ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

បានឃើញមាត្រា ១៩៥ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ........... ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១១ ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ.................... ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១១។

បានឃើញដីកាបញ្ជូនឱ្យឆ្លើយលេខ............... តព្រ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ ដោយមានការឯកភាពពីលោកព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ ។

ក្រោយពីបានពិនិត្យលើសំណុំរឿងចប់សព្វគ្រប់ យល់ឃើញថា :

នាមត្រកូល សុខ នាមខ្លួន សាន ហៅ វែង ភេទ ប្រុស អាយុ ២៣ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើត សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្ន ផ្លូវលំ ក្រុម១ ភូមិ១ ឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ មុខរបរ បើកបររថយន្តក្រុមហ៊ុនវីង ឪពុកឈ្មោះ សុខ (រ) ម្តាយឈ្មោះ សៅ (រ)នៅលើវ ។

ត្រូវចោទប្រកាន់ពីបទ អំពើលួច ដែលបានប្រព្រឹត្តនៅផ្ទះលេខ១២ ផ្លូវ១២៣ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពី ខែមិថុនា ឆ្នាំ២០១០ តាមមាត្រា ៣៥៣, ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

**យល់ឃើញថា :** -បទល្មើសខាងលើជាបទមជ្ឈិម ដែលច្បាប់តម្រូវឱ្យផ្តន្ទាទោស ពី៦ខែ ទៅ៣ឆ្នាំ ។

-ជនត្រូវចោទមិនព្រមចូលបង្ហាញខ្លួនតាមដីកាបង្គាប់ឱ្យចូលខ្លួនលេខ .......... ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## ហេតុដូច្នេះសម្រេច

១. ឱ្យចាប់ខ្លួនឈ្មោះសុខ សាន ហៅ វែង ភេទ ប្រុស អាយុ ២៣ឆ្នាំ ដែលមានអត្តសញ្ញាណខាងលើនេះ ។

២. បញ្ជាដល់កងកម្លាំងសាធារណៈ ឱ្យស្រាវជ្រាវរកចាប់ និងនាំខ្លួនឈ្មោះខាងលើនេះ មកប្រគល់ជូនសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមច្បាប់ ។

រាជធានីភ្នំពេញ. ថ្ងៃទី........ ខែមករា ឆ្នាំ២០១២

**ចៅក្រមស៊ើបសួរ**

ឧបសម្ព័ន្ធ ៦

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្ត**

**.........................**

**មន្ទីរស៊ើបសួរ**

សំណុំរឿងលេខៈ.................................

លេខស៊ើបសួរៈ...................................

## កំណត់ហេតុស្ដីពីការពិភាក្សាដេញដោលចំពោះមុខ[1]

(មាត្រា ២០៣ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់............. ខែ............. ថ្ងៃទី................ វេលាម៉ោង.................................

យើង....................................................... ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្ត ........................ អមដោយលោក/លោកស្រី....................................... ជាក្រឡាបញ្ជី ។

និងដោយមានវត្តមានលោក/លោកស្រី....................................... ជាអ្នកបកប្រែ ។

យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ................. ចុះថ្ងៃទី..........ខែ .................. ឆ្នាំ......................... ។

បានមកបង្ហាញខ្លួននៅក្នុងដំណាក់កាលស៊ើបសួរនៅចំពោះមុខយើង ជនដែលមានអត្តសញ្ញាណដូចខាងក្រោមៈ

| | |
|---|---|
| នាមត្រកូល | ៖............................. នាមខ្លួន ៖.................................... |
| កើតថ្ងៃទី | ៖.................................................................................... |
| ទីកន្លែងកំណើត | ៖.................................................................................... |
| អាសយដ្ឋាន | ៖.................................................................................... |
| មុខរបរ | ៖.................................................................................... |

---

[1] កំណត់ហេតុនេះ ត្រូវធ្វើឡើងបន្តពីកំណត់ហេតុស្ដីពីការបង្ហាញខ្លួនលើកដំបូង (នៅក្នុងថ្ងៃតែមួយ)

នៅលីវ ☐ ឬរៀបការ ☐ ឈ្មោះប្ដី ឬប្រពន្ធ ៖.............................. មានកូន.........

សញ្ជាតិ ៖.................................................................................................

ឪពុកឈ្មោះ.............................. រ-ស* ម្ដាយឈ្មោះ.............................. រ-ស*អនីតិជន ☐ ឬនីតិជន ☐

☐ជននេះបានប្រកាសប្រាប់ថា ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០ (ដប់) ឆ្នាំ ដែលស្ថិតនៅលំនៅបច្ចុប្បន្ន ។

ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ:.................................................................

☐ជននេះ ៖ ☐ចេះនិយាយ ☐ ចេះអាន ☐ចេះសរសេរអក្សរខ្មែរ

☐ជននេះ[2] ៖ ☐មិនចេះនិយាយ ☐មិនចេះអាន ☐មិនចេះសរសេរអក្សរខ្មែរ

ជននេះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ ពីបទ៖...................................................

អំពើដែលមានចែង និងផ្ដន្ទាទោសដោយមាត្រា..........នៃច្បាប់....................................
...................................................................................... ។

យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ......................... ចុះថ្ងៃទី............... ខែ............... ឆ្នាំ...................... ។

☐ដោយមានវត្តមាន លោក/លោកស្រីមេធាវី........................................ ដែលជនត្រូវចោទ បានជ្រើសរើសតាំងពាក់ដោយខ្លួនឯង ឬដែលត្រូវបានចាត់តាំងដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានមកបង្ហាញខ្លួននៅក្នុងបន្ទប់នៅចំពោះមុខយើង បន្ទាប់ពីបានពិគ្រោះមើលសំណុំរឿង និងបានធ្វើទំនាក់ទំនងដោយសេរីជាមួយនឹងជនត្រូវចោទ នៅពេលបង្ហាញខ្លួនជាលើកដំបូងនៅចំពោះមុខយើង ។

☐យើងបានប្រាប់ដល់ជនត្រូវចោទថា យើងមានបំណងសម្រេចឃុំខ្លួនគាត់ជាបណ្ដោះអាសន្ន ។

☐យើងបានប្រាប់ថា ជនត្រូវចោទអាចស្នើសុំពន្យារពេលដើម្បីរៀបចំការពារខ្លួន ។

☐យើងក៏បានបញ្ជាក់ប្រាប់ជនត្រូវចោទដែរថា យើងនឹងសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្ននៅថ្ងៃនេះ ។

---

[2]ក្នុងករណីដែលជននេះមិនចេះភាសាខ្មែរ ត្រូវសរសេរអត្តសញ្ញាណរបស់អ្នកបកប្រែចូលក្នុងកំណត់ហេតុ

☐ជនត្រូវចោទមិនទាន់មានជំនួយពីមេធាវីនៅឡើយ ហើយយើងបានបញ្ជាក់ប្រាប់ថា ជនត្រូវចោទមានសិទ្ធិទទួលបានជំនួយពីមេធាវីតាមការជ្រើសរើសដោយខ្លួនឯង ឬពីមេធាវីតាមការចាត់តាំង ។

ជនត្រូវចោទបានប្រកាសប្រាប់ថា៖

☐ខ្ញុំបដិសេធជំនួយពីមេធាវី

☐ខ្ញុំចង់បានជំនួយពីមេធាវីម្នាក់

☐លោក/លោកស្រីមេធាវី.............................................. ត្រូវបានជូនដំណឹងដោយ ............................................. អាចពិគ្រោះមើលសំណុំរឿងដែលទុកឲ្យគាត់ពិនិត្យ និងអាចសន្ទនាដោយសេរីជាមួយកូនក្តីរបស់គាត់ ។

ការពិភាក្សាដេញដោលចំពោះមុខទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន៖

☐ត្រូវបានធ្វើ

☐ត្រូវបានលើកទៅថ្ងៃទី........ខែ............ឆ្នាំ..............តាមសំណូមពររបស់.............. ..............................។

តំណាងអយ្យការបានបង្ហាញសេចក្តីសន្និដ្ឋានរបស់ខ្លួន ដូចខាងក្រោម៖

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

ជនត្រូវចោទបានបង្ហាញសេចក្តីសង្កេតរបស់ខ្លួន ដូចខាងក្រោម៖

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

លោក/លោកស្រីមេធាវី............................................. បានបង្ហាញសេចក្តីសន្និដ្ឋានការពារកូនក្តីរបស់ខ្លួន ដូចខាងក្រោម៖

..........................................................................................................................

..........................................................................................................................

..................................................................................................................................

..................................................................................................................................

☐យើងបានប្រាប់ដល់ជនត្រូវចោទថា យើងសម្រេចចេញដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នដោយមានសំអាងហេតុ ហើយយើងសម្រេចចេញដីកាបង្គាប់ឲ្យឃុំខ្លួននៅថ្ងៃនេះ ។

☐យើងបានឲ្យជនត្រូវចោទអានឡើងវិញនូវសេចក្តីប្រកាសទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឲ្យចុះហត្ថលេខានៅលើកំណត់ហេតុនេះ ។

☐បានអានចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង និងក្រឡាបញ្ជី ។

☐បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង, ក្រឡាបញ្ជី និងអ្នកបកប្រែ ។

**អ្នកបកប្រែ ជនត្រូវចោទ មេធាវី ក្រឡាបញ្ជី ចៅក្រមស៊ើបសួរ**

ឧបសម្ព័ន្ធ ៧

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូង

...................................

មន្ទីរស៊ើបសួរ

សំណុំរឿងលេខ............................

លេខស៊ើបសួរ...............................

## កំណត់ហេតុស្តីពីការសួរចម្លើយតទល់

(មាត្រា ១៤៧ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់.............. ខែ............ ថ្ងៃទី................. វេលាម៉ោង.................................

យើង............................................................. ចៅក្រមស៊ើបសួរនៃសាលាដំបូង ..............................អមដោយលោក/លោកស្រី........................................ ជាក្រឡាបញ្ជី។

និងដោយមានវត្តមានលោក/លោកស្រី........................................ ជាអ្នកបកប្រែ ។

បានមកបង្ហាញខ្លួនក្នុងនាមជាជនត្រូវចោទ នៅក្នុងមន្ទីរស៊ើបសួរ នៅចំពោះមុខយើង ជនដែលមានអត្តសញ្ញាណដូចខាងក្រោម ៖

នាមត្រកូល ៖ ........................... នាមខ្លួន ៖ ..................................................................

កើតថ្ងៃទី ៖ ........................................................................................................

ទីកន្លែងកំណើត ៖ ...............................................................................................

អាសយដ្ឋាន ៖ ......................................................................................................

មុខរបរ ៖ ............................................................................................................

នៅលីវ ☐ ឬរៀបការ ☐ ឈ្មោះប្ដី ឬប្រពន្ធ........................................... កូន............

សញ្ជាតិ ៖ ............................................................................................................

ឪពុកឈ្មោះ..........................................."រ-ស" ម្ដាយឈ្មោះ.......................................... "រ-ស"

អនីតិជន ☐ ឬនីតិជន ☐

☐ជននេះបានប្រកាសប្រាប់ថា ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០ (ដប់) ឆ្នាំ ដែលស្ថិតនៅលំនៅបច្ចុប្បន្ន ។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ.........................................................................

☐ជននេះ ៖ ☐ចេះនិយាយ ☐ ចេះអាន ☐ចេះសរសេរអក្សរខ្មែរ

| ☐ជននេះ:[1] | ៖ ☐មិនចេះនិយាយ | ☐ មិនចេះអាន | ☐មិនចេះសរសេរ អក្សរខ្មែរ |
|---|---|---|---|

បានមកបង្ហាញខ្លួនក្នុងនាម.................................................. ផងដែរ នៅក្នុងមន្ទីរស៊ើបសួរ នៅចំពោះមុខយើង ជនដែលមានអត្តសញ្ញាណដូចខាងក្រោម ៖

នាមត្រកូល ៖ ............................ នាមខ្លួន ៖ ..............................................................................

កើតថ្ងៃទី ៖ ........................................................................................................................

ទីកន្លែងកំណើត ៖ ..............................................................................................................

អាសយដ្ឋាន ៖ ....................................................................................................................

មុខរបរ ៖ ...........................................................................................................................

នៅលីវ ☐ ឬរៀបការ ☐ ឈ្មោះប្តី ឬប្រពន្ធ.................................................................... កូន............

សញ្ជាតិ ៖ ..........................................................................................................................

ឪពុកឈ្មោះ............................................"រ-ស" ម្ដាយឈ្មោះ.............................................. "រ-ស"

អនីតិជន ☐ ឬនីតិជន ☐

☐ជននេះបានប្រកាសប្រាប់ថា ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០ (ដប់) ឆ្នាំ ដែលស្ថិតនៅលំនៅបច្ចុប្បន្ន ។

ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ.................................................................................

| ☐ជននេះ: | ៖ ☐ចេះនិយាយ | ☐ ចេះអាន | ☐ចេះសរសេរអក្សរខ្មែរ |
|---|---|---|---|
| ☐ជននេះ:[2] | ៖ ☐មិនចេះនិយាយ | ☐ មិនចេះអាន | ☐មិនចេះសរសេរ អក្សរខ្មែរ |

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ឈ្មោះនេះ យើងបានប្រាប់ដល់ .................................................... ឲ្យដឹងយ៉ាងច្បាស់អំពីរឿងរ៉ាវ ដែលព្រះរាជអាជ្ញាបានប្តឹងមក យើងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ.......... ចុះថ្ងៃទី......... ខែ.................. ឆ្នាំ................ ដែលជាហេតុនាំឲ្យជននេះ ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ និង ☐ការឃុំខ្លួនបណ្ដោះអាសន្នតាមដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ............ ចុះថ្ងៃទី......... ខែ.................. ឆ្នាំ......................... ។

ជនត្រូវចោទឈ្មោះ....................................................... អមដោយលោក/លោកស្រី ........................................................... ជាមេធាវី ។

ជនត្រូវចោទឈ្មោះ....................................................... អមដោយលោក/លោកស្រី ........................................................... ជាមេធាវី ។

យើងបានសួរចម្លើយតទល់ដូចខាងក្រោម ៖

---

[1] ក្នុងករណីដែលជននេះមិនចេះភាសាខ្មែរ ត្រូវសរសេរអត្តសញ្ញាណរបស់អ្នកបកប្រែចូលក្នុងកំណត់ហេតុ

[2] ក្នុងករណីដែលជននេះមិនចេះភាសាខ្មែរ ត្រូវសរសេរអត្តសញ្ញាណរបស់អ្នកបកប្រែចូលក្នុងកំណត់ហេតុ

សួរ:...............................................................................................................
...................................................................................................................
...................................................................................................................

ឆ្លើយ:.........................................................................................................
...................................................................................................................
...................................................................................................................
...................................................................................................................

☐យើងបានឲ្យជនត្រូវចោទអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឲ្យចុះហត្ថលេខាលើកំណត់ហេតុនេះ ។

☐បានអានចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង និងក្រឡាបញ្ជី ។

☐បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង, ក្រឡាបញ្ជី និងអ្នកបកប្រែ ។[3]

**អ្នកបកប្រែ ជនត្រូវចោទ មេធាវី ក្រឡាបញ្ជី ចៅក្រមស៊ើប**

[3] គ្រប់ទំព័រត្រូវអនុលោមតាមមាត្រា២៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ឧបសម្ព័ន្ធ ៨

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូង

.......................................

មន្ទីរស៊ើបសួរ

សំណុំរឿងលេខ............................

លេខស៊ើបសួរ..............................

## កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ

(មាត្រា ១៨៥ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់.............. ខែ............. ថ្ងៃទី............ វេលាម៉ោង....................................

យើង.............................................................. ចៅក្រមស៊ើបសួរនៃសាលាដំបូង ..............................អមដោយលោក/លោកស្រី.................................... ជាក្រឡាបញ្ជី។

និងដោយមានវត្តមានលោក/លោកស្រី........................................ ជាអ្នកបកប្រែ ។

បានមកបង្ហាញខ្លួនក្នុងនាមជាជនត្រូវចោទ នៅចំពោះមុខយើង ជនដែលមានអត្តសញ្ញាណ ដូចខាងក្រោម ៖

| |
|---|
| នាមត្រកូល ៖ ........................... នាមខ្លួន ៖ ........................................................................ |
| កើតថ្ងៃទី ៖ ........................................................................................................... |
| ទីកន្លែងកំណើត ៖ ................................................................................................. |
| អាសយដ្ឋាន ៖ ....................................................................................................... |
| មុខរបរ ៖ .............................................................................................................. |
| នៅលីវ ☐ ឬរៀបការ ☐ ឈ្មោះប្តី ឬប្រពន្ធ................................................ កូន............ |
| សញ្ជាតិ ៖ ........................................................................................................... |
| ឪពុកឈ្មោះ........................................"រ-ស" ម្តាយឈ្មោះ......................................... "រ-ស" |
| អនីតិជន ☐ ឬនីតិជន ☐ |
| ☐ជននេះបានប្រកាសប្រាប់ថា ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០ (ដប់) ឆ្នាំ ដែលស្ថិតនៅលំនៅបច្ចុប្បន្ន ។ |

| | | | |
|---|---|---|---|
| ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ.................................................................................. | | | |
| ☐ជននេះ | ៖ ☐ចេះនិយាយ | ☐ ចេះអាន | ☐ចេះសរសេរអក្សរខ្មែរ |
| ☐ជននេះ[1] | ៖ ☐មិនចេះនិយាយ | ☐ មិនចេះអាន | ☐មិនចេះសរសេរ អក្សរខ្មែរ |

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ឈ្មោះនេះ យើងបានប្រាប់ដល់ឈ្មោះនេះឲ្យដឹងយ៉ាងច្បាស់អំពីរឿងរ៉ាវ ដែលព្រះរាជអាជ្ញាបានប្តឹងមក យើងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ............ ចុះថ្ងៃទី.......... ខែ............... ឆ្នាំ.................. ដែលជាហេតុនាំឲ្យជននេះ ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ និង ☐ការឃុំខ្លួនបណ្តោះអាសន្នតាមដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ.......... ចុះថ្ងៃទី........ ខែ............ ឆ្នាំ........... ។

ជនត្រូវចោទអមដោយលោក/លោកស្រី................................................... ជាមេធាវី។

យើងបានសួរចម្លើយឈ្មោះនេះ ហើយឈ្មោះនេះបានឆ្លើយប្រាប់យើង ដូចខាងក្រោមថា ៖

សួរ:.............................................................................................................................
.......................................................................................................................................
.......................................................................................................................................

ឆ្លើយ:[2]...........................................................................................................................
.......................................................................................................................................
.......................................................................................................................................
.......................................................................................................................................
.......................................................................................................................................
.......................................................................................................................................
.......................................................................................................................................
.......................................................................................................................................
.......................................................................................................................................
.......................................................................................................................................
.......................................................................................................................................
.......................................................................................................................................

---

[1] ក្នុងករណីដែលជននេះមិនចេះភាសាខ្មែរ ត្រូវសរសេរអត្តសញ្ញាណរបស់អ្នកបកប្រែចូលក្នុងកំណត់ហេតុ
[2] បើជននេះឆ្លើយដោយឯកឯង ត្រូវកត់ចូលក្នុងកំណត់ហេតុដោយមានការបញ្ជាក់

☐យើងបានឲ្យជនត្រូវចោទអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឲ្យចុះហត្ថលេខាលើកំណត់ហេតុនេះ ។

☐បានអានចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង និងក្រឡាបញ្ជី ។

☐បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង, ក្រឡាបញ្ជី និងអ្នកបកប្រែ ។

**អ្នកបកប្រែ ជនត្រូវចោទ មេធាវី ក្រឡាបញ្ជី ចៅក្រមស៊ើបសួរ**

ឧបសម្ព័ន្ធ ៩

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង

..........................

មន្ទីរស៊ើបសួរ

សំណុំរឿងលេខ:......................................

លេខស៊ើបសួរ:........................................

## កំណត់ហេតុស្តីពីការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

(មាត្រា ១៥០ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់............. ខែ............. ថ្ងៃទី................ វេលាម៉ោង..................................

យើង.......................................................... ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្ត ............................ អមដោយលោក/លោកស្រី.......................................... ជាក្រឡាបញ្ជី ។

និងដោយមានវត្តមានលោក/លោកស្រី......................................... ជាអ្នកបកប្រែ ។

បានមកបង្ហាញខ្លួនក្នុងនាមជា ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងដំណាក់កាលស៊ើបសួរ នៅចំពោះមុខយើង ជនដែលមានអត្តសញ្ញាណដូចខាងក្រោម៖

| | | | |
|---|---|---|---|
| នាមត្រកូល | ៖.............................. នាមខ្លួន ៖.................................................. | | |
| កើតថ្ងៃទី | ៖........................................................................................ | | |
| ទីកន្លែងកំណើត | ៖........................................................................................ | | |
| អាសយដ្ឋាន | ៖........................................................................................ | | |
| មុខរបរ | ៖........................................................................................ | | |
| នៅលីវ ☐ | ឬរៀបការ ☐ ឈ្មោះប្តី ឬប្រពន្ធ ៖.............................. មានកូន.......... | | |
| សញ្ជាតិ | ៖........................................................................................ | | |
| ឪពុកឈ្មោះ.............................. "រ-ស" ម្តាយឈ្មោះ.............................. "រ-ស"អនីតិជន ☐ ឬនីតិជន ☐ | | | |
| ☐ជននេះ: | ៖ ☐ចេះនិយាយ | ☐ ចេះអាន | ☐ចេះសរសេរអក្សរខ្មែរ |
| ☐ជននេះ:[1] | ៖ ☐មិនចេះនិយាយ | ☐មិនចេះអាន | ☐មិនចេះសរសេរអក្សរខ្មែរ |

[1]ក្នុងករណីដែលជននេះមិនចេះភាសាខ្មែរ ត្រូវសរសេរអត្តសញ្ញាណរបស់អ្នកបកប្រែចូលក្នុងកំណត់ហេតុ

| លោក/លោកស្រី...................................................................... ជាមេធាវី |
|---|

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ជននេះ ឲ្យដឹងយ៉ាងច្បាស់អំពីរឿងរ៉ាវ ដែលព្រះរាជអាជ្ញាបានប្តឹងមកយើងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ............... ចុះថ្ងៃទី........... ខែ........... ឆ្នាំ ...................... ។

យើងបានសួរ និងស្តាប់ចម្លើយឈ្មោះនេះដូចខាងក្រោមថា ៖

សួរ:.....................................................................................................................

.............................................................................................................................

.............................................................................................................................

ឆ្លើយ:..................................................................................................................

.............................................................................................................................

.............................................................................................................................

.............................................................................................................................

.............................................................................................................................

☐យើងបានឲ្យដើមបណ្តឹងរដ្ឋប្បវេណី អានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឲ្យចុះហត្ថលេខាលើកំណត់ហេតុនេះ ។

☐បានអានចប់សព្វគ្រប់ ហើយដើមបណ្តឹងរដ្ឋប្បវេណីមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង និងក្រឡាបញ្ជី ។

